**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ផែនការ
# អភិវឌ្ឍន៍សមត្ថភាពរបស់
# គ.ជ.អ.ប ឆ្នាំ២០១២

**លេខាធិការដ្ឋាន គ.ជ.អ.ប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
លេខ:..០២៥/...អវអនប
/១២

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៣ ឆ្នាំ២០១២

## សូមគោរពជូន
## ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**តាមរយៈ** : ឯកឧត្តម ហ៊ាន់ ចំរើន អនុប្រធានប្រតិបត្តិរបស់លេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ** : ស្នើសុំពិនិត្យ និងសម្រេចលើផែនការអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១២។

**យោង** :ប្រកាសលេខ១៦៥ ប្រក/គ.ជ.អ.ប ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមថា ដោយសហការ និងសម្របសម្រួលជាមួយអនុកម្មវិធីនានារបស់ផអ៣ អង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ២០១២ របស់គ.ជ.អ.ប។ ដើម្បីងាយស្រួលក្នុងការអនុវត្ត និងតាមដានការអនុវត្ត ក្រុមការងារបានរៀបចំដោយបែងចែកប្រធានបទនៃការអភិវឌ្ឍសមត្ថភាពតាមអនុកម្មវិធី នីមួយៗ។ ជាមួយគ្នានេះ ផែនការអភិវឌ្ឍសមត្ថភាពនេះ ក៏បានបញ្ចូលនូវប្រធានបទនានាដែលរាជធានី ខេត្តបានកំណត់សម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងរាជធានី ខេត្តរបស់ខ្លួននីមួយៗផងដែរ។

ដើម្បីធានា ខ្លឹមសារ ពេលវេលា ចំនួនថវិកាដែលមានរៀបចំមានលក្ខណៈត្រឹមត្រូវតាមការគ្រោងទុក និងស្របតាមការកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២ អង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយបានរៀបចំកិច្ចប្រជុំជាមួយអនុកម្មវិធី និងអ្នកពាក់ព័ន្ធទាំងអស់នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ កន្លងទៅនេះ។ ជាលទ្ធផល ផែនការអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១២នេះ មានចំនួន ៧៨ប្រធានបទ ក្នុងនោះ អនុកម្មវិធីទី០១មានចំនួន២៣ប្រធានបទ អនុកម្មវិធីទី២មានចំនួន០៨ប្រធានបទ អនុកម្មវិធីទី៣មានចំនួន០១ប្រធានបទ អនុកម្មវិធីទី៤មានចំនួន០៦ប្រធានបទ អនុកម្មវិធីទី៥មានចំនួន០៥ប្រធានបទ អនុកម្មវិធីទី៦មានចំនួនចំនួន០១ប្រធានបទ និងប្រធានបទដែលរាជធានី ខេត្តបានកំណត់សម្រាប់ការបណ្តុះបណ្តាលនៅរាជធានី ខេត្តរបស់ខ្លួនផ្សេងៗគ្នាមានចំនួនសរុប៣៤ប្រធានបទ។ ជាមួយគ្នានេះ ដើម្បីគាំទ្រដល់ការអនុវត្តការអភិវឌ្ឍសមត្ថភាពនេះ នឹងត្រូវចំណាយថវិកាប៉ាន់ស្មានសរុបប្រមាណចំនួន ១,៨៦៣,៦១៩ដុល្លារ ដែលថវិកានេះ ត្រូវបានគ្រោងក្នុងផែនការសកម្មភាព នឹងថវិកាប្រចាំឆ្នាំ២០១២រួចហើយ។

បន្ទាប់ពីទទួលបានការពិនិត្យ និងឯកភាពពីថ្នាក់ដឹកនាំ គ.ជ.អ.ប ផែនការអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១២ នេះនឹងត្រូវប្រែសម្រួលជាភាសាអង់គ្លេស និងថតចម្លង និងបែងចែកទៅគ្រប់ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធី ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប រដ្ឋបាលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀត។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាពិនិត្យ សម្រេចដោយអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

02/04/12

**ហ៊ាន់ ចំរើន**

**ប្រធានអង្គភាព**
**វិភាគ និងអភិវឌ្ឍគោលនយោបាយ**

Sothea

# មាតិកា

សេចក្តីផ្តើម ១

## អនុកម្មវិធីទី១ : លេខាធិការដ្ឋាន គ.ជ.អ.ប

១.១. ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៧
១.២. ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ៩
១.៣. វគ្គតម្រង់ទិសដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប ១១
១.៤. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងតួនាទីរបស់ទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប ១៣
១.៥. វគ្គតម្រង់ទិសសម្រាប់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ១៤
១.៦. សិក្ខាសាលាស្តីពីយុទ្ធសាស្ត្រផ្តល់សេវាប្រឹក្សាយោបល់ក្រុមប្រឹក្សា ១៦
១.៧. សិក្ខាសាលាស្តីពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ១៧
១.៨. សិក្ខាសាលាជាតិផ្លាស់ប្តូរបទពិសោធន៍ស្តីពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល ១៨
១.៩. ការតាមដាន និងវាយតម្លៃសម្រាប់ថ្នាក់រាជធានី ខេត្ត ២០
១.១០. ការតាមដាន និងវាយតម្លៃសម្រាប់ក្រសួង ស្ថាប័ន ២១
១.១១. ប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា ២២
១.១២. វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអព ២៤
១.១៣. ប្រព័ន្ធទិន្នន័យតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២៦
១.១៤. ការរៀបចំតារាង AWPB តាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់អនុកម្មវិធី និងថ្នាក់ក្រោមជាតិ ២៧
១.១៥. ភាពជាអ្នកដឹកនាំ និងបណ្តាញការងារ ២៩
១.១៦. ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអព ៣១
១.១៧. ការពង្រឹងតួនាទីអនុប្រធានអចិន្ត្រៃយ៍របស់ គ.ក.ស.ក និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ ៣២
១.១៨. ការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី តេស្តបេគុង ឋានលេខា និង អីភីអេស ៣៤
១.១៩. វគ្គតម្រង់ទិសសម្រាប់សវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ៣៦
១.២០. សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការរៀបចំគម្រោងថ្នាក់ក្រោមជាតិ ៣៧
១.២១. ប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន ៣៩
១.២២. ការបណ្តុះបណ្តាលទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ ៤០
១.២៣. ដំណើរការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៤៣

## អនុកម្មវិធីទី២ : ក្រសួងមហាផ្ទៃ


២.១. ការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ៤៦

២.២. កិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៤៨

២.៣. វគ្គតម្រង់ទិសស្ដីពីការអភិវឌ្ឍស្ថាប័ន ៥០

២.៤. ជំនាញអភិវឌ្ឍន៍ស្ថាប័ន ៥១

២.៥. ទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ ៥៣

២.៦. វគ្គរំលឹកឡើងវិញស្ដីពីជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព ៥៤

២.៧. ជំនាញអភិវឌ្ឍន៍សមត្ថភាពសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ៥៥

២.៨. សេវាសង្គមសម្រាប់ គ.ក.ស.ក និង គ.ក.ន.ក ៥៧


## អនុកម្មវិធីទី៣ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ


៣.១. ផ្សព្វផ្សាយអំពីគោលនយោបាយ និងគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ៦០


## អនុកម្មវិធីទី៤ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


៤.១. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអ៣ ៦២

៤.២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ៦៤

៤.៣. ការអនុវត្តថវិកាក្រុង ស្រុក ឆ្នាំ២០១២ ៦៦

៤.៤. សិក្ខាសាលាពិនិត្យលើឯកសារបណ្ដុះបណ្ដាល និងសៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ៦៧

៤.៥. បណ្ដុះបណ្ដាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ ៦៩

៤.៦. ការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ប្រចាំឆ្នាំ ៧០


## អនុកម្មវិធីទី៥ : ក្រសួងផែនការ


៥.១. ដំណើរការកសាងផែនការឃុំ សង្កាត់ ៧៣

៥.២. ការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ ៧៤

៥.៣. ការរៀបចំវេទិកាស្ដីពីកម្មវិធីវិនិយោគរាជធានី ខេត្ត និងការរៀបចំសិក្ខាសាលាសមាហរណ

កម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ រួមទាំងវិធីសាស្ត្រឆ្លើយតប និងបញ្ហាបយេនឌ័រ ៧៥
៥.៤. ការប្រមូលទិន្នន័យមូលដ្ឋាន ភូមិ ឃុំ សង្កាត់ សម្រាប់តម្រូវការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៧៦
៥.៥. ការកែច្នៃ និងការផលិតឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និង រាជធានី ខេត្ត ៧៨

## អនុកម្មវិធីទី៦ : សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់

៦.១. សញ្ញាណមូលដ្ឋាននៃសមាគមអាជ្ញាធរមូលដ្ឋាន (ទ្រឹស្តី និងឧទាហរណ៍) ៧៩

**វគ្គបណ្តុះបណ្តាលដែលកំណត់ដោយរាជធានី ខេត្ត** ៨១

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : កាលវិភាគបណ្តុះបណ្តាលរបស់ គ.ជ.អ.ប ឆ្នាំ២០១២ ៨៧
ឧបសម្ព័ន្ធទី២ : ថវិកាប៉ាន់ស្មានសម្រាប់ការបណ្តុះបណ្តាលរបស់ គ.ជ.អ.ប ឆ្នាំ២០១២ ៩០

# សេចក្តីផ្តើម

ផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។ ផែនការនេះផ្តោតសំខាន់លើការរៀបចំឡើងនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង រួមជាមួយនឹងការបង្កើត និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យក្លាយជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ដោយរួមបញ្ចូលទាំងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ នាពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងសំខាន់ៗនៃរដ្ឋបាលថ្នាក់នេះ ត្រូវបានរៀបចំឡើងវិញ និងកំពុងត្រូវបានដាក់ឱ្យដំណើរការជាបណ្តើរៗ ក្នុងស្ថានភាពមួយដែលមានតម្រូវការយ៉ាងខ្លាំងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន។

អាស្រ័យហេតុនេះ កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យនៃការងារកំណែទម្រង់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមន័យនេះ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ កន្លងមក ទោះបីជាគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានផ្តល់ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សា មន្ត្រី និងបុគ្គលិករបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិហើយក្តី ក៏សមត្ថភាពរបស់ក្រុមប្រឹក្សា មន្ត្រី និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះនៅមានការខ្វះចន្លោះនៅឡើយ ពិសេសតម្រូវការយល់ដឹងលើការអនុវត្តមុខងាររបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្ត ដែលទើបនឹងប្រកាសដាក់ឱ្យប្រើប្រាស់។ ដូច្នេះចាំបាច់ត្រូវតែធ្វើការកសាង និងពង្រឹងដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ អាចអនុវត្តមុខងាររបស់ខ្លួនស្របតាមគោលការណ៍ និងក្របខ័ណ្ឌច្បាប់ដែលបានកំណត់។

ដោយយល់ឃើញថា ការកសាងសមត្ថភាពមានសារសំខាន់ និងចាំបាច់ ទើបគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំ និងចងក្រងឯកសារផែនការអភិវឌ្ឍន៍សមត្ថភាពរបស់ គ.ជ.អ.ប សម្រាប់ឆ្នាំ២០១២នេះឡើង ដោយមានការសម្របសម្រួល និងដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍សមត្ថភាពរបស់អនុកម្មវិធីនានានៃផអ៣ ក្នុងគោលបំណងដើម្បីបង្កើតជាផែនការជាក់លាក់សម្រាប់ការកសាងសមត្ថភាពដល់តួអង្គសំខាន់ៗក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងដើម្បីងាយស្រួលក្នុងការសម្របសម្រួលក្នុងការផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាព ព្រមទាំងផ្តល់ជាព័ត៌មាន និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានាសម្រាប់គាំទ្រការកសាងសមត្ថភាពទាំងនោះផងដែរ។

ឯកសារផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១២នេះ ត្រូវបានរៀបរៀងឡើង ដោយបែងចែកប្រធានបទតាមអនុកម្មវិធីនីមួយៗរបស់ ផអ៣ និងបញ្ចូលនូវប្រធានបទនានាដែលរាជធានី ខេត្តបានកំណត់សម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងរាជធានី ខេត្តរបស់ខ្លួននីមួយៗផងដែរ ។ នៅតាមប្រធានបទនីមួយៗនឹងបរិយាយអំពីប្រវត្តិ ខ្លឹមសារសំខាន់ៗ យុទ្ធសាស្ត្រ ពេលវេលា និងថវិកាគ្រោងសម្រាប់ប្រធានបទនីមួយៗនោះ ។

ទោះបីជាផែនការកសាងសមត្ថភាពនេះត្រូវបានរៀបចំ និងចងក្រងដោយផ្អែកលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២ និងតាមរយៈការវិភាគតួនាទី ភារកិច្ច ការសិក្សាអំពីតម្រូវការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០១២ ព្រមទាំងផ្អែកលើព័ត៌មានដែលផ្ដល់ដោយអង្គការសង្គមស៊ីវិលនានាក៏ដោយ ក៏ផែនការកសាងសមត្ថភាពនេះមិនទាន់មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយ ដូច្នេះ គ.ជ.អ.ប នឹងរង់ចាំទទួលនូវការផ្ដល់យោបល់កែលម្អនានាពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើ នៅក្នុងឆ្នាំ២០១២នេះ តាមរយៈអនុកម្មវិធីនានានៃផអ៣ គ.ជ.អ.ប បានគ្រោងរៀបចំការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើប្រធានបទសំខាន់ៗដូចខាងក្រោម ៖

**អនុកម្មវិធីទី១ "លេខាធិការដ្ឋាន គ.ជ.អ.ប"** មានប្រធានបទចំនួន ២៣ ដូចខាងក្រោម ៖

១.១. ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ

១.២. ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ

១.៣. វគ្គតម្រង់ទិសដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប

១.៤. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងតួនាទីរបស់ទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប

១.៥. វគ្គតម្រង់ទិសសម្រាប់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

១.៦. សិក្ខាសាលាស្ដីពីយុទ្ធសាស្ត្រផ្ដល់សេវាប្រឹក្សាយោបល់ក្រុមប្រឹក្សា

១.៧. សិក្ខាសាលាស្ដីពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

១.៨. សិក្ខាសាលាជាតិផ្លាស់ប្ដូរបទពិសោធន៍ស្ដីពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល

១.៩. ការតាមដាន និងវាយតម្លៃសម្រាប់ថ្នាក់រាជធានី ខេត្ត

១.១០. ការតាមដាន និងវាយតម្លៃសម្រាប់ក្រសួង ស្ថាប័ន

១.១១. ប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

១.១២. វគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញ ស្ដីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអ៣

១.១៣. ប្រព័ន្ធទិន្នន័យតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

១.១៤. ការរៀបចំតារាង AWPB តាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់អនុកម្មវិធី និងថ្នាក់ក្រោមជាតិ
១.១៥. ភាពជាអ្នកដឹកនាំ និងបណ្ដាញការងារ
១.១៦. ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអព
១.១៧. ការពង្រឹងតួនាទីអនុប្រធានអចិន្ត្រៃយ៍របស់ គ.ក.ស.ក និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ
១.១៨. ការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី តេស្តបេតុង ឋានលេខា និង អ៊ីភីអេស
១.១៩. វគ្គតម្រង់ទិសសម្រាប់សវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
១.២០. សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការរៀបចំគម្រោងថ្នាក់ក្រោមជាតិ
១.២១. ប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
១.២២. ការបណ្ដុះបណ្ដាលទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ
១.២៣. ដំណើរការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**អនុកម្មវិធីទី២ "ក្រសួងមហាផ្ទៃ"** មានប្រធានបទចំនួន ០៨ ដូចខាងក្រោម ៖

២.១. ការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក
២.២. កិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ
២.៣. វគ្គតម្រង់ទិសស្តីពីការអភិវឌ្ឍស្ថាប័ន
២.៤. ជំនាញអភិវឌ្ឍន៍ស្ថាប័ន
២.៥. ទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ
២.៦. វគ្គរំលឹកឡើងវិញស្តីពីជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព
២.៧. ជំនាញអភិវឌ្ឍន៍សមត្ថភាពសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត
២.៨. សេវាសង្គមសម្រាប់ គ.ក.ស.ក និង គ.ក.ន.ក

**អនុកម្មវិធីទី៣ "រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ"** មានប្រធានបទចំនួន០១ ដូចខាងក្រោម ៖

៣.១. ផ្សព្វផ្សាយអំពីគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

**អនុកម្មវិធីទី៤ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"** មានប្រធានបទចំនួន ០៦ ដូចខាងក្រោម ៖

៤.១. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអព

៤.២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក

៤.៣. ការអនុវត្តថវិកាក្រុង ស្រុក ឆ្នាំ២០១២

៤.៤. សិក្ខាសាលាពិនិត្យលើឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

៤.៥. បណ្តុះបណ្តាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ

៤.៦. ការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ប្រចាំឆ្នាំ

**អនុកម្មវិធីទី៥ "ក្រសួងផែនការ"** មានប្រធានបទចំនួន ០៥ ដូចខាងក្រោម ៖

៥.១. ដំណើរការកសាងផែនការឃុំ សង្កាត់

៥.២. ការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ

៥.៣. ការរៀបចំវេទិកាស្តីពីកម្មវិធីវិនិយោគរាជធានី ខេត្ត និងការរៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ រួមទាំងវិធីសាស្ត្រឆ្លើយតប និងបញ្ហាបយេនឌ័រ

៥.៤. ការប្រមូលទិន្នន័យមូលដ្ឋាន ភូមិ ឃុំ សង្កាត់ សម្រាប់តម្រូវការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៥.៥. ការកែច្នៃ និងការផលិតឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត

**អនុកម្មវិធីទី៦ "សម្ព័ន្ធភាពជាតក្រុមប្រឹក្សាឃុំ សង្កាត់"** មានប្រធានបទចំនួន ០១ ដូចខាងក្រោម ៖

៦.១. សញ្ញាណមូលដ្ឋាននៃសមាគមអាជ្ញាធរមូលដ្ឋាន (ទ្រឹស្តី និងឧទាហរណ៍)

ជាមួយគ្នានេះ រាជធានី ខេត្តបានកំណត់នូវប្រធានសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងរាជធានី ខេត្តរបស់ខ្លួនបន្ថែមទៀតដោយឡែក១ពីគ្នា។ ជារួម រាជធានី ខេត្តបានកំណត់មានចំនួន៣៤ប្រធានបទ ដូចខាងក្រោម ៖

១. រំលឹកឡើងវិញស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

២. រំលឹកឡើងវិញស្តីពីការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់

៣. រំលឹកឡើងវិញស្តីពីនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុឃុំ សង្កាត់

៤. វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

៥. រំលឹកឡើងវិញស្តីពីគោលនយោបាយសុវត្ថិភាពដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិច

៦. រំលឹកឡើងវិញស្តីពីការរៀបចំផែនការ ការតាមដាន ត្រួតពិនិត្យ និងរបាយការណ៍ ផអ៣

៧. ការរៀបចំថវិកាឆ្នាំ២០១៣ ការបិទគណនេយ្យឆ្នាំ២០១២ និងការទូទាត់

៨. ការប្រមូល ការផលិត និងការចែកចាយទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់សម្រាប់តម្រូវការកសាងផែនការ

៩. វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងព័ត៌មានវិទ្យា

១០. សិក្ខាសាលាត្រួតពិនិត្យ ឆ្លុះបញ្ចាំង ការអនុវត្ត ផអ៣ ចុងឆ្នាំថ្នាក់ខេត្ត

១១. ការគ្រប់គ្រង ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

១២. រំលឹកឡើងវិញស្តីពីអភិបាលកិច្ចល្អសម្រាប់ឃុំ សង្កាត់

១៣. រំលឹកឡើងវិញស្តីពីតួនាទី គ.ក.ន.ក និងការអនុវត្តគម្រោងសេវាសង្គម

១៤. បណ្តុះបណ្តាលស្តីពីការកសាងកម្មវិធីវិនិយោគ ខេត្ត ក្រុង ស្រុក រួមទាំងវិធីសាស្ត្រឆ្លើយតបនិងបញ្ច្រាបយេនឌ័រ

១៥. ការសរសេរសំណើគម្រោងខ្នាតតូចសម្រាប់ឃុំ សង្កាត់

១៦. វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃការងារឃុំ សង្កាត់ និងការប្រមូលទិន្នន័យ

១៧. រំលឹកឡើងវិញស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

១៨. រំលឹកឡើងវិញស្តីពីការប្រើប្រាស់ឧបករណ៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការគណនា (មូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធ)

១៩. រំលឹកឡើងវិញស្តីពីជំនាញបណ្តុះបណ្តាល និងទស្សនយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព

២០. សិក្ខាសាលាឆ្លុះបញ្ចាំងពីការវិភាគចំណុចខ្លាំងនិងខ្សោយនៃការអនុវត្តមុខងារនិងសមត្ថភាពក្រុមប្រឹក្សាឃុំ

២១. បណ្តុះបណ្តាលអំពីការតាមដាន និងវាយតម្លៃសម្រាប់ក្រុង ស្រុក ខណ្ឌ

២២. វគ្គតម្រង់ទិសស្តីពីការប្រើប្រាស់ប្រព័ន្ធ PID DIS PDB CDB និង BID

២៣. វគ្គផ្សព្វផ្សាយស្តីពីគោលនយោបាយគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងសារពើភ័ណ្ឌ

២៤. រំលឹកឡើងវិញស្តីពីការអនុវត្តកិច្ចសន្យា និងបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់

២៥. វគ្គតម្រង់ទិសអំពីការគ្រប់គ្រងការិយាល័យ

២៦. វគ្គបណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួលសម្រាប់ការិយាល័យកិច្ចការនារីស្រុក ដើម្បីគាំទ្រ
ដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារនៃគ.ក.ន.ក ឃុំ សង្កាត់

២៧. វគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីលទ្ធកម្ម

២៨. រំលឹកឡើងវិញស្តីពីការសិក្សា និងស្តង់ដារបច្ចេកទេសគម្រោងឃុំ សង្កាត់

៣៩. ការប្រមូលទិន្នន័យរដ្ឋបាលក្រុង ស្រុកឆ្នាំ២០១២

៣០. វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ

៣១. វគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីជាតិ និងផែនការអនុវត្តបីឆ្នាំដំបូងដល់ក្រុមប្រឹក្សាខេត្ត មន្ទីរជំនាញ

៣២. វគ្គបណ្តុះបណ្តាលស្តីពី អូតូខេត

៣៣. វគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣៤. រំលឹកឡើងវិញស្តីពីតួនាទី និងរបៀបរបបការងាររបស់មេភូមិ

# អនុកម្មវិធីទី១

# ផ្នែកទី១
# អនុកម្មវិធីទី១ "លេខាធិការដ្ឋាន គ.ជ.អ.ប"

ក្នុងឆ្នាំ២០១២នេះ លេខាធិការដ្ឋាន គ.ជ.អ.ប ដែលជាស្ថាប័នទទួលអនុវត្តអនុកម្មវិធីទី១ និងទី១.ខ គ្រោងរៀបចំការអភិវឌ្ឍសមត្ថភាពដល់ក្រុមគោលដៅនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើប្រធានបទសំខាន់ៗចំនួន២៣ ដូចខាងក្រោម ៖

## ១.១. ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
(កូដ 1.4.1.3)

### ក). ប្រវត្តិ

ចំនុចសំខាន់របស់ផអ៣ គឺផ្តោតទៅលើកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេស នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្លាយជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។ ដោយផ្អែកតាមស្ថានភាពបច្ចុប្បន្ន សមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌភាគច្រើនហាក់ដូចជានៅមានកម្រិតទាបនៅឡើយក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិសេសក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ អាស្រ័យហេតុនេះ ការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសមត្ថភាពនឹងត្រូវអនុវត្តជាបន្តបន្ទាប់ក្នុង ផអ៣ ដំបូងនេះ។

ដើម្បីមានមូលដ្ឋានក្នុងការវាស់វែងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការបណ្តុះបណ្តាលស្តីពីការរៀបចំទិន្នន័យដើមគ្រានៃសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០១២ របស់ គ.ជ.អ.ប។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃការរៀបចំទិន្នន័យដើមគ្រា
- សមត្ថភាព និងឧបករណ៍វាស់វែងសមត្ថភាព
- ដំណើរការប្រមូលទិន្នន័យ
- យន្តការគាំទ្រ

ក្រុមការងាររៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ មួយត្រូវបានបង្កើតឡើង ដែលមានសមាសភាពមកពីលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាកំណែទម្រង់។ ក្រុមការងារនេះនឹងពិនិត្យលើខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង

ស្រុក ខណ្ឌ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដើម្បីរៀបចំសូចនាករ បញ្ជីសំណួរសម្រាប់វាស់វែងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ព្រមទាំងសៀវភៅណែនាំ និងវិធីសាស្ត្របណ្តុះបណ្តាល ហើយដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៧២រូប (០៣រូប/រាជធានី ខេត្តក្នុងនោះមកពី ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត០១រូប ទីប្រឹក្សាអភិវឌ្ឍសមត្ថភាពថ្នាក់រាជធានី ខេត្ត០១រូប និងមន្ត្រីព័ត៌មានវិទ្យារាជធានី ខេត្ត០១រូប)។ ការបណ្តុះបណ្តាលត្រូវបានចែកជា០២ថ្នាក់ ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប ៣៦នាក់។ ការបណ្តុះបណ្តាលនេះមានរយៈពេល ០២ថ្ងៃ។
- **ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត :** បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅរាជធានី ខេត្តរបស់ខ្លួនដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ដោយរួមបញ្ចូលទាំងទីប្រឹក្សាកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ត្រីជំនួយការព័ត៌មានវិទ្យាថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ ដើម្បីឱ្យក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធទាំងនេះមានសមត្ថភាពក្នុងការគាំទ្រ និងសម្របសម្រួលការប្រមូលទិន្នន័យនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមករា-កុម្ភៈ ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែ មីនា ឆ្នាំ២០១២ : បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែ មីនា ឆ្នាំ២០១២ : បណ្តុះបណ្តាលក្រុមការងារអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ៨,០៨២ ដុល្លារ
- បណ្តុះបណ្តាលក្រុមការងារអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត : ៦,៦៩២ ដុល្លារ

**<u>សរុប : ១៤,៧៧៤ ដុល្លារ</u>**

## ១.២. ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពជាតិសម្រាប់ ផអ៣

(កូដ 1.1.1.6)

### ក). ប្រវត្តិ

ផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។ ផអ៣ គឺជាផែនការមួយដែលមានលក្ខណៈទូលំទូលាយសម្រាប់ការងារកំណែទម្រង់របស់ "រាជរដ្ឋាភិបាលទាំងមូល" នៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់។ ដូច្នេះ ការអភិវឌ្ឍសមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យ ឬបរាជ័យនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រប់លំដាប់ថ្នាក់ ក៏ដូចជានៅក្នុងស្ថាប័នផ្សេងទៀតដែលគាំទ្រដល់រដ្ឋបាលទាំងនេះ។ អាស្រ័យហេតុនេះ អនុកម្មវិធីទាំង៦នៃផអ៣ដែលផ្ដោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាព ដែលត្រូវធ្វើការសម្របសម្រួលជាមួយគ្នា ដើម្បីតម្រឹមឱ្យស្របជាមួយនឹងគោលនយោបាយជាតិនានា ហើយសមត្ថភាពទាំងអស់ត្រូវធ្វើការចាត់អាទិភាព និងធ្វើសុខុដុមនីយកម្ម ដើម្បីឈានទៅសម្រេចបាននូវសមិទ្ធផលនានាដែលបានគ្រោងទុក។

ក្របខ័ណ្ឌជាតិស្ដីពីការអភិវឌ្ឍសមត្ថភាពនេះ គឺជារចនាសម្ព័ន្ធទស្សនទានជាមូលដ្ឋាន ដែលនឹងត្រូវប្រើប្រាស់ ដើម្បីអនុវត្តការអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅក្នុងផអ៣ទាំងមូល។ ក្របខ័ណ្ឌនេះ ផ្ដល់នូវល័ក្ខខ័ណ្ឌចាំបាច់នានាសម្រាប់ការអភិវឌ្ឍសមត្ថភាព ដោយរួមបញ្ចូលទាំងការកំណត់អំពីអត្ថន័យ វិសាលភាព អ្នកពាក់ព័ន្ធ យុទ្ធសាស្ត្រ ព្រមទាំងការគ្រប់គ្រង និងការសម្របសម្រួលដំណើរការនានានៃការអភិវឌ្ឍសមត្ថភាពនៅក្នុងផអ៣។

ដោយយល់ឃើញពីភាពចាំបាច់នៃការរៀបចំក្របខ័ណ្ឌជាតិស្ដីពីការអភិវឌ្ឍសមត្ថភាពនេះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិនិត្យមើលឡើងវិញ ព្រមទាំងធ្វើការកែសម្រួលនូវក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពជាតិសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍រយៈពេលបីឆ្នាំ និងផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់។ អាស្រ័យហេតុនេះ លេខាធិការដ្ឋានបានបញ្ចូលការបណ្ដុះបណ្ដាលស្ដីពីក្របខ័ណ្ឌជាតិអភិវឌ្ឍន៍សមត្ថភាពទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០១២។

### ខ). ខ្លឹមសារនៃការបណ្ដុះបណ្ដាល

វគ្គបណ្ដុះបណ្ដាលនេះ ផ្ដោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាព
- ការគ្រប់គ្រងការអភិវឌ្ឍសមត្ថភាព
- ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព
- ការរៀបចំរបាយការណ៍អភិវឌ្ឍន៍សមត្ថភាព

- យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព
- វិធីសាស្ត្រអភិវឌ្ឍន៍សមត្ថភាព
- របាយការណ៍អភិវឌ្ឍន៍សមត្ថភាព
- ការបញ្ជ្រាបយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព
- ការតាមដានត្រួតពិនិត្យអំពីការអភិវឌ្ឍសមត្ថភាព
- អ្នកផ្ដល់សេវាអភិវឌ្ឍន៍សមត្ថភាព
- របៀបផ្ទេរចំណេះដឹងពីទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាទៅមន្ត្រីរដ្ឋាភិបាល

ការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិកាដ្ឋាន គ.ជ.អ.ប នឹងសម្របសម្រួលក្នុងការពិនិត្យ និងកែសម្រួលក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពជាតិសម្រាប់អនុវត្តផអ៣ ដែលបានរៀបចំ និងដាក់បញ្ចូលក្នុងឯកសារ ផអ៣។ ការពិនិត្យ និងកែសម្រួលត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានា ពិសេសអនុកម្មវិធីទាំង០៦នៃផអ៣ និងអនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់ពីបានពិនិត្យ និងកែសម្រួល លេខាធិការដ្ឋាន គ.ជ.អ.ប នឹងដាក់សេចក្ដីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពជាតិនេះជូនប្រធាន គ.ជ.អ.ប ពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការឯកភាពពីប្រធាន គ.ជ.អ.ប ក្រុមការងារនៃការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិកាដ្ឋាន គ.ជ.អ.ប នឹងរៀបចំឯកសារសម្រាប់ការបណ្ដុះបណ្ដាល។

**គ). យុទ្ធសាស្ត្រនៃការបណ្ដុះបណ្ដាល**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្ដុះបណ្ដាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្ដុះបណ្ដាលដល់ក្រសួង ស្ថាប័នអនុកម្មវិធី :** ក្រុមការងារនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងផ្ដល់ការបណ្ដុះបណ្ដាលដល់តំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ពិសេសក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីរបស់ ផអ៣។ ដូច្នេះក្រសួង ស្ថាប័ននីមួយៗនឹងចាត់បញ្ជូនតំណាងរបស់ខ្លួនចំនួន០៣រូប ឱ្យមកចូលរួមការបណ្ដុះបណ្ដាលនេះ។ ការបណ្ដុះបណ្ដាលនេះមានរយៈពេល០២ថ្ងៃ។
- **ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៧២រូប (០៣រូប/រាជធានី ខេត្ត ក្នុងនោះមកពីក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត០២រូប ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត០១រូប។ ការបណ្ដុះបណ្ដាលត្រូវបានចែកជា០២ថ្នាក់ ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប ៣៦នាក់។ ការបណ្ដុះបណ្ដាលនេះមានរយៈពេល០២ថ្ងៃ។

- **ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត :** បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅរាជធានី ខេត្តរបស់ខ្លួនដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ដោយរួមបញ្ចូលទាំងទីប្រឹក្សាកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ។

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ មេសា-ឧសភា ឆ្នាំ២០១២ : ពិនិត្យ កែសម្រួលក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពជាតិ
- ខែ មិថុនា ឆ្នាំ២០១២ : រៀបចំឯកសារបណ្តុះបណ្តាល
- ខែ កក្កដា ឆ្នាំ ២០១២ : បណ្តុះបណ្តាលតំណាងក្រសួង ស្ថាប័ន និងបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែ សីហា ឆ្នាំ២០១២ : បណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលដល់តំណាងក្រសួង ស្ថាប័ន : ៣០០ ដុល្លារ
- បណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ : ៦,៥០០ ដុល្លារ

**សរុប : ៩,៥០០ ដុល្លារ**

## ១.៣. វគ្គតម្រង់ទិសសម្រាប់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប

(កូដសកម្មភាព ៖ 1.1.2.1.2, 1.1.2.1.3)

ក). **ប្រវត្តិ**

ផ្អែកតាមប្រកាសរបស់ គ.ជ.អ.ប លេខ ១៦៥ ប្រ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៦៨៥ ប្រ.ក ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១២ ស្តីពីការតែងតាំងមន្ត្រីរាជការ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងមានរចនាសម្ព័ន្ធ ព្រមទាំងមន្ត្រីមកបំពេញការងារបានគ្រប់គ្រាន់តាមតួនាទី និងមុខតំណែងដែលបានកំណត់។

ដើម្បីធានាឱ្យមន្ត្រីដែលទើបនឹងចូលកាន់មុខតំណែងមានសមត្ថភាពគ្រប់គ្រាន់ ការបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាព គឺជាកិច្ចការសំខាន់ និងបន្ទាន់បំផុត ពិសេសលើប្រធានបទពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កម្មវិធីជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២នេះផងដែរ។

ដោយមើលឃើញពីភាពចាំបាច់នេះ លេខាធិការដ្ឋានបានដាក់បញ្ចូលការបណ្តុះបណ្តាលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កម្មវិធីជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២ សម្រាប់មន្ត្រីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- កម្មវិធីជាតិ
- ផែនការអនុវត្តរយៈពេលបីឆ្នាំ
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២
- លក្ខខណ្ឌការងាររបស់មន្ត្រី និងទីប្រឹក្សានីមួយៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប

ការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិកាដ្ឋាន គ.ជ.អ.ប នឹងសម្របសម្រួលជាមួយក្រុមអភិវឌ្ឍន៍សមត្ថភាពរបស់អនុកម្មវិធីទី២ ដើម្បីរៀបចំឯកសារ និងវិធីសាស្ត្របណ្តុះបណ្តាល ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលដោយផ្ទាល់ដល់មន្ត្រីទាំងអស់ និងមន្ត្រីកិច្ចសន្យា (តាមការចាំបាច់)របស់លេខាធិការដ្ឋាន គ.ជ.អ.ប ។ ការបណ្តុះបណ្តាលនេះ ត្រូវរៀបចំឡើងនៅលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានរយៈពេល០៣ថ្ងៃ ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ មេសា ឆ្នាំ២០១២ : ពិនិត្យ និងកែសម្រួលឯកសារបណ្តុះបណ្តាល
- ខែ ឧសភា ឆ្នាំ២០១២ : អនុវត្តការបណ្តុះបណ្តាល

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាល : ១,២០០ ដុល្លារ

**សរុប : ១,២០០ ដុល្លារ**

## ១.៤. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងតួនាទីរបស់ទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប (កូដ 1.1.2.1.5, 1.2.1.1.5)

### ក). ប្រវត្តិ

រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានកែសម្រួល និងរៀបចំឡើងវិញតាមរយៈប្រកាសរបស់ គ.ជ.អ.ប លេខ ១៦៥ ប្រ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ ជាមួយគ្នានេះ ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាចាំបាច់នានាក៏ត្រូវបានជ្រើសរើស និងដាក់ពង្រាយតាមមុខតំណែងទាំងអស់ផងដែរ។ ទោះបីជាការជ្រើសរើសទីប្រឹក្សាត្រូវបានអនុវត្តឡើងដោយមានការប្រកួតប្រជែងស្របតាមនីតិវិធីដែលបានកំណត់ក៏ដោយ ក៏សមត្ថភាពរបស់ទីប្រឹក្សាមួយចំនួននៅមានកម្រិតពិសេសពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងរបៀបផ្ទេរចំណេះដឹងទៅឱ្យមន្ត្រីរដ្ឋាភិបាល។

ហេតុដូច្នេះ ដើម្បីធានាឱ្យទីប្រឹក្សានីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវា ស្របតាមតួនាទី និងលក្ខខ័ណ្ឌការងាររបស់ខ្លួន លេខាធិការដ្ឋាន គ.ជ.អ.ប សម្រេចដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យសម្រាប់ទីប្រឹក្សារបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
  - ទស្សនទាននៃការធ្វើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
  - បទពិសោធន៍នៃប្រទេសនានាអំពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
  - ក្របខ័ណ្ឌច្បាប់អំពីការធ្វើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
  - ការអនុវត្តគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅកម្ពុជាបច្ចុប្បន្ន
  - របៀបជំរុញការអនុវត្តគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅកម្ពុជា
- តួនាទីរបស់ទីប្រឹក្សា
  - ល័ក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សា
  - ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាល
  - ការផ្ទេរចំណេះដឹងរបស់ទីប្រឹក្សាឱ្យទៅមន្ត្រីរដ្ឋាភិបាល

ការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្ស រដ្ឋបាលថ្នាក់ក្រោមជាតិនឹងសហការជាមួយកម្មវិធី SPACE ដើម្បីរៀបចំឯកសារសម្រាប់ការបណ្តុះបណ្តាលនេះ។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួចហើយ ក្រុមការងារ នឹងដាក់សេចក្តីព្រាងនេះ ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងសម្រេច។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងារនឹងផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ដល់ទីប្រឹក្សាទាំងអស់របស់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានចំនួន ១៧១រូប និងមន្ត្រីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ ដោយសារមានចំនួនមន្ត្រី និងទីប្រឹក្សាច្រើន ការបណ្តុះបណ្តាលនឹងរៀបចំជា០៥ក្រុម ឬថ្នាក់ដូចខាងក្រោម ៖

- **ក្រុមទី១ :** សម្រាប់ទីប្រឹក្សាថ្នាក់ជាតិរបស់លេខាធិការដ្ឋាន គ.ជ.អ.ប (២៣រូប) និងទីប្រឹក្សារបស់អនុកម្មវិធីនានា (១១រូប) សរុប ៣៤ រូប។
- **ក្រុមទី២ :** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់រាជធានី ខេត្ត (២៤រូប) និងទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី ខេត្ត (២៤រូប) សរុប ៤៨រូប។
- **ក្រុមទី៣ :** ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ៤៣រូប។
- **ក្រុមទី៤ :** ទីប្រឹក្សាតាមដានត្រួតពិនិត្យ និងវាយតម្លៃថ្នាក់រាជធានី ខេត្ត (២៤រូប) និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់រាជធានី ខេត្ត (២៤រូប) សរុប៤៨ រូប។
- **ក្រុមទី៥ :** មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ត្រីសំខាន់ៗមកពីអនុកម្មវិធីនានា

### ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែ មីនា-មេសា ឆ្នាំ២០១២ : រៀបចំឯកសារបណ្តុះបណ្តាល
- ខែ ឧសភា-កក្កដា ឆ្នាំ២០១២ : បណ្តុះបណ្តាល

### ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- បណ្តុះបណ្តាល : ៧៥,០០០ដុល្លារ

**សរុប : ៧៥,០០០ដុល្លារ**

## ១.៥. ចក្ខុគម្រង់ទិសសម្រាប់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (កូដសកម្មភាព 1.5.2.1.5)

### ក). ប្រវត្តិ

ក្រៅពីអនុវត្តអនុកម្មវិធីទី១ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ត្រូវទទួលបន្ទុកក្នុងការអនុវត្តអនុកម្មវិធី១ខ ដោយត្រូវធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពជាតំណាង មានគណនេយ្យភាព និងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានប្រព័ន្ធគាំទ្រ និងការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងការអនុវត្តអនុកម្មវិធីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងទទួលខុសត្រូវក្នុងការជ្រើសរើសមន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្តចំនួន២៤រូប និងមន្ត្រីសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន៥៥រូប។ ទោះបីជាដំណើរការជ្រើសរើសត្រូវធ្វើឡើងដោយការប្រកួតប្រជែង ដើម្បីធានាថា មន្ត្រីសម្របសម្រួលដែលបានជ្រើសមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគាំទ្រការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ត្រូវមានការតម្រង់ទិសដល់មន្ត្រីសម្របសម្រួលទាំងនេះបន្ថែមទៀតដែរ។

ដោយមើលឃើញពីភាពចាំបាច់នេះ លេខាធិការដ្ឋានបានដាក់បញ្ចូលការបណ្តុះបណ្តាលតម្រង់ទិសដល់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប ផងដែរ។

## ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា
- ការរៀបចំវេទិកាពិគ្រោះយោបល់របស់ក្រុមប្រឹក្សា និង
- បច្ចេកទេសក្នុងការប្រឹក្សាយោបល់

ការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិកាដ្ឋាន គ.ជ.អ.ប នឹងសម្របសម្រួលជាមួយក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ និងកម្មវិធី SPACE ដើម្បីរៀបចំឯកសារ និងវិធីសាស្ត្របណ្តុះបណ្តាល។

## គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលដោយផ្ទាល់ដល់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ (សរុប៧៩រូប) ដោយបែងចែកជាពីរថ្នាក់ ឬពីរតំបន់ ដែលមួយថ្នាក់ ឬមួយតំបន់មានសិក្ខាកាមប្រមាណ ៣៨រូប។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៥ថ្ងៃ។

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែ មីនា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែ មេសា ឆ្នាំ២០១២ : ការអនុវត្តការបណ្តុះបណ្តាល

## ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- បណ្តុះបណ្តាល : ២៤,៦២០ ដុល្លារ

**សរុប : ២៤,៦២០ដុល្លារ**

## ១.៦. សិក្ខាសាលាស្តីពីយុទ្ធសាស្ត្រផ្តល់សេវាប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សា

(កូដសកម្មភាព ៖ 1.5.2.3.2)

### ក). ប្រវត្តិ

ក្រៅពីអនុវត្តអនុកម្មវិធីទី១ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ត្រូវទទួលបន្ទុកក្នុងការអនុវត្តអនុកម្មវិធី១២ ដោយត្រូវធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពជាតំណាង មានគណនេយ្យភាព និងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានប្រព័ន្ធគាំទ្រ និងការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ក្នុងការអនុវត្តអនុកម្មវិធីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងទទួលខុសត្រូវក្នុងការជ្រើសរើសមន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្តចំនួន២៤រូប និងសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន៩៥រូប ។ ទោះបីជាដំណើរការជ្រើសរើសត្រូវធ្វើឡើងដោយការប្រកួតប្រជែង ដើម្បីធានាថា មន្ត្រី ដែលបានជ្រើសមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគាំទ្រការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ត្រូវមានការតម្រង់ទិសដល់មន្ត្រីប្រឹក្សាយោបល់ទាំងនេះបន្ថែមទៀតដែរ ។ បន្ទាប់ពីប្រតិបត្តិការផ្តល់សេវាសម្របសម្រួលដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងអំពីបទពិសោធន៍ពីព្រោះការផ្តល់សេវាសម្របសម្រួលដល់ក្រុមប្រឹក្សា គឺជាកិច្ចការថ្មី និងចាំបាច់ត្រូវមានការពិនិត្យ និងកែតម្រូវជាបន្តបន្ទាប់ ។

ដោយមើលឃើញពីភាពចាំបាច់នេះ លេខាធិការដ្ឋានបានដាក់បញ្ចូលការរៀបចំសិក្ខាសាលាស្តីពីយុទ្ធសាស្ត្រផ្តល់សេវាប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប ។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- វិធីសាស្ត្រផ្តល់សេវាប្រឹក្សាយោបល់
- ឧបករណ៍ផ្តល់ប្រឹក្សា
- ឯកសារបច្ចេកទេស
- យុទ្ធសាស្ត្រ
- មេរៀន និងបទពិសោធន៍

ការិយាល័យអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសម្របសម្រួលជាមួយក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ និងកម្មវិធី SPACE ដើម្បីរៀបចំសិក្ខាសាលានេះ ។

គ). **យុទ្ធសាស្ត្រ**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារនឹងណែនាំទៅរដ្ឋបាលរាជធានី ខេត្តដើម្បីរៀបចំសិក្ខាសាលានេះ។ ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្តនឹងជួយសម្របសម្រួលសិក្ខាសាលានេះនៅតាមរាជធានី ខេត្តរបស់ខ្លួនចំនួនពីរលើក ដែលមួយលើកៗមានការចូលរួមពីប្រធាន ឬតំណាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួន។ សិក្ខាសាលានីមួយៗមានរយៈពេល០២ថ្ងៃ។

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ កក្កដា ឆ្នាំ២០១២ : សិក្ខាសាលាលើកទី១
- ខែ តុលា ឆ្នាំ២០១២ : សិក្ខាសាលាលើកទី២

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- សិក្ខាសាលា : ១៧,២២៤ ដុល្លារ

**សរុប : ១៧,២២៤ ដុល្លារ**

## ១.៧. សិក្ខាសាលាស្តីពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

(កូដសកម្មភាព : 1.5.2.3.3)

ក). **ប្រវត្តិ**

ក្រៅពីអនុវត្តអនុកម្មវិធីទី១ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ត្រូវទទួលបន្ទុកក្នុងការអនុវត្តអនុកម្មវិធី១ខ ដោយត្រូវធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពជាតំណាង មានគណនេយ្យភាព និងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានប្រព័ន្ធគាំទ្រ និងការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងការអនុវត្តអនុកម្មវិធីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងទទួលខុសត្រូវក្នុងការជ្រើសរើសមន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្តចំនួន២៤រូប និងសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន៥៥រូប។ ក្រៅពីផ្តល់សេវាសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មន្ត្រីសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានភារកិច្ចអភិវឌ្ឍន៍សមត្ថភាពជូនក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។ ហេតុនេះ គ.ជ.អ.ប សម្រេចដាក់បញ្ចូលការរៀបចំសិក្ខាសាលាស្តីពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០១២ របស់ គ.ជ.អ.ប។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិការពិគ្រោះយោបល់
- របៀបជំរុញការចូលរួម
- ។ល។

**គ). យុទ្ធសាស្ត្រ**

ដោយមានការគាំទ្រមន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត មន្ត្រីសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនឹងសម្របសម្រួលសិក្ខាសាលានេះនៅថ្នាក់ក្រុង ស្រុក ខណ្ឌនីមួយៗ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នឹងត្រូវបានអញ្ជើញឱ្យចូលរួមសិក្ខាសាលានៅថ្នាក់ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ សិក្ខាសាលានេះនឹងរៀបចំឡើងចំនួនពីរលើក ដែលមួយលើកៗមានរយៈពេល០១ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ សីហា ឆ្នាំ២០១២ : សិក្ខាសាលាលើកទី១
- ខែ វិច្ឆិកា ឆ្នាំ២០១២ : សិក្ខាសាលាលើកទី២

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- សិក្ខាសាលា : ១៩,៤០០ ដុល្លារ

**សរុប : ១៩,៤០០ ដុល្លារ**

## ១.៨. សិក្ខាសាលាជាតផ្លាស់ប្តូរបទពិសោធន៍ស្តីអំពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល

ក). ប្រវត្តិ

កំណែទម្រង់ការអភិវឌ្ឍតាមបែបវិមជ្ឈការនៅថ្នាក់ក្រោមជាតិ គឺមានលក្ខណៈស៊ីជម្រៅ និងជាការប្តេជ្ញាចិត្តរយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបង្កើតឱ្យមាននូវក្រុមប្រឹក្សាជាអង្គអភិបាលកិច្ចមួយដែលប្រមូលផ្តុំនូវទស្សនៈ គំនិត និងចំណេះដឹងផ្នែកអភិវឌ្ឍន៍ និងនយោបាយផ្សេងៗគ្នា។ តាមរយៈកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធ ការគ្រប់គ្រង តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ក្រោមជាតិ។ ដោយសារ

កំណែទម្រង់នេះទើបចាប់ផ្តើម ហេតុនេះទាមទារនូវការអភិវឌ្ឍសមត្ថភាពតាមរយៈការអនុវត្តបណ្តើររៀនសូត្របណ្តើរ ទាំងក្រុមប្រឹក្សា និងគណៈអភិបាល។

តាមរយៈផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) ដែលនឹងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពជាពិសេសនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១២ លេខាធិការដ្ឋានគ.ជ.អ.ប នឹងរៀបចំសិក្ខាសាលា ឬវេទិកាថ្នាក់ជាតិដើម្បីផ្លាស់ប្តូរបទពិសោធន៍ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិពីប្រទេសផ្សេងៗ ផ្តោតលើប្រធានបទស្តីពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ក្រុង ស្រុក ខណ្ឌ។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសហការជាមួយកម្មវិធី SPACE ដើម្បីអញ្ជើញសមាជិកក្រុមប្រឹក្សាក្រុងណាមួយនៃសហព័ន្ធអាល្លឺម៉ង់ ចូលរួមបង្ហាញនូវបទពិសោធន៍នៃការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន។

**ខ). ខ្លឹមសារនៃសិក្ខាសាលា**

សិក្ខាសាលានេះ ផ្តោតលើប្រធានបទសំខាន់ៗដូចខាងក្រោម៖

- ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងអន្តររដ្ឋបាល
- ដំណើរការនៃការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យតាមដាន និងការគ្រប់គ្រងលើរដ្ឋបាលថ្នាក់ក្រោមជាតិ

**គ). យុទ្ធសាស្ត្រ**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋានគ.ជ.អ.ប និងសហការជាមួយកម្មវិធី SPACE រៀបចំសិក្ខាសាលានេះរយៈពេល០១ថ្ងៃ ដោយមានអ្នកចូលរួមជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សរុបចំនួន១១០រូប ដែលក្នុងនោះ ៧២រូបជាសមាជិកក្រុមប្រឹក្សារាជធានីខេត្ត (៣រូបពីរាជធានី និងខេត្តនីមួយៗ ក្នុងនោះក្រុមប្រឹក្សាជាស្ត្រី១រូប និងសមាជិកមកពីគណបក្សជំទាស់១រូប) និង៤៨រូបជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ សមាជិកក្រុមប្រឹក្សាដែលចូលរួម នឹងចែករំលែកបន្តនូវចំណេះដឹងដែលបានទទួលពីសិក្ខាសាលានេះដល់សមាជិកក្រុមប្រឹក្សាដទៃទៀតរបស់ខ្លួន។

**ឃ). ពេលវេលាសម្រាប់រៀបចំសិក្ខាសាលា**

- ខែ មីនា ឆ្នាំ ២០១២

**ង). ថវិកាគ្រោងសម្រាប់សិក្ខាសាលា**

- ចំណាយសម្រាប់សិក្ខាសាលា : ៩,២៨០ដុល្លារ

**<u>សរុប : ៩,២៨០ដុល្លារ</u>**

## ១.៩. ការតាមដាន និងវាយតម្លៃសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

(កូដសកម្មភាព 1.4.2.1.5)

### ក). ប្រវត្តិ

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ច សម្របសម្រួលការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទាំងថ្នាក់ជាតិដែលរួមមានអនុកម្មវិធីទាំង៦ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយពិនិត្យឃើញថា សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសមត្ថភាពផ្នែកតាមដាន និងវាយតម្លៃនៅមានកម្រិតនៅឡើយទាំងផ្នែកចំណេះដឹង និងការយល់ដឹងពីប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ផអព និងដើម្បីបំប៉នសមត្ថភាព និងពង្រឹងប្រសិទ្ធភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តកម្មវិធីជាតិ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានមានផែនការផ្តល់ការបណ្តុះបណ្តាលថ្នាក់ជាតិមួយសម្រាប់ទូទាំង២៤រាជធានី ខេត្ត ដែលការបណ្តុះបណ្តាលនេះ គឺស្ថិតនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០១២ របស់ គ.ជ.អ.ប។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទស្សនទាននៃការតាមដាន និងវាយតម្លៃ
- ការណែនាំបង្ហាញពីទម្រង់របាយការណ៍កែសម្រួលថ្មីប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់ផអព
- ការណែនាំពីទម្រង់តាមដានសម្រាប់ថ្នាក់ក្រោមជាតិ

ក្រុមការងាររៀបចំការបណ្តុះបណ្តាលនេះ គឺបង្កើតឡើងដោយទីប្រឹក្សា និងមន្ត្រីនៅក្នុងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ក្រុមការងារនឹងពិភាក្សាជាមួយអ្នកពាក់ព័ន្ធថ្នាក់រាជធានី ខេត្ត ដើម្បីសិក្សាពីឧបសគ្គ បញ្ហាប្រឈមនានាទៅលើការតាមដាន និងការរៀបចំរបាយការណ៍ផអព និងរៀបចំចងក្រងឯកសារសម្រាប់ការបណ្តុះបណ្តាលនេះ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលនេះនឹងត្រូវធ្វើតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់រាជធានី ខេត្ត :** ការបណ្តុះបណ្តាលគ្រូបង្គោល ថ្នាក់រាជធានី ខេត្ត សម្រាប់ទូទាំង២៤រាជធានី ខេត្ត នឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៧២រូប (០៣រូប/រាជធានី ខេត្ត ក្នុងនោះគឺមានទីប្រឹក្សាតាមដាន ត្រួតពិនិត្យខេត្ត០១រូប នាយកទីចាត់ការផែនការ និងវិនិយោគ០១រូប និងមន្ត្រីទទួលបន្ទុកផ្នែកត្រួតពិនិត្យនិងវាយតម្លៃក្នុងទីចាត់ការផែនការ និងវិនិយោគ០១រូប)។ ការបណ្តុះបណ្តាលនឹងគ្រោងធ្វើនៅសណ្ឋាគារក្នុងរាជធានីភ្នំពេញសម្រាប់រយៈពេល០៣ថ្ងៃ។

- **ការបណ្តុះបណ្តាលបន្តដល់ថ្នាក់រាជធានី ខេត្ត** : បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅថ្នាក់រាជធានី ខេត្ត ដល់មន្ត្រី និងអ្នកពាក់ព័ន្ធការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃថ្នាក់រាជធានី ខេត្ត។
- **ការបណ្តុះបណ្តាលបន្តដល់ថ្នាក់ស្រុក** : បន្ទាប់ពីចូលរួមការបណ្តុះបណ្តាល គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តដល់ថ្នាក់ស្រុកដល់ទីប្រឹក្សាកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ត្រីក្នុងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ដើម្បីឱ្យទីប្រឹក្សា និងមន្ត្រីទាំងនោះយល់ដឹងពីដំណើរការការងារត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមីនា-ឧសភា ឆ្នាំ២០១២ : សិក្សា ពិភាក្សា និងរៀបចំឯកសារ
- ខែមិថុនា ឆ្នាំ២០១២ : រៀបចំការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ
- ខែកក្កដា ឆ្នាំ ២០១២ : ការបណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ៩,៩៥០ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ : ២៣,០០០ ដុល្លារ

**សរុប : ៣២,៩៥០ ដុល្លារ**

## ១.១០. ការតាមដាន និងវាយតម្លៃសម្រាប់ក្រសួង ស្ថាប័នដៃគូនៅថ្នាក់ជាតិ

(កូដ 1.4.2.1.8 )

ក). ប្រវត្តិ

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ច សម្របសម្រួលលើការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទាំងថ្នាក់ជាតិរួមមានអនុកម្មវិធីទាំង៦ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយពិនិត្យឃើញថា សមត្ថភាពរបស់ដៃគូ រួមមានអនុកម្មវិធី និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាអំពីការយល់ដឹងលើប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ផអពនៅមានកម្រិត និងដើម្បីបំប៉ន់សមត្ថភាព និងពង្រឹងប្រសិទ្ធភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីជាតិនៅតាមអនុកម្មវិធី ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អង្គភាពនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានមានផែនការផ្តល់ការ

បណ្តុះបណ្តាលថ្នាក់ជាតិមួយសម្រាប់អនុកម្មវិធី ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដែលការបណ្តុះបណ្តាលនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ២០១២ របស់ គ.ជ.អ.ប ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើវិធានស្តង់ដារនៃប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ ប្រធានបទនៃការបណ្តុះបណ្តាលមានដូចខាងក្រោម ៖

- ក្របខ័ណ្ឌលទ្ធផលរបស់ផអព
- ទស្សនទាននៃការតាមដាន និងវាយតម្លៃ
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ផអព
- ឧបករណ៍ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ

ក្រុមការងាររៀបចំ និងផ្តល់ការបណ្តុះបណ្តាលនេះ គឺបង្កើតឡើងដោយទីប្រឹក្សា និងមន្ត្រីនៅក្នុងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ក្រុមការងារនឹងពិភាក្សាជាមួយអ្នកពាក់ព័ន្ធតាមអនុកម្មវិធី ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីសិក្សានូវឧបសគ្គ និងបញ្ហាប្រឈមទៅលើការតាមដាន និងវាយតម្លៃ និងរៀបចំចងក្រងឯកសារសម្រាប់ការបណ្តុះបណ្តាលនេះ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលនេះនឹងធ្វើតាមយុទ្ធសាស្ត្រដូចខាងក្រោម៖

- **ការបណ្តុះបណ្តាលដល់អ្នកគោលដៅ ៖** ការបណ្តុះបណ្តាលដល់អ្នកគោលដៅ (០៣រូបពីអនុកម្មវិធីនីមួយៗ និង០២រូបពីក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត) នឹងត្រូវរៀបចំឡើងដោយមានសិក្ខាកាមចូលរួមចំនួន៤០រូប។ ការបណ្តុះបណ្តាលនឹងគ្រោងធ្វើនៅខេត្តព្រះសីហនុ សម្រាប់រយៈពេល០៥ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមិថុនា ឆ្នាំ២០១២ : សិក្សា និងរៀបចំឯកសារ
- ខែកក្កដាឆ្នាំ២០១២ : រៀបចំការបណ្តុះបណ្តាល

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាល : ៩,៨០០ ដុល្លារ

**សរុប : ៩,៨០០ ដុល្លារ**

## ១.១១. ប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា (កូដសកម្មភាព 1.4.2.2.4)

### ក). ប្រវត្តិ

ដើម្បីជួយបង្កើនសមត្ថភាពដល់មន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួនកាន់តែមានប្រសិទ្ធភាព គ.ជ.អ.ប សម្រេចដាក់បញ្ចូលវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យាទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពរបស់ គ.ជ.អ.ប សម្រាប់ឆ្នាំ២០១២ នេះ ។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យនិងព័ត៌មានវិទ្យា ទៅដល់មន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្តមានមាតិកាសំខាន់ៗដូចខាងក្រោម ៖

- របៀបប្រើប្រាស់ប្រពន្ធ័ទិន្នន័យ និងរបាយការណ៍
- គ្រប់គ្រង និងថែទាំបណ្តាញកុំព្យូទ័រ
- ចំណេះដឹងថ្មីៗស្តីពីប្រព័ន្ធសុវត្ថិភាពកុំព្យូទ័រ
- នីតិវិធីក្នុងការប្រមូល និងរាយការណ៍បន្ត (ស្តីពីផលលំបាកក្នុងការប្រើប្រាស់ប្រព័ន្ធទិន្នន័យក៏ដូចជាតម្រូវការថ្មីៗ)

ការិយាល័យព័ត៌មានវិទ្យានៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិភាក្សា រៀបចំមេរៀនដោយបញ្ចូលនូវការអនុវត្តផ្ទាល់សម្រាប់សិក្ខាកាមព្រមទាំងមានការចែករំលែកបទពិសោធន៍រវាងខេត្ត និងខេត្ត។ ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងនៅខេត្តដោយជ្រើសរើសយកមន្ត្រីព័ត៌មានវិទ្យារាជធានី ខេត្ត១រូបមកពីរាជធានី ខេត្តទាំងអស់ ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

អង្គភាពតាមដាន វាយតម្លៃ និងព័ត៌មានវិទ្យាសហការណ៍ជាមួយទីប្រឹក្សាព័ត៌មានវិទ្យាថ្នាក់ជាតិក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនេះ ។

យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលត្រូវបានធ្វើឡើងជាពីរលើកដូចខាងក្រោម ៖

- លើកទី១ ៖ ជាការបណ្តុះបណ្តាលផ្ទាល់នៅថ្នាក់ជាតិ ដែលត្រូវធ្វើឡើងសម្រាប់សិក្ខាកាមជាមន្ត្រីព័ត៌មានវិទ្យាចំនួន២៤រូប មកពីគ្រប់រាជធានី ខេត្តទាំងអស់ ។
- លើកទី២ ៖ ជាការបណ្តុះបណ្តាលបន្ថែមដោយផ្ទាល់នៅថ្នាក់ជាតិ ដែលត្រូវធ្វើឡើងសម្រាប់សិក្ខាកាមជាមន្ត្រីព័ត៌មានវិទ្យាចំនួន២៤រូប មកពីគ្រប់រាជធានី ខេត្តទាំងអស់ផងដែរ ។

ចំនួនថ្ងៃនៃការបណ្តុះបណ្តាលនីមួយៗ មានចំនួន០៣ថ្ងៃ ។

### ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមិថុនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលលើកទី១
- ខែតុលា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលលើកទី២

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

ថវិកាសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល រួមមាន ការចំណាយសម្រាប់ការបោះពុម្ពឯកសារ ប្រាក់ឧបត្ថម្ភ ការធ្វើដំណើរ ដោយរួមបញ្ចូលទាំងការចំណាយសម្រាប់សិក្ខាកាមមកពីគ្រប់រាជធានី ខេត្តទាំងអស់។

- ការបណ្តុះបណ្តាលថ្នាក់រាជធានីខេត្ត : ១០,៩៣៦ ដុល្លារ

<u>**សរុប : ១០,៩៣៦ ដុល្លារ**</u>

## ១.១២. វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអព

(កូដសកម្មភាព 1.3.1.6.3)

ក). ប្រវត្តិ

ប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិកនៃផអព ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីគ្រប់គ្រងនូវព័ត៌មាននានាពាក់ព័ន្ធនឹងបុគ្គលិកដែលកំពុងបំពេញការងារក្រោមក្របខ័ណ្ឌផអពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រមាណជិត២០០០នាក់ ដែលបែងចែកជាបីប្រភេទដូចជា ៖ ទីប្រឹក្សា មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីទទួលបានចំណាយប្រតិបត្តិការអាទិភាព។ ពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីណែនាំដល់គ្រប់ក្រសួង ស្ថាប័ន និងអ្នកអនុវត្តគម្រោងនានាបានស្គាល់នូវប្រព័ន្ធទិន្នន័យនេះ លេខាធិការដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យនេះ ចំនួនពីរវគ្គរួចមកហើយ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ នៅខេត្តព្រះសីហនុ និងលើកទី២ នៅថ្ងៃទី១២-១៥ ខែកក្កដា ឆ្នាំ២០១១នៅខេត្តសៀមរាប។ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអពនេះបានចំនួនមួយវគ្គរួចមកហើយដែរ នៅថ្ងៃទី២៦-២៧ ខែតុលា ឆ្នាំ២០១១ នៅខេត្តបាត់ដំបង។

ប៉ុន្តែ មន្ត្រីដែលបានចូលរួមភាគច្រើន ជាពិសេសមន្ត្រីនៅថ្នាក់ក្រោមជាតិមិនត្រូវបានតែងតាំងជាមន្ត្រីទទួលបន្ទុកប្រព័ន្ធទិន្នន័យនេះឡើយ ហើយមន្ត្រីមួយចំនួនទៀតដែលបានទទួលវគ្គបណ្តុះបណ្តាលរួចមកហើយបានលាឈប់ពីការងារ និងជំនួសមកវិញនូវមន្ត្រីដែលពុំទាន់យល់ដឹងពីប្រព័ន្ធទិន្នន័យនេះច្បាស់លាស់ ដែលជាហេតុនាំឱ្យការគ្រប់គ្រងព័ត៌មានបុគ្គលិកនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ។ ដោយមើលឃើញពីបញ្ហានេះ ក្រុមការងារនៃលេខាធិការដ្ឋាន គ.ជ.អ.ប គ្រោងនឹងរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអពនេះដល់មន្ត្រី ដែលជាជនបង្គោលទទួលបន្ទុកការងារគ្រប់គ្រងបុគ្គលិករបស់រាជធានី ខេត្ត និងអនុកម្មវិធីទាំង០៦ រួមមាន លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់។

## ខ). គោលបំណង និងលទ្ធផលរំពឹងទុក

### ខ.១ គោលបំណង

គោលបំណងនៃវគ្គបណ្តុះបណ្តាលគឺដើម្បី ៖

- ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកគ្រប់គ្រងព័ត៌មានបុគ្គលិករបស់អនុកម្មវិធីនានា និង រាជធានី ខេត្ត ក្នុងការគ្រប់គ្រងទិន្នន័យប្រកបដោយប្រសិទ្ធភាព។
- ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធទិន្នន័យបុគ្គលិក (Personnel Database - PDB)

### ខ.២ លទ្ធផលរំពឹងទុក

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល សិក្ខាកាមទាំងអស់នឹងទទួលបាននូវ៖

- ចំណេះដឹង និងជំនាញក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអព
- មានលទ្ធភាពគ្រប់គ្រងព័ត៌មានបុគ្គលិកស្របតាមគោលការណ៍ណែនាំ
- មានលទ្ធភាពក្នុងការបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធ

## គ). អ្នកសម្របសម្រួល និងសិក្ខាកាមចូលរួម

ទីប្រឹក្សា និងមន្ត្រីដែលពាក់ព័ន្ធមួយចំនួននឹងធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗដូចជា : គោលការណ៍គ្រប់គ្រង បុគ្គលិកក្រោមក្របខ័ណ្ឌផអព បច្ចុប្បន្នភាពនៃការអនុវត្តចំណាយប្រតិបត្តិការអាទិភាព និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យបុគ្គលិក។

សិក្ខាកាម និងអ្នកសម្របសម្រួលដែលត្រូវចូលរួម រួមមានដូចខាងក្រោម ៖

| | |
|---|---|
| ១. មន្ត្រីបច្ចេកទេសគ្រប់គ្រងបុគ្គលិកនៃរាជធានី ខេត្ត | ចំនួន០១រូប |
| ២. ជំនួយការគណនេយ្យ ឬជំនួយការការិយាល័យនៃរាជធានី ខេត្ត | ចំនួន០១រូប |
| ៣. មន្ត្រីបច្ចេកទេសរដ្ឋបាលនៃអនុកម្មវិធី | ចំនួន០១រូប |
| ៤. មន្ត្រីធនធានមនុស្សនៃលេខាធិការដ្ឋាន គ.ជ.អ.ប | ចំនួន០២រូប |
| ៥. មន្ត្រីរដ្ឋបាលនៃលេខាធិការដ្ឋាន គ.ជ.អ.ប | ចំនួន០១រូប |
| ៦. ទីប្រឹក្សាធនធានមនុស្សនៃលេខាធិការដ្ឋាន គ.ជ.អ.ប | ចំនួន០១រូប |
| ៧. មន្ត្រី និងទីប្រឹក្សាព័ត៌មានវិទ្យានៃលេខាធិការដ្ឋាន គ.ជ.អ.ប | ចំនួន០៦រូប |

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ថ្ងៃទី០២-០៦ ខែមេសា ឆ្នាំ២០១២ (ជាផែនការ និងអាចមានការប្រែប្រួល)

## ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល : ៩,២៤០ ដុល្លារ

**<u>សរុប : ៩,២៤០ ដុល្លារ</u>**

## ១.១៣. ប្រព័ន្ធទិន្នន័យតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
(AWPB-DB) (លេខកូដយោងសកម្មភាព **1.3.1.9.2** និង **1.3.1.9.3**)

### ក). ប្រវត្តិ

ប្រព័ន្ធទិន្នន័យតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំបង្កើតឡើងសម្រាប់ផ្តល់លទ្ធភាពដល់អនុកម្មវិធី និងរាជធានី ខេត្តក្នុងការគ្រប់គ្រងការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន និងអាចមានលទ្ធភាពក្នុងការតាមដាន និងវាយតម្លៃដោយប្រើប្រាស់សូចនាករ និងធ្វើការពិនិត្យលើវឌ្ឍនភាពនៃការចំណាយ ។ ប្រព័ន្ធទិន្នន័យនេះត្រូវបានរៀបចំឡើងជាទម្រង់ Web-based Application ដែលផ្តល់ភាពងាយស្រួលក្នុងការធ្វើរបាយការណ៍បូកសរុបទាន់ពេលវេលា ។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យតាមការអនុវត្តដានផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមានមាតិកាសំខាន់ៗ ដូចខាងក្រោម ៖

- គ្រប់គ្រងបញ្ជីលទ្ធផល និងសកម្មភាពដែលមាននៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- រៀបចំផែនការថវិកាប្រចាំឆ្នាំ
- ការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធគណនេយ្យ
- កំណត់គោលដៅ និងវឌ្ឍនភាពសូចនាករ
- ចំណុចគន្លឹះក្នុងការផ្ទៀងផ្ទាត់ និងបញ្ចូលទិន្នន័យឱ្យបានត្រឹមត្រូវ
- បញ្ហាប្រឈមនានា និងដំណោះស្រាយ
- វិធីសាស្ត្រក្នុងការបញ្ចូលទិន្នន័យ
- ស្វែងរក និងទាញយកទិន្នន័យ

ការិយាល័យព័ត៌មានវិទ្យានៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំអភិវឌ្ឍន៍ប្រព័ន្ធ និងពិភាក្សារៀបចំមេរៀនដោយធ្វើបច្ចុប្បន្នភាព និងកែសម្រួលខ្លឹមសារផ្អែកលើប្រព័ន្ធទិន្នន័យ ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ការិយាល័យព័ត៌មានវិទ្យានៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន នឹងរៀបចំការបណ្តុះបណ្តាលនេះតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ដំណាក់កាលទី១ ការបណ្តុះបណ្តាលត្រូវបានធ្វើជាពីរថ្នាក់ផ្សេងគ្នាដូចខាងក្រោម ៖
  - ទី១ : ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ជាតិ ដែលមានសិក្ខាកាមចំនួន៣០រូប ក្នុងនោះរួមមានតំណាង០៣រូបមកពីអនុកម្មវិធីនីមួយៗ និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប

- ទី២ : ការបណ្តុះបណ្តាលសម្រាប់ថ្នាក់រាជធានី ខេត្ត ដែលមានសិក្ខាកាមចំនួន៦០រូប ក្នុងនោះរួមមាន មន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត (១រូប/រាជធានី ខេត្ត) ទីប្រឹក្សាតាមដានត្រួតពិនិត្យថ្នាក់រាជធានី ខេត្ត (១រូប/រាជធានី ខេត្ត)

- ដំណាក់កាលទី២ ការបណ្តុះបណ្តាលត្រូវបានធ្វើជាពីរថ្នាក់ផ្សេងគ្នាដូចខាងក្រោម (ដូចដំណាក់កាលទី១ដែរ) ៖
  - ទី១ : ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ជាតិ ដែលមានសិក្ខាកាមចំនួន៣០រូប ក្នុងនោះរួមមានតំណាង០៣រូបមកពីអនុកម្មវិធីនីមួយៗ និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប
  - ទី២ : ការបណ្តុះបណ្តាលសម្រាប់ថ្នាក់រាជធានី ខេត្ត ដែលមានសិក្ខាកាមចំនួន៦០រូប ក្នុងនោះរួមមាន មន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត (១រូប/រាជធានី ខេត្ត) ទីប្រឹក្សាតាមដានត្រួតពិនិត្យថ្នាក់រាជធានី ខេត្ត (១រូប/រាជធានី ខេត្ត)
- រយៈពេលនៃការបណ្តុះបណ្តាលនីមួយៗ : ០២ថ្ងៃ

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមិថុនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដំណាក់កាលទី១ (សម្រាប់អនុកម្មវិធី និងខេត្ត)
- ខែវិច្ឆិកា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដំណាក់កាលទី២ (សម្រាប់អនុកម្មវិធី និងខេត្ត)

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

ថវិកាសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល ដូចជាការបោះពុម្ពឯកសារ ប្រាក់ឧបត្ថម្ភ ការធ្វើដំណើរការបណ្តុះបណ្តាលថ្នាក់ជាតិនឹងគាំទ្រលើការចំណាយទាំងអស់សម្រាប់ទូទាំងរាជធានី ខេត្ត ។

- ការបណ្តុះបណ្តាលថ្នាក់រាជធានីខេត្ត : ១៥,១២០ ដុល្លារ

**សរុប : ១៥,១២០ ដុល្លារ**

## ១.១៤. ការរៀបចំតារាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំតាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋាន សម្រាប់អនុកម្មវិធី និងរដ្ឋបាលរាជធានី ខេត្ត

(កូដសកម្មភាព 1.31.9.2 និង 1.3.1.9.3)

**ក). ប្រវត្តិ**

ក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការរៀបចំតារាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានដែលមានឈ្មោះថា "ទិន្នន័យមូលដ្ឋាន ជាតិសម្រាប់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (National AWPB Dababase-NAD)" ។ ការរៀបចំទិន្នន័យមូលដ្ឋាននេះ ផ្អែកជាសំខាន់លើលទ្ធផល និងសកម្មភាពនៃផែនការ

អនុវត្តរយៈពេលបីឆ្នាំ (ផអ៣) នៃកម្មវិធីជាតិ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ស្របតាមលទ្ធផល និងសកម្មភាពជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ។ សម្រាប់ឆ្នាំ២០១២ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានផែនការពិនិត្យ និងកែសម្រួលប្រព័ន្ធទិន្នន័យមូលដ្ឋាននេះរួមទាំងដំណើរការនៃការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយសហការជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធនានានៃលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីនៃ ផអ៣ ដើម្បីធានាថា ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ ត្រូវបានរៀបចំប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ដូច្នេះ ការរៀបចំវគ្គបណ្តុះបណ្តាលដល់អនុកម្មវិធី និងរដ្ឋបាលរាជធានី ខេត្ត ក្នុងឆ្នាំ ២០១២ ស្តីពីដំណើរការ និងទិន្នន័យមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ គឺជាការងារអាទិភាព និងមានសារសំខាន់បំផុត។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃកម្មវិធីជាតិ និង ផអ៣
- លទ្ធផល និងសកម្មភាពនៃ ផអ៣
- ដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាន និង
- ការរៀបចំ និងការកែសម្រួលសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប និងស្ថាប័នអនុវត្តនានា។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យ សម្រាប់រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយសហការជិតស្និទ្ធជាមួយអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប។ វគ្គបណ្តុះបណ្តាលនេះនឹងរៀបចំដោយផ្ទាល់ដល់មន្ត្រី និងទីប្រឹក្សាអនុកម្មវិធី និងរដ្ឋបាលរាជធានី ខេត្ត។

សម្រាប់អនុកម្មវិធី វគ្គបណ្តុះបណ្តាលនេះនឹងត្រូវធ្វើឡើងចំនួន០១វគ្គ មានរយៈពេល០២ថ្ងៃ ដែលមានសិក្ខាកាមចូលរួមចំនួនប្រមាណជា២០នាក់ (ជាមធ្យម០៣នាក់ក្នុងអនុកម្មវិធីនីមួយៗ ក្នុងនោះមានមន្ត្រីអនុកម្មវិធីចំនួន០២រូប និងទីប្រឹក្សាពាក់ព័ន្ធចំនួន០១រូប)។

ចំពោះថ្នាក់រាជធានី ខេត្ត វគ្គបណ្តុះបណ្តាលនេះ នឹងត្រូវធ្វើឡើងចំនួន០២វគ្គ ក្នុងមួយវគ្គមានរយៈពេល០២ថ្ងៃ ដែលមានសិក្ខាកាមចូលរួមចំនួន៧២នាក់ (ជាមធ្យម០៣នាក់ក្នុងរាជធានី ខេត្តនីមួយៗ ក្នុងនោះមានមន្ត្រីចំនួន០២រូប និងទីប្រឹក្សាពាក់ព័ន្ធចំនួន០១រូប)។

### ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមិថុនា-កក្កដា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល

- ខែមករា ឆ្នាំ២០១២ : វគ្គរំលឹកដល់មន្ត្រី និងទីប្រឹក្សារាជធានី ខេត្ត (ផ.ស.ថ ២០១២)
- ខែសីហា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រី និងទីប្រឹក្សារាជធានី ខេត្ត (ផ.ស.ថ ២០១៣)
- ខែសីហា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រី និងទីប្រឹក្សាអនុកម្មវិធី (ផ.ស.ថ ២០១៣)

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលមន្ត្រី និងទីបឹក្សាថ្នាក់ជាតិ : ៦០០ ដុល្លារ
- បណ្តុះបណ្តាលមន្ត្រី និងទីប្រឹក្សាថ្នាក់ជធានី ខេត្ត : ១៤,៥២០ ដុល្លារ

**សរុប : ១៥,១២០ ដុល្លារ**

## ១.១៥. ភាពជាអ្នកដឹកនាំ និងបណ្តាញការងារ (កូដសកម្មភាព 1.6.2.1.3 )

ក). **ប្រវត្តិ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៩ គឺជាព្រឹត្តការណ៍ដ៏សំខាន់មួយ ដែលបានរួមចំណែកបង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិនៅតាមរដ្ឋបាលទាំងនោះ ដែលជាផ្នែកមួយដ៏សំខាន់នៃកំណែទម្រង់វិមជ្ឈការ ។ តាមរយៈសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីក្នុងឆ្នាំ២០១១ យើងរកឃើញថាការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំក្រោមជាតិមានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកគិតគូរ និងដោះស្រាយបញ្ហាស្ត្រី កុមារ យុវជន និងការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាព និងថវិកានៅតាមកម្រិតរដ្ឋបាលនីមួយៗ ។

ទោះបីជាដូច្នេះក៏ដោយយោងតាមការប្រមូលព័តិមានស្តីពីតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំជាស្ត្រីថ្នាក់ក្រោមជាតិ បង្ហាញថាពួកគាត់ត្រូវការការពង្រឹងសមត្ថភាពលើចំណេះដឹង និងជំនាញជាក់លាក់មួយចំនួនដើម្បីឱ្យគាត់បំពេញមុខងារបានកាន់តែប្រសើរថែមទៀត ។ ប្រធានបទនៃការពង្រឹងសមត្ថភាពសំខាន់ៗដែលត្រូវបណ្តុះបណ្តាលក្នុងឆ្នាំ២០១២ គឺភាពជាអ្នកដឹកនាំ និងបណ្តាញការងារ ។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

មាតិកានៃការបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- គោលការណ៍សំខាន់ៗនៃភាពជាអ្នកដឹកនាំ (គោលគំនិត និងការបញ្ជ្រាបយេនឌ័រ ការធ្វើផែនការ របាយការណ៍ ជំនាញតស៊ូមតិ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ)
- គោលការណ៍សំខាន់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ជំនាញសម្របសម្រួលវេទិកា និងបណ្តាញការងារ

គ). **យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលនឹងត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាជាមួយវិទ្យាស្ថាន ឬអង្គការមិនមែនរដ្ឋាភិបាល

ដែលមានសមត្ថភាព និងបទពិសោធន៍ក្នុងការបណ្តុះបណ្តាលជាយូរឆ្នាំ ពិសេសមានបទពិសោធន៍ក្នុងការហ្វឹកហ្វឺនទៅដល់ស្ត្រីជាថ្នាក់ដឹកនាំរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ រាល់ឯកសារ និងខ្លឹមសារបណ្តុះបណ្តាលនឹងត្រូវរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកិច្ចការនារី ទីប្រឹក្សា និងអ្នកពាក់ព័ន្ធនានា។

ចំពោះវិធីសាស្ត្រនៃការបណ្តុះបណ្តាលមិនមែនធ្វើឡើងតែម្តងចប់ទេ ប៉ុន្តែនឹងត្រូវធ្វើឡើងជាជំហានៗដោយទុករយៈពេលអោយសិក្ខាកាមយកចំណេះដឹងដែលបានរៀនទៅអនុវត្តនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់គាត់។ បន្ទាប់មកនឹងមាន ការជួបគ្នាសារជាថ្មីរវាងសិក្ខាកាម និងអ្នកសម្របសម្រួលដោយឆ្លុះបញ្ចាំងពីទ្រឹស្តី និងការអនុវត្តជាក់ស្តែង ហើយស្វែងរកចំណុចដែលត្រូវកែលម្អបន្ថែម។

- **សម្រាប់ស្ត្រីជាថ្នាក់ដឹកនាំរាជធានី និងខេត្ត ៖**
  - **ការបណ្តុះបណ្តាល និងវេទិកាជាមួយនឹងស្ត្រីជាថ្នាក់ដឹកនាំរាជធានី ខេត្ត :** ការបណ្តុះបណ្តាលនេះត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៦២រូប (សមាជិកាក្រុមប្រឹក្សារាជធានី ខេត្តចំនួន៣៨រូប និងអភិបាលរងជាស្ត្រីចំនួន២៤រូប)។ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពនេះ នឹងរៀបចំជាពីរតំបន់មានលក្ខណៈជាជំហានៗ និងភ្ជាប់ជាមួយនឹងការតាមដានលទ្ធផលក្រោយវេទិកា និងសិក្ខាសាលានៅនឹងកន្លែងការងារផ្ទាល់របស់សិក្ខាកាម ។
- **សម្រាប់ស្ត្រីជាថ្នាក់ដឹកនាំថ្នាក់ក្រុង ស្រុក ខណ្ឌ៖**
  - **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានីខេត្តនៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៩៦រូប (០៤រូប/រាជធានី ខេត្តក្នុងនោះមកពីមន្ទីរកិច្ចការនារី០២រូប ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ០១រូប ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត ០១រូប)។ ការបណ្តុះបណ្តាលត្រូវបានបែងចែកជា០៣ថ្នាក់ដោយមួយថ្នាក់ៗមានសិក្ខាកាម៣២រូប។
- **ការបណ្តុះបណ្តាល និងវេទិកាជាមួយនឹងស្ត្រីជាថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ :** បន្ទាប់ពីការចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នឹងរៀបចំផែនការលម្អិតក្នុងការចុះទៅសម្របសម្រួលកម្មវិធីក្នុងបណ្តាខេត្ត រាជធានី ដោយផ្តោតលើពេលវេលា ក្រុមអ្នកសម្របសម្រួល និងតម្រូវការគាំទ្របច្ចេកទេសពីថ្នាក់ជាតិ ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមេសា ឆ្នាំ២០១២ : រៀបចំល័ក្ខខ័ណ្ឌការងារ និងជ្រើសរើសវិទ្យាស្ថានបណ្តុះបណ្តាល
- ខែមេសា-ឧសភា ឆ្នាំ២០១២ : រៀបចំខ្លឹមសារមេរៀន និងឯកសារនានា
- ខែមិថុនា ឆ្នាំ២០១២ : បណ្តុះបណ្តាលចាប់ផ្តើមដំណើរការ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ថ្លៃសេវាវិទ្យាស្ថានបណ្តុះបណ្តាល និងការចំណាយផ្សេងៗ : ២០០,០០០ ដុល្លារ

**<u>សរុប : ២០០,០០០ ដុល្លារ</u>**

## ១.១៦. ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអព

(កូដសកម្មភាព 1.6.1.1.4 )

### ក). ប្រវត្តិ

យោងតាម ផអព អនុកម្មវិធីនីមួយៗនឹងទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ ផអព ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តអាចនឹងមិនឆ្លើយតបតាមការរំពឹងទុកឡើយ ដោយសារសមត្ថភាព និងបទពិសោធន៍ពាក់ព័ន្ធការងារយេនឌ័ររបស់ស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗនៅមានកម្រិត។ ដូច្នេះ ដើម្បីធានាថា អនុកម្មវិធីនីមួយៗអាចមានលទ្ធភាពបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពនីមួយៗរបស់ខ្លួន លេខាធិការដ្ឋាន គ.ជ.អ.ប បានដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពី "ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអព" ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

មាតិកានៃការបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទស្សនទានយេនឌ័រ និងការអនុវត្តនៅក្នុង ផអព និង អនុកម្មវិធី
- ឧបករណ៍វិភាគយេនឌ័រ
- របៀបប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រសួងកិច្ចការនារី សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនេះដោយអនុវត្តតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ការបណ្តុះបណ្តាលសម្រាប់ថ្នាក់គ្រប់គ្រងអនុកម្មវិធី : មន្ត្រីជាន់ខ្ពស់របស់ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន នឹងរៀបចំការបណ្តុះបណ្តាលចំនួន០១ព្រឹក ឬ០១រសៀល សម្រាប់ថ្នាក់ដឹកនាំមកពីអនុកម្មវិធីនីមួយៗ។
- ការបណ្តុះបណ្តាលសម្រាប់មន្ត្រីបច្ចេកទេស និងទីប្រឹក្សា : មន្ត្រីក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាននឹងរៀបចំការបណ្តុះបណ្តាដល់មន្ត្រីបច្ចេកទេស និងទីប្រឹក្សាមកពីអនុកម្មវិធីនីមួយៗ។ ការបណ្តុះបណ្តាលនៅតាមអនុកម្មវិធីនីមួយៗមានរយៈពេលបីថ្ងៃ។

### ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមីនា ឆ្នាំ២០១២ : បណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំអនុកម្មវិធី
- ខែមេសា-មិថុនា ឆ្នាំ២០១២ : បណ្តុះបណ្តាលសម្រាប់មន្ត្រីបច្ចេកទេស និងទីប្រឹក្សា

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- រៀបចំឯកសារ : ៩២,០០០ ដុល្លារ
- បណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំអនុកម្មវិធី : ១,៣៨០ ដុល្លារ
- បណ្តុះបណ្តាលសម្រាប់មន្ត្រីបច្ចេកទេស និងទីប្រឹក្សា : ៧,៣០០ ដុល្លារ

<u>សរុប : ១៧,៨៨០ ដុល្លារ</u>

## ១.១៧. ការបញ្ជ្រាបយេនឌ័រ និងតួនាទីជាអនុប្រធានអចិន្ត្រៃយ៍របស់ គ ក ស ក

(កូដសកម្មភាព 1.6.2.1.1 )

ក). ប្រវត្តិ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានបង្កើតឡើងយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទីសំខាន់ ក្នុងការផ្តល់យោបល់ និងលើកជាអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ កុមារ និងជនងាយរងគ្រោះដែលស្ថិតនៅក្នុងដែនអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា។ សមាជិករបស់គណៈកម្មាធិការនេះរួមមាន សមាជិកក្រុមប្រឹក្សាជាស្ត្រីទាំងអស់ អភិបាលរងជាស្ត្រី និងប្រធាន ឬអនុប្រធានមន្ទីរជំនាញសំខាន់ៗដូចជា មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរផែនការ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសុខាភិបាល តំណាងសមាគមក្រុមប្រឹក្សាឃុំសង្កាត់ ស្នងការដ្ឋាននគរបាល និងទីចាត់ការអន្តរវិស័យ។

មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ក្នុងនាមជាអនុប្រធានអចិន្ត្រៃយ៍របស់ គ.ក.ស.ក និងក្នុងនាមជាអង្គភាពសម្របសម្រួលនឹងគាំទ្រលើបណ្តាញយេនឌ័រនានានៅថ្នាក់ក្រោមជាតិដើរតួនាទីសំខាន់០២គឺ ៖ បង្កើនភាពអង់អាចដល់ស្ត្រី និងបញ្ជ្រាបយេនឌ័រ។ ការបង្កើនភាពអង់អាចដល់ស្ត្រីនឹងត្រូវធ្វើឡើងជាមួយសមាជិកក្រុមប្រឹក្សា និងអភិបាលរងជាស្ត្រីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពិសេសក្នុងការបំពេញតួនាទីរបស់ពួកគាត់នៅក្នុង គ.ក.ស.ក។ ដោយឡែកការបញ្ជ្រាបយេនឌ័រ មន្ទីរនិងការិយាល័យកិច្ចការនារី នឹងត្រូវអនុវត្តតាមរយៈសម្របសម្រួលបញ្ចូលបញ្ហាសមភាពយេនឌ័រ ស្ត្រី កុមារ និងយុវវ័យទៅក្នុងផែនការ និងសកម្មភាពរបស់ក្រុមប្រឹក្សាកម្រិតនីមួយៗ។ ដើម្បីបំពេញតួនាទីដ៏សំខាន់ទាំង០២

នេះ មន្ទីរ និងការិយាល័យកិច្ចការនារី ត្រូវការយ៉ាងចាំបាច់នូវការអភិវឌ្ឍសមត្ថភាពលើចំណេះដឹង និងជំនាញសំខាន់មួយចំនួននៅក្នុងឆ្នាំ២០១២នេះ តាមរយៈការបណ្តុះបណ្តាល និងការហ្វឹកហ្វឺននានា។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

មាតិកានៃការបណ្តុះបណ្តាលនេះផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- តួនាទី និងភារកិច្ចរបស់អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការបញ្រ្ជាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិ
- ឧបករណ៍វិភាគ និងបញ្រ្ជាបយេនឌ័រ(Gender Analysis and mainstreaming Tools) និងការរៀបចំរបាយការណ៍
- ការប្រមូល និងវិភាគព័ត៌មាន
- ជំនាញសម្របសម្រួលវេទិកា និងបណ្តាញការងារយេនឌ័រនៅថ្នាក់ក្រោមជាតិ
- គោលការណ៍សំខាន់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

- **សិក្ខាសាលាស្តីពីការបញ្រ្ជាបយេនឌ័រនៅថ្នាក់ក្រោមជាតិ និងការអនុវត្តភារកិច្ចរបស់អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ :** សិក្ខាសាលានេះ រៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៧២រូប (ថ្នាក់ដឹកនាំ និងអ្នកទទួលបន្ទុកយេនឌ័រ មន្ទីរកិច្ចការនារី និងអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត)។ សិក្ខាសាលានឹងរៀបចំដើម្បីពង្រឹងសមត្ថភាពការអនុវត្តផែនការសកម្មភាព និងប្រចាំឆ្នាំរបស់មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការបំពេញភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត។ កម្មវិធីនេះក៏ផ្តោតលើការពង្រឹងសមត្ថភាពដល់មន្ទីរកិច្ចការនារីរាជធានី ខេត្ត ក្នុងការគាំទ្រដល់ការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ លើការងារបញ្រ្ជាបយេនឌ័រ និងភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ក.ស.ក ថ្នាក់ក្រុង ស្រុក ខណ្ឌ។
- **សិក្ខាសាលាពង្រឹងសមត្ថភាពការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ស្តីពីការបញ្រ្ជាបយេនឌ័រនៅថ្នាក់ក្រោមជាតិ និងការអនុវត្តភារកិច្ចរបស់អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ :** សិក្ខាសាលានេះ នឹងរៀបចំដោយមន្ទីរកិច្ចការនារីរាជធានី ខេត្ត ដែលចូលរួមដោយតំណាងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ និងជាអនុប្រធានអចិន្ត្រៃយនៃ គ.ក.ស.ក ថ្នាក់ក្រុង ស្រុក ខណ្ឌ ទូទាំងរាជធានី ខេត្ត។ សិក្ខាសាលានេះ នឹងរៀបចំលក្ខណៈជាបន្តបន្ទាប់ ស្របតាមស្ថានភាពជាក់ស្តែងតាមខេត្តនីមួយៗ ភ្ជាប់ជាមួយនឹងសកម្មភាព

ចុះគាំទ្របច្ចេកទេសដោយផ្ទាល់ពីមន្ទីរកិច្ចការនារី ព្រមទាំងការចុះតាមដាន និងជំរុញការអនុវត្តការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមេសា ឆ្នាំ២០១២ : សិក្ខាសាលាសម្រាប់សមាជិកអចិន្ត្រៃយ៍ គ.ក.ស.ក រាជធានី ខេត្ត
- សិក្ខាសាលាសម្រាប់សមាជិកអចិន្ត្រៃយ៍ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ នឹងត្រូវរៀបចំឡើងរាជធានី ខេត្ត ជាប្រចាំត្រីមាស ឬប្រចាំឆមាស ដោយយោងតាមផែនការ សកម្មភាពរបស់មន្ទីរកិច្ចការនារីរាជធានី ខេត្ត នីមួយៗ។

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- សិក្ខាសាលាទាំងនៅថ្នាក់ជាតិ និងខេត្ត : ១៣,០០០ ដុល្លារ

**<u>សរុប : ១៣,០០០ ដុល្លារ</u>**

## ១.១៨. វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី តេស្តបេតុង ហ៊ានលេខា និង GPS (កូដសកម្មភាព 1.3.1.7.2)

**ក). ប្រវត្តិ**

មូលនិធិឃុំ សង្កាត់ គឺជាយន្តការមួយដែលបានផ្ទេរសារពើពន្ធពីរាជរដ្ឋាភិបាលថ្នាក់ជាតិដើម្បីផ្តល់ហិរញ្ញប្បទាន ចំណាយរដ្ឋបាល និងចំណាយអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់។ មូលនិធិមួយចំណែកត្រូវបានវិភាជន៍សម្រាប់ចំណាយអភិវឌ្ឍន៍ ដើម្បីរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដូចជាផ្លូវលំជនបទ សំណង់ ផ្លូវលំ សាលារៀន មណ្ឌលសុខភាព សំណង់សិល្បការផ្នែកធារាសាស្ត្រ អគារសហគមន៍ និងការផ្គត់ផ្គង់ទឹក។

ដើម្បីឆ្លើយតបក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើត និងអនុវត្តគម្រោង ហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិមានសុខុដុមនីយកម្មនៅក្នុងក្របខ័ណ្ឌ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់កាអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអនុកម្មវិធីទី២នៃក្រសួងមហាផ្ទៃ នឹងសហប្រតិបត្តិការគ្នារៀបចំបើកវគ្គបណ្តុះបណ្តាលគោលនយោបាយប្រើប្រាស់ ឧបករណ៍ **ឌីស៊ីភី តេស្តបេតុង ហ៊ានលេខា** និង **GPS**ក្នុងគោលបំណងផ្តល់ឱកាសឱ្យមន្ត្រីគម្រោងថ្នាក់ក្រោមជាតិដែលជាមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) អភិវឌ្ឍន៍សមត្ថភាព និងទទួលបាននូវចំណេះដឹងក្នុងការប្រើប្រាស់ឧបករណ៍សម្រាប់ជួយគាំទ្រក្នុងការសិក្សាគ្រោងប្លង់ ប៉ាន់ស្មានតម្លៃ និងអនុវត្តការសាងសង់គម្រោងមូលនិធិឃុំ សង្កាត់ស្របតាមបទដ្ឋានបច្ចេកទេស។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ក្រុមការងារ នឹងរៀបចំចងក្រងឯកសារជាបទបង្ហាញតាមប្រធានបទនីមួយៗ ដែលប្រើពាក្យបច្ចេកទេសសាមញ្ញពោរពេញដោយអត្ថន័យសំខាន់ៗ ងាយស្រួលយល់សម្រាប់មន្ត្រី ដែលមានបទពិសោធន៍តិចផ្នែកបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ បទបង្ហាញទាំងនោះ គឺជាគោលការណ៍ត្រួតណែនាំពីការសិក្សាការគ្រោងប្លង់ ប៉ាន់ស្មានតម្លៃ និងតាមដានការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដែលប្រើប្រាស់មូលនិធិឃុំសង្កាត់។ វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ប្រធានបទទី១ : ការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី
- ប្រធានបទទី២ : ការប្រើប្រាស់ឧបករណ៍ តេស្តបេតុង
- ប្រធានបទទី៣ : ការប្រើប្រាស់ឧបករណ៍ ឋានលេខា
- ប្រធានបទទី៤ : ការប្រើប្រាស់ឧបករណ៍ GPS

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិរបស់អនុកម្មវិធីទី២នៃក្រសួងមហាផ្ទៃនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រ ដូចខាងក្រោម ៖

- រៀបចំ និងផ្តល់ឱ្យសិក្ខាកាមដែលចូលរួមនូវឯកសារបណ្តុះបណ្តាលជាភាសាខ្មែរ
- វគ្គបណ្តុះបណ្តាលនេះបែងចែកជាពីរ ៖
  1. **រៀនទ្រឹស្តីនៅក្នុងថ្នាក់ :** ធ្វើបទបង្ហាញតាមប្រធានបទនីមួយៗ សំណួរ-ចម្លើយ ពេលធ្វើបទបង្ហាញចប់ប្រធានបទនីមួយៗ
  2. អនុវត្តជាក់ស្តែងជាមួយឧបករណ៍ ឌីស៊ីភី តេស្តបេតុង ឋានលេខា និង GPS នៅទីតាំងការដ្ឋាន ដែលបានជ្រើសរើសដោយចែកសិក្ខាកាមជាបួនក្រុមតូចៗ រួចអនុវត្តជាក់ស្តែងជាមួយឧបករណ៍ទាំងនោះ បន្ទាប់មកតាមក្រុមនីមួយៗត្រូវធ្វើការគណនា និងធ្វើបទបង្ហាញលទ្ធផលជូនវគ្គបណ្តុះបណ្តាល ដើម្បីចែករំលែកបទពិសោធន៍ពីការអនុវត្តផ្ទាល់នេះ
  3. វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ០៤ថ្ងៃ។
- គ្រូបង្គោលក្នុងការបណ្តុះបណ្តាល គឺអញ្ជើញទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធពីថ្នាក់ខេត្ត ដែលមានបទពិសោធន៍មកជួយបណ្តុះបណ្តាលរួមជាមួយគ្រូបង្គោលនៅថ្នាក់ជាតិ។

### ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល និងទីកន្លែង

- ខែមីនា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែមេសា ឆ្នាំ២០១២ : មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

យោងតាមផែនការសកម្មភាព និងថវិកាឆ្នាំ ២០១២ លេខកូដ១.៣.១.៧.២ រៀបចំវគ្គបណ្តុះ បណ្តាល ស្តីពីគោលនយោបាយ និងបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងថ្នាក់ក្រោមជាតិមានថវិកាសរុប ៖ **១១,២២០ ដុល្លារ។**

## ១.១៩. វគ្គតម្រង់ទិសសម្រាប់សវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប

(កូដ 1.3.1.8.3, 1.3.1.8.4)

ក). ប្រវត្តិ

យោងតាមរចនាសម្ព័ន្ធថ្មីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើង។ ក្រុមសវនករផ្ទៃក្នុងត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់ដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប និងមានតួនាទីភារកិច្ចសំខាន់ៗក្នុងការធ្វើសវនកម្មផ្ទៃក្នុងលើទីភ្នាក់ងារទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលអនុវត្តកម្មវិធី ឬគម្រោងស្ថិតនៅក្រោមក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យមើលលើភាពត្រឹមត្រូវ ភាពពេញលេញនៃបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តតាមនីតិវិធីប្រតិបត្តិការនានាដែលបានកំណត់ជាធរមាន និងបំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។ ដើម្បីឱ្យក្រុមសវនកម្មផ្ទៃក្នុងនេះមានសមត្ថភាពពេញលេញក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន លេខាធិការដ្ឋាន គ.ជ.អ.ប នឹងបញ្ចូលប្រធានបទស្តីពីវគ្គតម្រង់ទិសសម្រាប់សវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំរបស់ គ.ជ.អ.ប។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ផ្នែកនានានៃសវនកម្មផ្ទៃក្នុង
- យុទ្ធសាស្ត្រធ្វើសវនកម្មដោយផ្អែកលើការវិភាគហានិភ័យ និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ
- ក្របខ័ណ្ឌវាយតម្លៃហានិភ័យ និងកម្មវិធីសវនកម្ម
- ការអនុវត្តសវនកម្ម
- ការសរសេររបាយការណ៍

ដោយមានជំនួយពីទីប្រឹក្សាក្នុងស្រុក ក្រុមសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិនិត្យ និងកែសម្រួលសេចក្តីព្រាងសៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ មុនពេលចាប់ផ្តើមពិនិត្យ ក្រុមការងារនឹងទទួលបានការបណ្តុះបណ្តាល ដែលត្រូវសម្របសម្រួលដោយទីប្រឹក្សាបរទេស

ដែលបានរៀបចំសេចក្តីព្រាងឯកសារនេះ។ បន្ទាប់ពីពិនិត្យ និងកែសម្រួល ក្រុមការងារនឹងដាក់សៀវភៅណែនាំនេះជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងារនឹងអនុវត្តការបណ្តុះបណ្តាលដោយផ្ទាល់ដល់ ៖

- **ក្រុមសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប** ដែលមានចំនួនប្រមាណ ១០រូប ។ ការបណ្តុះបណ្តាលនេះមានរយៈពេល០២ថ្ងៃ នៅថ្នាក់ជាតិ។
- **សវនករផ្ទៃក្នុងរាជធានី ខេត្ត :** បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលខាងលើ ក្រុមសវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងសហការជាមួយក្រុមការងាររៀបចំឯកសារដើម្បីផ្តល់ការបណ្តុះបណ្តាលដល់សវនករផ្ទៃក្នុងរាជធានី ខេត្ត ដែលមានចំនួនសរុប ២៤រូប។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ នៅថ្នាក់ជាតិ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែឧសភា ឆ្នាំ២០១២ : បណ្តុះបណ្តាលក្រុមការងារអន្តរក្រសួង
- ខែឧសភា ឆ្នាំ២០១២ : ក្រុមការងារពិនិត្យ កែសម្រួលឯកសារបណ្តុះបណ្តាល
- ខែកក្កដា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ
- ខែកក្កដា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលសវនករផ្ទៃក្នុងថ្នាក់រាជធានី ខេត្ត

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលក្រុមសវនកម្មថ្នាក់ជាតិ : ៣០០ ដុល្លារ
- បណ្តុះបណ្តាលសវនករផ្ទៃក្នុងរាជធានី ខេត្ត : ២,៦៦៨ ដុល្លារ

**<u>សរុប : ២,៩៦៨ ដុល្លារ</u>**

## ១.២០. សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចសម្រាប់ការរៀបចំគម្រោងថ្នាក់ក្រោមជាតិ (កូដសកម្មភាព ៖ 1.3.1.7.2)

**ក). ប្រវត្តិ**

ដើម្បីធានាថា រាល់គម្រោងវិនិយោគដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ទាំងអស់មិនបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់បានតម្រូវឱ្យមានការសិក្សាអំពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។ បន្ទាប់ពីទទួលបានការអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំនេះ ការបណ្តុះបណ្តាលត្រូវបានផ្តល់ជូនគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ពិនិត្យមើលឡើងវិញលើការអនុវត្តគោលនយោបាយសុវត្ថិភាព

បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនាថ្មីៗនេះបង្ហាញឱ្យឃើញថា សមត្ថភាពរបស់រដ្ឋបាលខេត្ត និងអ្នកពាក់ព័ន្ធនានាអំពីការសិក្សាលើសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៅមានកម្រិតនៅឡើយ ហេតុដូច្នេះ លេខាធិការដ្ឋាន គ.ជ.អ.ប សម្រេចដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចសម្រាប់ការអនុវត្តគម្រោងនៅថ្នាក់ក្រោមជាតិ ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ២០១២ របស់ គ.ជ.អ.ប ។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- វដ្តនៃគម្រោងមូលនិធិឃុំ សង្កាត់
- ដំណើរការនៃការសិក្សាសុវត្ថិភាពដីធ្លី
- គោលការណ៍ណែនាំស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន
- គោលការណ៍ណែនាំស្តីពីសុវត្ថិភាពជនជាតិដើមភាគតិច
- ការបំពេញទម្រង់នានា
- បញ្ជីឃ្លាំមើលកិច្ចការពារសុវត្ថិភាពបរិស្ថាន និងជនជាតិដើមភាគតិច

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងពិនិត្យលើសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ព្រមទាំងដកស្រង់មេរៀនបទពិសោធន៍ដែលបានទទួលបានពីការអនុវត្តជាក់ស្តែងក្នុងឆ្នាំកន្លងទៅរួចរៀបចំជាឯកសារបណ្តុះបណ្តាល ។

គ). **យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងារនឹងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** គ្រូបង្គោលរាជធានី ខេត្តចំនួន ៦៩រូប (០៣រូប/ខេត្ត ដែលជាជនបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្ត) នឹងចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិនេះ)។ ការបណ្តុះបណ្តាលមានរយៈពេល០២ថ្ងៃ។
- **ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត :** បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលនៅថ្នាក់ជាតិ គ្រូបង្គោលមកពីខេត្តនីមួយៗនឹងរៀបចំការបណ្តុះបណ្តាលនៅថ្នាក់ខេត្តរបស់ខ្លួន។ សិក្ខាកាមនៅថ្នាក់ខេត្តរួមមាន ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក។ ការបណ្តុះបណ្តាលមាន រយៈពេល០២ថ្ងៃ។

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា ឆ្នាំ២០១២ : ពិនិត្យ កែសម្រួលឯកសារបណ្តុះបណ្តាល

- ខែមេសា ឆ្នាំ២០១២ : បណ្តុះបណ្តាលគ្រូបង្គោលខេត្តនៅថ្នាក់ជាតិ
- ខែឧសភា-មិថុនា ឆ្នាំ២០១២ : បណ្តុះបណ្តាលដល់ក្រុមគោលដៅថ្នាក់ខេត្ត

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាល : ៨០៥៥ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត : ២៦៧៨១ ដុល្លារ

**<u>សរុប : ៣៤៧៣៦ដុល្លារ</u>**

## ១.២១. ប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន

(កូដសកម្មភាព ៖ 1.3.1.2.2)

ក). **ប្រវត្តិ**

ផ្អែកតាមប្រកាសរបស់ គ.ជ.អ.ប លេខ ១៦៥ ប្រ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៦៨៥ ប្រ.ក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ ស្តីពីការតែងតាំងមន្ត្រីរាជការ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងមានរចនាសម្ព័ន្ធ ព្រមទាំងមន្ត្រីមកបំពេញការងារបានគ្រប់គ្រាន់តាមតួនាទី និងមុខតំណែងដែលបានកំណត់។

នីតិវិធី និងរបៀបរបបការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប នឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នៅក្នុងលេខាធិការដ្ឋាន។ ដើម្បីឱ្យមន្ត្រី និងទីប្រឹក្សាទាំងអស់របស់លេខាធិការដ្ឋាន គ.ជ.អ.ប យល់ដឹងអំពីប្រព័ន្ធ នីតិវិធី និងរបៀបរបបការងារទាំងនេះ លេខាធិការដ្ឋានបានដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ការគ្រប់គ្រងផ្ទៃក្នុង
- ការទំនាក់ទំនង
- របៀបរបបការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប

ក្រោមការណែនាំរបស់ថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានសមាសភាពមកពីអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី និងអង្គភាពពាក់ព័ន្ធនានានឹងរៀបចំសេចក្តីព្រាងប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

បន្ទាប់ពីមានការឯកភាពពីថ្នាក់ដឹកនាំ គ.ជ.អ.ប ក្រុមការងារនឹងរៀបចំឯកសារបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី និងទីប្រឹក្សាព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់។ ការបណ្តុះបណ្តាលនេះមានរយៈពេល ០១ថ្ងៃ។

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែឧសភា-កក្កដា ឆ្នាំ២០១២ : រៀបចំឯកសារបណ្តុះបណ្តាល
- ខែកក្កដា ឆ្នាំ២០១២ : អនុវត្តការបណ្តុះបណ្តាល

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- បណ្តុះបណ្តាល : ៧២០ ដុល្លារ

**សរុប : ៧២០ ដុល្លារ**

## ១.២២. ការបណ្តុះបណ្តាលទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ

(កូដសកម្មភាព 1.3.1.5.4)

ក). ប្រវត្តិ

ក្នុងឆ្នាំ២០១១នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើកំណែទម្រង់ដ៏ធំមួយទៅលើរចនាសម្ព័ន្ធអភិបាលកិច្ចនៅទូទាំងប្រទេស ក្នុងគោលបំណងអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ ក្នុងរយៈពេល៣ឆ្នាំដំបូងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌកំពុងត្រូវបានពង្រឹងសមត្ថភាព ក្នុងការអនុវត្តមុខងារដែលមានស្រាប់ ក៏ដូចជាត្រៀមទទួលមុខងារថ្មីនានាដែលនឹងត្រូវផ្ទេរពីថ្នាក់ជាតិជាបន្តបន្ទាប់។ ជាមួយគ្នានេះដែរ ឃុំ សង្កាត់ទទួលបាននូវការគាំទ្រជាបន្តក្នុងដំណើរការកសាងផែនការ និងថវិការបស់ខ្លួន។

ចាប់ពីឆមាសទី២ ឆ្នាំ២០១១មក រចនាសម្ព័ន្ធនៃគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅថ្នាក់រាជធានី ខេត្តក៏ត្រូវបានកែសម្រួលដោយច្របាច់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលឯកភាពនៅថ្នាក់រាជធានី ខេត្ត។

ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ ទីប្រឹក្សានានានៅគ្រប់លំដាប់ត្រូវបានជ្រើសរើស នឹងត្រូវបានចាត់តាំងឱ្យបំពេញការងារយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សានិងរដ្ឋបាលតាមលំដាប់។ ដោយសារលើកនេះការយកចិត្តទុកដាក់ត្រូវបានផ្តោតដល់កម្រិតក្រុង ស្រុក ខណ្ឌ ដើម្បីអភិវឌ្ឍន៍សមត្ថភាព និងកែលម្អការផ្តល់សេវាដូចនេះទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានជ្រើសរើស និងដាក់ពង្រាយតាមក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ ក្រុង ស្រុក ខណ្ឌទាំងអស់ចំនួន១៩៤នាក់ ដែលក្នុងនោះស្ត្រីមានចំនួន ៣០នាក់ ត្រូវបានជ្រើសរើសចប់សព្វគ្រប់នៅក្នុងត្រីមាសទី២។ ទីប្រឹក្សាទាំងនេះភាគច្រើន (៧៧ភាគរយ) ជាអតីតមន្ត្រីនៃគណៈកម្មាធិការប្រតិបត្តិ មួយចំនួនទៀតជាអតីតមន្ត្រីរាជការស៊ីវិល និងមួយចំនួនទៀតជាអតីតបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។ ដោយសារពួកគេចេញមកពីប្រភពផ្សេងគ្នា ប្រវត្តិការងារ បទពិសោធន៍ និងសញ្ញាណលើកម្មវិធីក៏មានកម្រិតផ្សេងគ្នាដែរ។

ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ ក្រុង ស្រុក ខណ្ឌមានភារកិច្ច និងតួនាទីចំពេងក្នុងការកសាងសមត្ថភាពបុគ្គល (ដូចជាការងារហិរញ្ញវត្ថុ លទ្ធកម្ម ផែនការ រដ្ឋបាល របាយការណ៍និងយេនឌ័រជាដើម) និងសមត្ថភាពស្ថាប័ន (ដូចជា ការងារតម្រង់ទិសលើកម្មវិធី ផែនការអន្តរាគមន៍ និងការវាយតម្លៃលទ្ធផល)។ លើសពីនេះទីប្រឹក្សាត្រូវគាំទ្រដល់ការិយាល័យដែលពាក់ព័ន្ធ ជាពិសេសការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់។

តាមរយៈការបំពេញបេសកកម្មតាមខេត្តមួយចំនួនកន្លងមក ទីប្រឹក្សានៃការិយាល័យគាំទ្រសេវាទីប្រឹក្សានៅថ្នាក់ក្រោមជាតិ បានសង្កេតឃើញថា ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការនៅការគាំទ្រជាក់លាក់បន្ថែមទៀត ទាំងផ្នែកបច្ចេកទេស ការងារគ្រប់គ្រង ការកសាងផែនការ ក៏ដូចជារបៀបរបបធ្វើការងារ ដើម្បីអនុញ្ញាតឱ្យពួកគេបំពេញការងារកាន់តែប្រកបដោយគុណភាព ប្រសិទ្ធិភាព និងទំនុកចិត្ត។

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្នុងការបំពេញភារៈកិច្ចរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ ទាំងផ្នែកបច្ចេកទេស និងការគ្រប់គ្រង សំដៅគាំទ្រដល់ក្រុមប្រឹក្សា និងរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

មាតិកាសំខាន់ៗដែលនឹងបញ្ចូលក្នុងវគ្គបណ្តុះបណ្តាលនេះ រួមមាន ៖

- ការពិនិត្យឡើងវិញអំពីតួនាទី និងភារកិច្ចរបស់ទីប្រឹក្សាថ្នាក់ក្រោមជាតិ និងខ្សែគណនេយ្យភាព និងបទពិសោធន៍ដែលទទួលបានពីបេសកកម្មតាមខេត្ត
- ការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សៀវភៅណែនាំអំពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- ការសម្របសម្រួលការងាររដ្ឋបាល និងគ្រប់គ្រង

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលនេះចែកជាពីរដំណាក់កាលដូចខាងក្រោម ៖

ក.១) <u>**ដំណាក់កាលទី១ "ការបណ្តុះបណ្តាល និងធ្វើបង្ហាញ (វគ្គទី១)**</u> នឹងធ្វើនៅខេត្តកំពង់ចាម ដែលមានសិក្ខាកាមមកពីខេត្តកំពង់ចាម (១៧ក្រុង-ស្រុក) ស្វាយរៀង (៨ក្រុង-ស្រុក) និងព្រៃវែង

(១៣ក្រុង- ស្រុក) ៖

- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ៣នាក់
- ទីប្រឹក្សាត្រួតពិនិត្យថ្នាក់ខេត្ត ៣នាក់
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ៣៨នាក់
- ក្រុមសម្របសម្រួលថ្នាក់ជាតិ ៣នាក់

**សរុប** **៤៧នាក់**

ខ.២) **ដំណាក់កាលផ្សព្វផ្សាយបន្ត** : បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលដំណាក់កាលទី១ ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត (០៣រូប) ទីប្រឹក្សាត្រួតពិនិត្យថ្នាក់ខេត្ត (០៣រូប) និងក្រុមសម្របសម្រួលថ្នាក់ជាតិ (០៣រូប) នឹងរៀបចំការបណ្តុះបណ្តាលដល់ទីប្រឹក្សាក្រុង ស្រុក ខណ្ឌនៅតាមមណ្ឌលចំនួន៤ ដូចខាងក្រោម ៖

- **មណ្ឌលបាត់ដំបង** សម្រាប់សិក្ខាកាមជាទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក មកពីខេត្តបាត់ដំបង (១៤នាក់) បន្ទាយមានជ័យ (៩នាក់) ប៉ៃលិន (២ នាក់) ពោធិ៍សាត់ (៦នាក់) និងកំពង់ឆ្នាំង (៨នាក់) និងក្រុមសម្របសម្រួល២នាក់ **សរុបទាំងអស់ចំនួន ៤១នាក់**។
- **មណ្ឌលព្រះសីហនុ** សម្រាប់សិក្ខាកាមជាទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុកមកពីខេត្តព្រះសីហនុ (៤នាក់) កោះកុង (៧នាក់) កំពង់ស្ពឺ (៨នាក់) កំពត (៨នាក់) តាកែវ (១០នាក់) និងកែប (២នាក់) និងក្រុមសម្របសម្រួល២នាក់ **សរុបទាំងអស់ចំនួន ៤៤នាក់**។
- **មណ្ឌលខេត្តសៀមរាប** សម្រាប់សិក្ខាកាមជាទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ មកពីខេត្ត សៀមរាប (១២នាក់) កំពង់ធំ (៨នាក់) ព្រះវិហារ (៨នាក់) និងរាជធានីភ្នំពេញ (៩នាក់) និងក្រុមសម្របសម្រួល២នាក់ **សរុបទាំងអស់ចំនួន ៤៤នាក់**។
- **មណ្ឌលខេត្តមណ្ឌលគិរី** សម្រាប់សិក្ខាកាមជាទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុកមកពីខេត្តមណ្ឌលគិរី (៥នាក់) រតនគិរី (៩នាក់) ក្រចេះ (៦នាក់) ស្ទឹងត្រែង (៥នាក់) និងកណ្តាល (១១នាក់) និងក្រុមសម្របសម្រួល២នាក់ **សរុបទាំងអស់ចំនួន ៣៨នាក់**។

**ឃ). កាលបរិច្ឆេទ**

វគ្គបណ្តុះបណ្តាលនេះ នឹងគ្រោងរៀបចំនៅក្នុងខែមេសា និងដើមខែឧសភាឆ្នាំ២០១២។

**ង). ថវិកាគ្រោងទុក**

ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាលនេះមានចំនួន **១៨,៤៨០ដុល្លារអាមេរិក**។

**ច). សម្ភារៈចាំបាច់សម្រាប់ដំណើរការវគ្គបណ្តុះបណ្តាល**

- Markers, Flipchart, Paper stickers,

- Laptop Computer, LCD Projector, Handouts,

**ឌ). ទីកន្លែងសម្រាប់ការបណ្តុះបណ្តាល**

ខេត្តគោលដៅទាំង៥ (កំពង់ចាម បាត់ដំបង សៀមរាប ព្រះសីហនុ និងមណ្ឌលគិរី) ជាកន្លែងនៃការរៀបចំការបណ្តុះបណ្តាល ត្រូវបានស្នើសុំឱ្យសម្របសម្រួលក្នុងការផ្តល់បន្ទប់សម្រាប់ការបណ្តុះបណ្តាល ដោយមិនគិតថ្លៃ ដែលបន្ទប់នេះអាចផ្ទុកបានសិក្ខាកាមប្រមាណ៤០នាក់។ ក្នុងករណីមិនមានបន្ទប់ទំនេរសម្រាប់ការងារនេះ សូមផ្តល់ជម្រើសនានាជូនក្រុមសម្របសម្រួលនៅថ្នាក់ជាតិ។

**១.២៣. ដំណើរការនៃការផ្ទេរមុខងារ** (កូដសកម្មភាព 1.2.1.2.2, 1.2.1.2.3 និង 1.2.1.2.6)

**ក) ប្រវត្តិ**

ការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាសមាសភាគដ៏សំខាន់មួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការបង្វិតសេវាសាធារណៈឱ្យទៅកៀកជិតប្រជាពលរដ្ឋ និងកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ប្រកបដោយតម្លាភាព និងមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ។ ព្រមជាមួយនេះ ការផ្ទេរមុខងារ និងធនធាន ក៏ជាការពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់កិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដែលក្នុងនោះរួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានផងដែរ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើត និងដំណើរការចាប់តាំងពីឆ្នាំ២០០២មក។ ជាមួយនឹងការបង្កើតឡើងនូវក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាលក៏បានផ្ទេរធនធានថវិកាពីថវិកាជាតិឱ្យទៅឃុំ សង្កាត់មាន ការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ទន្ទឹមនឹងនេះ រចនាសម្ព័ន្ធ និងប្រព័ន្ធថ្មីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការជាបណ្តើរៗរួចហើយ បន្ទាប់ពីការបោះឆ្នោតនៅថ្នាក់រដ្ឋបាលទាំងនេះនាឆ្នាំ២០០៩មក។ ដូច្នេះពេលនេះជាវេលាដ៏សមស្របមួយ ដែលយើងត្រូវចាប់ផ្តើមគិតគូរអំពីការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងគ្រប់គ្រងការផ្តល់សេវាសាធារណៈនានា និងការអភិវឌ្ឍមូលដ្ឋាន ដែលអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព សំដៅឆ្លើយតបតម្រូវការជាអាទិភាពរបស់មូលដ្ឋានក្រោមការទទួលខុសត្រូវយ៉ាងពេញលេញ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាការពិតណាស់ កិច្ចដំណើរការផ្ទេរមុខងារ និងធនធាន គឺជាកិច្ចការដ៏សាំញ៉ាំ និងរសើប តែជាកិច្ចការចាំបាច់ដែលត្រូវតែអនុវត្ត ដោយមានការប្តេជ្ញាចិត្ត និងការសម្របសម្រួលជាមួយយុទ្ធសាស្ត្រតាមវិស័យនានា

សម្រាប់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ការងារនេះ ត្រូវ អនុវត្តដោយប្រុងប្រយ័ត្ន និងដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសង្គម សេដ្ឋកិច្ច និងសមត្ថភាពធនធានមនុស្សរបស់កម្ពុជាយើង ជាមួយការរៀនសូត្របទពិសោធន៍ពីប្រទេសផ្សេងៗទៀត ទាំងនៅក្នុង និងក្រៅតំបន់ ដើម្បីបង្ការកុំឱ្យមានការខុសឆ្គង និងត្រៀមលក្ខណៈបង្ការជាមុននូវបញ្ហាប្រឈម និងការគ្រប់គ្រងហានិភ័យនានា ដែលអាចលេចចេញពីដំណើរការផ្ទេរមុខងារ និងធនធាននេះឱ្យស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រង និងដោះស្រាយបាន។

ដើម្បីធានាឱ្យការងារខាងលើប្រព្រឹត្តទៅបានជោគជ័យ ក្រសួង ស្ថាប័ននានា ចាំបាច់ត្រូវយល់ដឹងពីគោលការណ៍អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដំណើការនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ) ខ្លឹមសារនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលផ្តោតទៅលើប្រធានបទដូចខាងក្រោម ៖

- ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ស្រុក ខណ្ឌ
- អនុក្រឹត្យស្តីពីដំណើរការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់
- សេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

## គ) យុទ្ធសាស្ត្រ

លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា រៀបចំឯកសារនានាសម្រាប់ការបណ្តុះបណ្តាលទាំងនេះ។ ការបណ្តុះបណ្តាល នឹងត្រូវរៀបចំឡើងជាបីដំណាក់កាល៖

- ដំណាក់កាលទីមួយ : រៀបចំសិក្ខាសាលាណែនាំស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ស្រុក ខណ្ឌ និងការផ្ទេរមុខងារ និងធនធានដល់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នទាំងអស់ ដែលស្ថិតនៅក្នុងវិស័យ ឬកិច្ចការអាទិភាព។ ចំនួនអ្នកចូលរួម ៤០រូប ក្នុងនោះ ៣០រូបមកពីក្រសួង ស្ថាប័នស្ថិតនៅក្នុងវិស័យ ឬកិច្ចការអាទិភាព និង១០រូបមកពីលេខាធិការដ្ឋាន គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍។ សិក្ខាសាលានេះមានរយៈពេល០១ថ្ងៃ។

- ដំណាក់កាលទីពីរ : រៀបចំសិក្ខាសាលាស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដល់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួងចំនួន ៦ គឺក្រសួងអបរំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន។ អ្នកចូលរួមមានចំនួន៣០រូប ក្នុងនោះ ២០រូបមកពីក្រសួង ស្ថាប័ន ស្ថិតនៅក្នុងវិស័យ ឬកិច្ចការអាទិភាព និងក្រសួង ស្ថាប័នពាក់ព័ន្ធ និង១០រូបមកពីលេខាធិការដ្ឋានគ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍។ សិក្ខាសាលានេះមានរយៈពេល១ថ្ងៃ។
- ដំណាក់កាលទីបី : រៀបចំសិក្ខាសាលាស្តីពីការពិនិត្យមើលមុខងារឡើងវិញរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដល់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួងចំនួន៦ គឺក្រសួងអបរំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន។ អ្នកចូលរួមមានចំនួន៣០រូប ក្នុងនោះ ២០រូបមកពីក្រសួង ស្ថាប័ន ស្ថិតនៅក្នុងវិស័យ ឬកិច្ចការអាទិភាព និងក្រសួង ស្ថាប័នពាក់ព័ន្ធ និង១០រូបមកពីលេខាធិការដ្ឋានគ.ជ.អ.បនិងដៃគូអភិវឌ្ឍន៍។ សិក្ខាសាលានេះមានរយៈពេល១ថ្ងៃ។

**ឃ) ពេលវេលានៃការរៀបចំការបណ្តុះបណ្តាល**

- ខែមេសា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដំណាក់កាលទីមួយ
- ខែឧសភា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដំណាក់កាលទីពីរ
- ខែមិថុនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដំណាក់កាលទីបី

**ង) ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលដំណាក់កាលទីមួយ : ៩៤០ ដុល្លារ
- ការបណ្តុះបណ្តាលដំណាក់កាលទីពីរ : ៣០,០០០ ដុល្លារ
- ការបណ្តុះបណ្តាលដំណាក់កាលទីបី : ១,៥០០ ដុល្លា

<u>សរុប : ៣២,៤៤០ ដុល្លារ</u>

# អនុកម្មវិធីទី២

# ផ្នែកទី២
# អនុកម្មវិធីទី២ "ក្រសួងមហាផ្ទៃ"

វគ្គបណ្តុះបណ្តាលសម្រាប់អនុកម្មវិធីទី២ ឆ្នាំ២០១២ មានចំនួន០៨ប្រធានបទដូចខាងក្រោម ៖

## ២.១. ការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក

### ក). ប្រវត្តិ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលនីមួយៗត្រូវ មានផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ហេតុនេះហើយបានជាក្នុងឆ្នាំ២០១១ រដ្ឋបាលក្រុង ស្រុកបានរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របពេលដែលរាជរដ្ឋាភិបាលគ្រោងផ្ទេរមូលនិធិដល់រដ្ឋបាលក្រុង ស្រុក ក្នុងឆ្នាំ២០១២នេះ គម្រោងអភិវឌ្ឍន៍មូលនិធិក្រុង ស្រុកនឹងចាប់ផ្តើមដំណើរការរបស់ខ្លួនជាលើកដំបូងនៅរដ្ឋបាលក្រុង ស្រុក។

ដើម្បីបង្កើនការយល់ដឹងក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍កាន់តែមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានគ្រោងវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ក្នុងផែនការបណ្តុះបណ្តាលឆ្នាំ២០១២ របស់អនុកម្មទី២។

### ខ). ខ្លឹមសារ

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក
- ការរៀបចំគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក
- លទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា
- ការត្រួតពិនិត្យ និងវាយតម្លៃអភិវឌ្ឍន៍ក្រុង ស្រុក
- ការថែរក្សាគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក។

ក្នុងឆ្នាំ២០១២នេះ ក្រសួងមហាផ្ទៃនឹងរៀបចំ និងអនុម័តសេចក្តីណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក។ បន្ទាប់ពីសេចក្តីណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិក្រុង ស្រុកត្រូវបានអនុម័ត ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិក្នុងអនុកម្មវិធីទី២នឹងរៀបចំឯកសារបណ្តុះបណ្តាល ហើយធ្វើការបណ្តុះបណ្តាលសាកល្បង។ ផ្អែកតាមលទ្ធផលនៃការបណ្តុះបណ្តាលសាកល្បង ឯកសារបណ្តុះបណ្តាលនឹងត្រូវកែសម្រួលសម្រាប់រៀបចំការបណ្តុះបណ្តាលជាផ្លូវការ។

### គ). យុទ្ធសាស្ត្រ

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួម មានចំនួនប្រមាណ៨០នាក់ ដែលមកពី២៤រាជធានី ខេត្ត (ដោយមួយរាជធានី ខេត្ត ចាត់បញ្ជូនសិក្ខាកាម ចូលរួម៣-៤នាក់ ក្នុងនោះ ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ១-២នាក់ យោងតាមទំហំខេត្ត ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត១នាក់ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគ១នាក់)។ ការបណ្តុះបណ្តាលរៀបចំជា២ថ្នាក់ ដែលមាន៤០នាក់ ក្នុងមួយថ្នាក់។ ការបណ្តុះបណ្តាលមានរយៈពេល០៥ថ្ងៃ។
- **ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្តុះបណ្តាលបន្តដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ដែលជាក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត នៃរាជធានី ខេត្ត។ ការបណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត មានរយៈពេល០៥ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក :** គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ដែលក្នុងនោះរួមមាន ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងនាយករងរដ្ឋបាល។ ការបណ្តុះបណ្តាលនឹងរៀបចំនៅថ្នាក់រាជធានី ខេត្ត រយៈពេល០១ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក :** គ្រូឧទ្ទេសដែលជាក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត នឹងរៀបចំបណ្តុះបណ្តាលបន្តដល់មន្ត្រីរដ្ឋបាលក្រុង ស្រុកនៅតាមក្រុង ស្រុក។ ការបណ្តុះបណ្តាលនេះ រៀបចំនៅថ្នាក់ក្រុង ស្រុករយៈពេល០៥ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែមេសា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែមេសា-ឧសភា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត
- ខែឧសភា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក
- ខែឧសភា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ: ១៦,៦៧០ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត : ៤,០៨០ ដុល្លារ
- ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក : ២៧,១៦០ដុល្លារ
- ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក : ៥៤,៣២០ ដុល្លារ

**សរុប : ១០២,២៣០ ដុល្លារ**

## ២.២. កិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ក). ប្រវត្តិ

បន្ទាប់ពី បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមក រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនតាមគោលការណ៍ នីតិវិធី និងរបៀបរបបការងារមួយថ្មី ហេតុនេះ ដើម្បីអនុវត្តដំណើរការកិច្ចការរដ្ឋបាលថ្មីនេះ ក្រសួងមហាផ្ទៃសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំ និងអនុម័តនូវសេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១២។

ដើម្បីបង្កើនការយល់ដឹងក្នុងការអនុវត្តកិច្ចការរដ្ឋបាលឱ្យមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានគ្រោងវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងផែនការបណ្តុះបណ្តាលឆ្នាំ២០១២ របស់អនុកម្មវិធីទី២។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទ ដូចខាងក្រោម ៖

- ប្រភេទលិខិតរដ្ឋបាល
- ការតាក់តែងលិខិត
- របៀបរបបការងារ
- ការគ្រប់គ្រងបុគ្គលិក
- ការគ្រប់គ្រងឧបករណ៍ និងសម្ភារៈ
- ការគ្រប់គ្រងឯកសារ

បន្ទាប់ពីសេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាលក្រុង ស្រុក ខណ្ឌ អនុម័តរួច ក្រុមអភិវឌ្ឍន៍សមត្ថភាព អនុកម្មវិធីទី២នឹងរៀបចំឯកសារបណ្តុះបណ្តាល រួចធ្វើការបណ្តុះបណ្តាលសាកល្បង។ ផ្អែកតាមលទ្ធផលនៃការបណ្តុះបណ្តាលសាកល្បងឯកសារបណ្តុះបណ្តាល នឹងត្រូវកែសម្រួលសម្រាប់រៀបចំការបណ្តុះបណ្តាលជាផ្លូវការ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិ :** វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួន៨០នាក់ មកពី២៤រាជធានី ខេត្ត (រាជធានី ខេត្តនីមួយៗ ចាត់បញ្ជូនមន្ត្រី៣-៤នាក់ ក្នុងនោះ ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត១-២នាក់ យោងតាមទំហំខេត្ត ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត១នាក់ និងមន្ត្រីទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្ត

១នាក់)។ ការបណ្តុះបណ្តាលរៀបចំជា២ថ្នាក់ ដែលមាន៤០នាក់ក្នុងមួយថ្នាក់។ ការបណ្តុះបណ្តាលមានរយៈ ពេល០៤ថ្ងៃ។

- **ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្តុះបណ្តាលបន្តដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ដែលជាក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្តនៅថ្នាក់រាជធានី ខេត្ត។ ការបណ្តុះបណ្តាលនេះរៀបចំនៅថ្នាក់រាជធានី ខេត្តក្នុងរយៈពេល០៤ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក :** គ្រូបង្គោលរាជធានី ខេត្ត នឹងរៀបចំការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលក្នុងនោះរួមមាន ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងនាយករងរដ្ឋបាល។ ការបណ្តុះបណ្តាលនេះរៀបចំនៅថ្នាក់រាជធានី ខេត្ត រយៈពេល០១ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក :** គ្រូឧទ្ទេសរាជធានី ខេត្ត នឹងរៀបចំការបណ្តុះបណ្តាលបន្តដល់មន្ត្រីរដ្ឋបាលក្រុង ស្រុកនៅតាមក្រុង ស្រុក។ ការបណ្តុះបណ្តាលនេះ រៀបចំនៅថ្នាក់ក្រុង ស្រុកមានរយៈពេល០៤ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមិថុនា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែកក្កដា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែកក្កដា-សីហា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត
- ខែសីហា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក
- ខែសីហា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ: ១៤,២៩០ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត : ៤,០៨០ ដុល្លារ
- ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក : ២៧,១៦០ដុល្លារ
- ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក : ៥៤,៣២០ដុល្លារ

**<u>សរុប : ៩៩,៨៥០ ដុល្លារ</u>**

## ២.៣. វគ្គតម្រង់ទិសការអភិវឌ្ឍស្ថាប័ន

### ក). ប្រវត្តិ

ក្នុងបរិបទថ្មីនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានស្វ័យភាពកាន់តែច្រើនក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន និងផ្តល់សេវានានាទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងគាំទ្រឃុំ សង្កាត់ ដូចនេះ ទាមទារឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានសមត្ថភាពមួយពេញលេញ និងប្រកបដោយវិជ្ជាជីវៈ។ ការអភិវឌ្ឍស្ថាប័នត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ក្នុងការបង្កើន និងពង្រឹងសមត្ថភាព ស្ថាប័ន និងសមត្ថភាពបុគ្គលិក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហេតុនេះហើយទើប ផអ៣ កំណត់ការអភិវឌ្ឍស្ថាប័នជាលទ្ធផលចម្បងមួយនៅក្នុងអនុកម្មវិធីទី២។ ការអភិវឌ្ឍស្ថាប័ននឹងត្រូវដាក់ឱ្យអនុវត្តនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ទាំង១៩៤ក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១២។

ការអភិវឌ្ឍស្ថាប័ន មិនត្រឹមតែអនុវត្តជាមួយបុគ្គលិករបស់រដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវអនុវត្តជាមួយថ្នាក់ដឹកនាំនានារបស់រដ្ឋបាលក្រុង ស្រុកផងដែរ ពិសេសក្នុងដំណើរការអនុវត្តត្រូវមានការគាំទ្រពីថ្នាក់ដឹកនាំរដ្ឋបាល ហេតុនេះ ដើម្បីបង្កើនការយល់ដឹងដល់រដ្ឋបាលក្រុង ស្រុក ក្រសួងមហាផ្ទៃបានគ្រោងវគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីពី ការអភិវឌ្ឍស្ថាប័នក្នុងផែនការបណ្តុះបណ្តាល ឆ្នាំ២០១២ របស់អនុកម្មទី២។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- សញ្ញាណនៃការអភិវឌ្ឍស្ថាប័ន
- ដំណើរការអភិវឌ្ឍស្ថាប័ន
- តួនាទី និងភារកិច្ចរបស់បណ្តាអ្នកពាក់ព័ន្ធ
- សមាសធាតុសំខាន់ៗនៃការអភិវឌ្ឍស្ថាប័ន

លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយក្រសួងមហាផ្ទៃ រៀបចំសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន។ បន្ទាប់មកដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។ បន្ទាប់ពីសៀវភៅណែនាំនេះអនុម័តរួច ក្រុមអភិវឌ្ឍន៍សមត្ថភាពអនុកម្មវិធីទី២ នឹងរៀបចំជាឯកសារបណ្តុះបណ្តាលសម្រាប់វគ្គតម្រង់ទិសនេះ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ត្រូវរៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលនេះមាន សិក្ខាកាមចូលរួមចំនួន៦៧នាក់មកពី២៤រាជធានី ខេត្ត (រាជធានី ខេត្តនីមួយៗចាត់បញ្ជូនទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្តទាំងអស់ ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត០១នាក់)។ ការ

បណ្តុះបណ្តាលរៀបចំជា២ថ្នាក់ ដែលមាន៣៣-៣៤នាក់ក្នុងមួយថ្នាក់។ ការបណ្តុះបណ្តាលមានរយៈពេល០៣ថ្ងៃ។

- **ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត** : គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្តុះបណ្តាលបន្តដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត (ដែលជាក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានីខេត្ត)។ ការបណ្តុះបណ្តាលនេះ រៀបចំនៅថ្នាក់រាជធានី ខេត្តរយៈពេល ៣ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក** : គ្រូឧទ្ទេសរាជធានី ខេត្ត នឹងរៀបចំការបណ្តុះបណ្តាលបន្តដល់មន្ត្រីទាំងអស់(ទាំងបុគ្គលិក និងថ្នាក់ដឹកនាំ)របស់រដ្ឋបាលក្រុង ស្រុកនៅតាមសាលាក្រុង ស្រុក ខណ្ឌ។ ការបណ្តុះបណ្តាលនេះរៀបចំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ មានរយៈពេល០៣ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែមេសា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែមេសា-ឧសភា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត
- ខែឧសភា-កក្កដា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ: ១០,៧២០ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត : ៤,០៨០ ដុល្លារ
- ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក : ៥៤,៣២០ ដុល្លារ

**សរុប : ៦៩,១២០ ដុល្លារ**

## ២.៤. ជំនាញអភិវឌ្ឍន៍ស្ថាប័ន

**ក). ប្រវត្តិ**

ក្នុងបរិបទថ្មីនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានស្វ័យភាពកាន់តែច្រើនក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន និងផ្តល់សេវានានាទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងគាំទ្រឃុំ សង្កាត់ ដូចនេះ ទាមទារឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានសមត្ថភាពមួយពេញលេញ និងប្រកបដោយវិជ្ជាជីវៈ។ ការអភិវឌ្ឍស្ថាប័នត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ក្នុងការបង្កើន និងពង្រឹងសមត្ថភាព ស្ថាប័ន និងសមត្ថភាពបុគ្គលិក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហេតុនេះ

ហើយ ទើបផអពាកំណត់ការអភិវឌ្ឍស្ថាប័នជាលទ្ធផលចម្បងមួយនៅក្នុងអនុកម្មវិធីទី២។ ការអភិវឌ្ឍស្ថាប័ននឹងត្រូវដាក់ឱ្យអនុវត្តនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ទាំង១៩៤ក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១២។

ការអភិវឌ្ឍស្ថាប័ន ជាដំណើរការថ្មីមួយក្នុងការអភិវឌ្ឍស្ថាប័នក្នុងថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយត្រូវធ្វើឡើងជាបន្តបន្ទាប់ និងជាប្រចាំតាមតម្រូវការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបុគ្គលម្នាក់ៗ ហេតុនេះ ក្រសួងមហាផ្ទៃបានគ្រោងវគ្គបណ្តុះបណ្តាលស្តីពីជំនាញអភិវឌ្ឍស្ថាប័ន ក្នុងផែនការបណ្តុះបណ្តាលឆ្នាំ២០១២ របស់អនុកម្មទី២។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- សញ្ញាណនៃការអភិវឌ្ឍស្ថាប័ន
- ដំណើរការអភិវឌ្ឍស្ថាប័ន
- ការតម្រង់ទិស
- ការប៉ាន់ប្រមាណតម្រូវការស្ថាប័ន
- ការរៀបចំផែនការអន្តរាគមន៍
- ការរៀបចំ និងផ្តល់អន្តរាគមន៍
- ការវាយតម្លៃលទ្ធផលអន្តរាគមន៍
- ទម្រង់ និងឧបករណ៍នានាសម្រាប់ការអភិវឌ្ឍស្ថាប័ន
- បន្ទាប់ពីសៀវភៅណែនាំនេះអនុម័តរួច ក្រុមអភិវឌ្ឍន៍សមត្ថភាពអនុកម្មវិធីទី២ នឹងរៀបចំជាឯកសារបណ្តុះបណ្តាល រួចបណ្តុះបណ្តាលសាកល្បង។ ផ្អែកតាមលទ្ធផលនៃការបណ្តុះបណ្តាលសាកល្បងឯកសារបណ្តុះបណ្តាលនឹងត្រូវកែសម្រួលសម្រាប់រៀបចំការបណ្តុះបណ្តាលផ្លូវការ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ជំនាញអភិវឌ្ឍន៍ស្ថាប័ននឹងត្រូវរៀបចំជា៣វគ្គបន្តបន្ទាប់គ្នា ដោយវគ្គទី១.បណ្តុះបណ្តាលសញ្ញាណនៃការអភិវឌ្ឍស្ថាប័ន ការតម្រង់ទិស ការប៉ាន់ប្រមាណតម្រូវការស្ថាប័នមានរយៈពេល០៥ថ្ងៃ វគ្គទី២.បណ្តុះបណ្តាលការរៀបចំ ផែនការអន្តរាគមន៍មានរយៈពេល០៤ថ្ងៃ និងវគ្គទី៣. បណ្តុះបណ្តាលការរៀបចំ និងផ្តល់អន្តរាគមន៍មានរយៈពេល០៤ថ្ងៃ ដោយអនុវត្តតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិ :** វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមចំនួន៦៧នាក់ មកពី២៤រាជធានី ខេត្ត (រាជធានី ខេត្តនីមួយៗចាត់បញ្ជូនទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្តទាំងអស់ ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ១នាក់)។ ការ

បណ្តុះបណ្តាលរៀបចំជា២ថ្នាក់ ដែលមាន៣៣-៣៤នាក់ ក្នុងមួយថ្នាក់។ ការបណ្តុះបណ្តាលមានរយៈពេល០៥ថ្ងៃ។

- **ការបណ្តុះបណ្តាលដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្ត នឹងរៀបចំការបណ្តុះបណ្តាលបន្តដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត។ ការបណ្តុះបណ្តាលរៀបចំនៅថ្នាក់រាជធានី ខេត្ត មានរយៈពេល០៥ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមេសា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែឧសភា កក្កដា កញ្ញា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែឧសភា កក្កដា កញ្ញា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ : ៤០,៨០០ ដុល្លារ
- ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត : ១២,២៤០ ដុល្លារ

**សរុប : ៥៣,០៤០ ដុល្លារ**

## ២.៥. ទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ

**ក). ប្រវត្តិ**

បញ្ហាយេនឌ័រជាអន្តរវិស័យ ត្រូវបានយកចិត្តទុកដាក់ក្នុងការបញ្ជ្រាបរាល់សកម្មភាពនានារបស់អនុកម្មវិធីទាំងអស់ក្នុង ផអ៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដើម្បីធ្វើឱ្យសកម្មភាពនានារបស់អនុកម្មវិធីទី២ មានប្រសិទ្ធភាព និងកាន់តែយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ អនុកម្មវិធីទី២ បានជួលសេវាពីអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិអំពីទស្សនៈយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព។ វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល០៦ថ្ងៃ ដែលរៀបចំជាពីរផ្នែក គឺផ្នែក ទី១.បណ្តុះបណ្តាលពីទស្សនយេនឌ័រ ដែលបានធ្វើឡើងកាលពីថ្ងៃទី១៤-១៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងផ្នែកទី២.បណ្តុះបណ្តាលពីឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍនឹងត្រូវធ្វើឡើងថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០១២។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- យុទ្ធសាស្ត្រយេនឌ័រក្នុង ផអ៣

- យេនឌ័រ និងការផ្តល់សេវា
- ទស្សនៈយេនឌ័រក្នុងកម្មវិធីរបស់ក្រុមប្រឹក្សា
- ការវិភាគយេនឌ័រ
- ការប៉ាន់ប្រមាណវិញ្ញោចយេនឌ័រក្នុងសេវាសាធារណៈ
- ការបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់
- យេនឌ័រ និងការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សា

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ រៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ** : ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិចំនួន ២៥នាក់ និងទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរបស់អនុកម្មវិធីទី២ ចំនួន០៣នាក់ និងត្រូវចូលរួមវគ្គបណ្តុះបណ្តាលនេះ ។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកុម្ភៈ ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែមីនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ : ៦,៧០៥ ដុល្លារ

**<u>សរុប : ៦,៧០៥ ដុល្លារ</u>**

## ២.៦. វគ្គរំលឹកឡើងវិញស្តីពីជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនៈយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព

**ក). ប្រវត្តិ**

ក្នុងឆ្នាំ២០១១ ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិបានទទួលការបណ្តុះបណ្តាលអំពីជំនាញអភិវឌ្ឍន៍សមត្ថភាពរយៈពេល១០ថ្ងៃ និងទស្សនយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាពរយៈពេល០៦ថ្ងៃ (ដោយផ្នែកទី១ រយៈពេល០៣ថ្ងៃ ក្នុងឆ្នាំ២០១១ និងផ្នែកទី២រយៈពេល០៣ថ្ងៃក្នុងឆ្នាំ២០១២) ។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលនេះមក ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិបានយកចំណេះដឹងទាំងនេះទៅប្រើប្រាស់ក្នុងការងាររបស់ខ្លួន ហេតុនេះដើម្បីឆ្លុះបញ្ចាំង និងបង្កើនគុណភាពការងារទាំងនោះបន្ថែម អនុកម្មវិធីទី២ បានរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព ដើម្បីបំពេញបន្ថែមនូវចំណេះដឹងខ្វះខាតកន្លងមក ។

## ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ការឆ្លុះបញ្ចាំងលើការអនុវត្តកន្លងមក
- ការប៉ាន់ប្រមាណតម្រូវការ
- ការរៀបចំផែនការសកម្មភាព
- វិធីសាស្ត្រសម្របសម្រួល
- ការត្រួតពិនិត្យ និងវាយតម្លៃវគ្គ
- ទស្សនយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រ

## គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ រៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ :** ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិចំនួន ២៥នាក់ ត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលសរុប០៥ថ្ងៃ ដោយចែកចេញជា២-៣លើក ហើយក្នុងមួយលើកៗ អាចមានរយៈពេល១-២ថ្ងៃ។

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែឧសភា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែមិថុនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ

## ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ : ៥,៨៥០ ដុល្លារ

**សរុប : ៥,៨៥០ ដុល្លារ**

# ២.៧. ជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនៈយេនឌ័រសម្រាប់ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត

## ក). ប្រវត្តិ

នៅក្នុងឆ្នាំដំបូងៗនៃការអនុវត្ត ផអ៣ មានតម្រូវការជាច្រើនក្នុងការបង្កើនការយល់ដឹងលើគោលការណ៍ ប្រព័ន្ធ និងនីតិវិធីនានា។ ម្យ៉ាងទៀត ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ទើបតែបានរៀបចំជាលើកដំបូង ហេតុនេះដើម្បីធ្វើឱ្យក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្តមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជួយការងារអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិកនៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក៏ដូចជារួមចំណែកក្នុងការអភិវឌ្ឍស្ថាប័ននៅក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃបានគ្រោងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញអភិវឌ្ឍន៍សមត្ថភាពក្នុងឆ្នាំ២០១២នេះ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- បញ្ញត្តិទូទៅយេនឌ័រ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
- ការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសមត្ថភាព
- ការគ្រោងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព
- ការរៀបចំឯកសារ ប្លង់មេរៀន និងសម្ភារៈជំនួយ
- វិធីសាស្ត្រអភិវឌ្ឍន៍សមត្ថភាពតាមបែបចូលរួម
- ការត្រួតពិនិត្យ និងវាយតម្លៃវគ្គ

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ រៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិ :** វគ្គបណ្តុះបណ្តាលមានសិក្ខាកាមចូលរួមចំនួន៦៧នាក់មកពី២៤រាជធានី ខេត្ត (រាជធានី ខេត្តនីមួយៗ ចាត់បញ្ជូនទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្តទាំងអស់ និងក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត០១នាក់)។ ការបណ្តុះបណ្តាលរៀបចំជា០២ថ្នាក់ ដែលមាន៣៣-៣៤នាក់ក្នុងមួយថ្នាក់។ ការបណ្តុះបណ្តាលមានរយៈពេល១០ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្តុះបណ្តាលបន្តដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ក្រៅពីនេះ រាជធានី ខេត្តមួយចំនួនក៏បានបញ្ចូលទីប្រឹក្សាគាំទ្រកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ខណ្ឌ ផងដែរ តាមលទ្ធភាពរាជធានី ខេត្តនីមួយៗ (ចំនួនសិក្ខាកាមក្នុងថ្នាក់នីមួយៗ)។ ការបណ្តុះបណ្តាលនេះរៀបចំនៅថ្នាក់រាជធានី ខេត្ត មានរយៈពេល១០ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមករា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែកុម្ភៈ ឆ្នាំ២០១២ : ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែមីនា ឆ្នាំ២០១២ : ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ : ២៧,៤៤០ ដុល្លារ
- ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត : ៤,០៨០ ដុល្លារ

**សរុប : ៣១,៥២០ ដុល្លារ**

## ២.៨. សេវាសង្គមសម្រាប់ គ.ក.ស.ក និង គ.ក.ន.ក

### ក). ប្រវត្តិ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ បានបង្កើតឡើងក្នុងឆ្នាំ២០០៧ (យោងតាមសេចក្តីណែនាំលេខ សជណ ០៨២/គ.ជ.វ.វ) ដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តមុខងារក្នុងការផ្តល់សេវាសង្គមនៅមូលដ្ឋាន។ បន្ទាប់ពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានដាក់ឱ្យប្រើប្រាស់មករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្មី និងរៀបចំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ខ្លួន ជាហេតុធ្វើឱ្យប្រព័ន្ធទំនាក់ទំនង និងការគាំទ្រឃុំ សង្កាត់ត្រូវបានកែសម្រួល ហេតុនេះ ខ្លឹមសារ សេចក្តីណែនាំមួយចំនួនទាក់ទងនឹងការផ្តល់សេវាសង្គមរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏ត្រូវធ្វើបច្ចុប្បន្នភាពផងដែរ។ ក្នុងឆ្នាំ២០១២ ក្រសួងមហាផ្ទៃបានរៀបចំកែសម្រួលខ្លឹមសារសេចក្តីណែនាំមួយចំនួនទាក់ទងនឹងការផ្តល់សេវាសង្គមនៅឃុំ សង្កាត់។

ដើម្បីបង្កើនការយល់ដឹងដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ក្រសួងមហាផ្ទៃបានគ្រោងវគ្គបណ្តុះបណ្តាលស្តីពីសេវាសង្គមសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងផែនការបណ្តុះបណ្តាល ឆ្នាំ២០១២របស់អនុកម្មទី២។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- តួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- យន្តការគាំទ្រគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- ការអភិវឌ្ឍផ្នែកសង្គម ឬសេវាសង្គម

បន្ទាប់ពីក្រសួងមហាផ្ទៃ សហការជាមួយក្រុមការងារសេវាសង្គមថ្នាក់ជាតិរបស់ គ.ជ.អ.ប អង្គការ UNICEF និងអង្គការ UNFPA រៀបចំសៀវភៅណែនាំស្តីពីសេវាសង្គមមក ក្រុមការងារនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងរៀបចំឯកសារបណ្តុះបណ្តាល និងធ្វើការបណ្តុះបណ្តាលសាកល្បង ដើម្បីកែសម្រួលមុននឹងដាក់ឱ្យបណ្តុះបណ្តាលជាផ្លូវការ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំតាមដំណាក់កាល ដូចខាងក្រោម ៖

- **ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិ :** ការបណ្ដុះបណ្ដាលនេះមានសិក្ខាកាមចូលរួមចំនួន១០៥នាក់ មកពី២៤រាជធានី ខេត្ត (រាជធានី ខេត្តនីមួយៗ ចាត់បញ្ជូនមន្ត្រីចំនួន ៣-៤នាក់ ក្នុងនោះមានទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ០១នាក់ មន្ត្រីទីចាត់ការផែនការ និងវិនិយោគ០១នាក់ ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត០១នាក់ និងមន្ត្រីទទួលបន្ទុកសេវាសង្គម០១នាក់)។ ការបណ្ដុះបណ្ដាលរៀបចំជា០២ថ្នាក់ ដែលមាន៥២-៥៣នាក់ក្នុងមួយថ្នាក់។ ការបណ្ដុះបណ្ដាលនេះមានរយៈពេល០៤ថ្ងៃ។
- **ការបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្តនឹងរៀបចំការបណ្ដុះបណ្ដាលដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ដែលជាក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត និងក្រុមសេវាសង្គមថ្នាក់រាជធានី ខេត្ត។ ការបណ្ដុះបណ្ដាលនេះរៀបចំនៅថ្នាក់រាជធានី ខេត្ត រយៈពេល០៣ថ្ងៃ។
- **ការបណ្ដុះបណ្ដាលដល់ គ.ក.ស.ក រាជធានី ខេត្ត :** គ្រូបង្គោលរាជធានី ខេត្ត រៀបចំការបណ្ដុះបណ្ដាលដល់សមាជិក គ.ក.ស.ក របស់ក្រុមប្រឹក្សារាជធានី ខេត្ត នៅតាមសាលារាជធានី ខេត្ត។ ការបណ្ដុះបណ្ដាលនេះ មានរយៈពេល ២ថ្ងៃ។
- **ការបណ្ដុះបណ្ដាលដល់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ :** គ្រូឧទ្ទេសរាជធានី ខេត្ត នឹងរៀបចំការបណ្ដុះបណ្ដាល ដល់សមាជិក គ.ក.ស.ក របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅតាមសាលាក្រុង ស្រុក ខណ្ឌ។ ការបណ្ដុះបណ្ដាលនេះមានរយៈពេល ២ថ្ងៃ។
- **ការបណ្ដុះបណ្ដាលដល់ គ.ក.ន.ក :** គ្រូឧទ្ទេសរាជធានី ខេត្ត នឹងរៀបចំការបណ្ដុះបណ្ដាលដល់សមាជិក គ.ក.ន.ក ឃុំ សង្កាត់។ ការបណ្ដុះបណ្ដាលនឹងរៀបចំនៅតាមឃុំ សង្កាត់នីមួយៗ មានរយៈពេល ២ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្ដុះបណ្ដាល**

- ខែមិថុនា ឆ្នាំ២០១២ : ការរៀបចំឯកសារបណ្ដុះបណ្ដាល
- ខែកញ្ញា ឆ្នាំ២០១២ : ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ
- ខែកញ្ញា-តុលា ឆ្នាំ២០១២ : ការបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត
- ខែកញ្ញា-តុលា ឆ្នាំ២០១២ : ការបណ្ដុះបណ្ដាលដល់ គ.ក.ស.ក រាជធានី ខេត្ត
- ខែកញ្ញា-តុលា ឆ្នាំ២០១២ : ការបណ្ដុះបណ្ដាលដល់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ
- ខែតុលា-វិច្ឆិកា ឆ្នាំ២០១២ : ការបណ្ដុះបណ្ដាលដល់ គ.ក.ន.ក ឃុំ សង្កាត់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ: ២៤,៥១៥ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត : ២២,៥៦០ ដុល្លារ
- ការបណ្តុះបណ្តាលដល់ គ.ក.ន.ក : ៣៤២,៩៣០ ដុល្លារ
- ការបណ្តុះបណ្តាលដល់ គ.ក.ស.ក រាជធានី ខេត្ត : ៣,៨៤០ ដុល្លារ
- ការបណ្តុះបណ្តាលដល់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ : ៤០,៧៤០ ដុល្លារ

<u>**សរុប : ៤៣៤,៥៨៥ ដុល្លារ**</u>

# អនុកម្មវិធីទី៣

# ផ្នែកទី៣

# អនុកម្មវិធីទី៣ "រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ"

ក្នុងឆ្នាំ២០១២ អនុកម្មវិធីទី៣ មានវគ្គបណ្តុះបណ្តាលចំនួន ០១ គឺ ៖

## ៣.១. ផ្សព្វផ្សាយអំពីគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

### ក). ប្រវត្តិ

ចំនុចសំខាន់របស់អនុកម្មវិធីទី៣នៃផអ៣ គឺផ្តោតទៅលើការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានាថា ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មូលដ្ឋានក្នុងបរិបទនៃកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ដោយផ្អែកតាមស្ថានភាពបច្ចុប្បន្ន សមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតទាបនៅឡើយក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិសេសក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ អាស្រ័យហេតុនេះ ការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសមត្ថភាពនឹងត្រូវអនុវត្តជាបន្តបន្ទាប់ក្នុង ផអ៣ ដំបូងនេះ។

ដូច្នេះការផ្សព្វផ្សាយគោលនយោបាយ និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅរដ្ឋបាលក្រោមជាតិនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ ២០១២ របស់ គ.ជ.អ.ប។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃការការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋ
- ការផ្សព្វផ្សាយគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការគ្រប់គ្រងបុគ្គលិក មន្ត្រីរាជនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យន្តការគាំទ្រការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមការងារអនុកម្មវិធីទី៣នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នឹងរៀបចំការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលតាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនៅថ្នាក់ជាតិ :** ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះនឹងអញ្ជើញមន្ត្រីពាក់ព័ន្ធមកពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មកទទួលការផ្សព្វផ្សាយនៅរាជធានីភ្នំពេញ ។
- **ការបណ្តុះបណ្តាលក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត :** ក្រុមការងារមួយនឹងត្រូវបានរៀបចំ និងចុះតាមបណ្តាខេត្ត ក្រុង ស្រុកគោលដៅដើម្បីផ្សព្វផ្សាយគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងសៀវភៅណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រង បុគ្គលិកមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកុម្ភៈ-មេសា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែមិថុនា ឆ្នាំ២០១២ : ផ្សព្វផ្សាយនៅថ្នាក់ជាតិលើកទី០១
- ខែកក្កដា-កញ្ញា ឆ្នាំ២០១២ : ក្រុមការងារចុះផ្សព្វផ្សាយនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក
- ខែតុលា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែវិច្ឆិកា ឆ្នាំ ២០១២ : ការផ្សព្វផ្សាយនៅថ្នាក់ជាតិលើកទី០២

**ង). ថវិកាគ្រោងសម្រាប់ការផ្សព្វផ្សាយ**

- ការផ្សព្វផ្សាយនៅថ្នាក់ជាតិលើកទី១ : ៥៤,១០០ ដុល្លារ
- ការផ្សព្វផ្សាយនៅថ្នាក់ជាតិលើកទី២ : ២៨,១៨០ ដុល្លារ

**<u>សរុប : ៨២,២៨០ ដុល្លារ</u>**

# អនុក្រមវិធីទី៤

# ផ្នែកទី៤
# អនុកម្មវិធីទី៤ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"

ប្រធានបទអភិវឌ្ឍន៍សមត្ថភាពសំខាន់ៗ ដែលអនុកម្មវិធីទី៤គ្រោងអនុវត្តក្នុងឆ្នាំ២០១២ មានចំនួន ០៦ប្រធានបទ រួមមាន ៖

## ៤.១. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអព

### ក). ប្រវត្តិ

អនុកម្មវិធីទី៤របស់ផអព ផ្ដោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មី សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្ដោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ៤.៤នៃអនុកម្មវិធីទី៤ កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាព ដោយផ្ដោតសំខាន់លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i)សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង (ii)ពិនិត្យតាមដាន និងវាយតម្លៃ លទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្ដោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គឺនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះ ជាការសំខាន់ណាស់ ដែលនាយកដ្ឋាននេះត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤ ។

### ខ). ខ្លឹមសារនៃការបណ្ដុះបណ្ដាល

វគ្គបណ្ដុះបណ្ដាលនេះ ផ្ដោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអព
- ការរៀបចំថវិកា (រចនាសម្ព័ន្ធនៃលេខកូដថវិកា)
- ការអនុវត្តថវិកា (កិច្ចបញ្ជីការគណនេយ្យ និយ័តថវិកា...)
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការិយបរិច្ឆេទ

ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលរបស់ថ្នាក់ក្រោមជាតិមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមកពីក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ និងមន្ត្រីពីផ្នែកហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន

គ.ជ.អ.ប ។ ក្រុមការងារនេះមានតួនាទីរៀបចំ ពិនិត្យលើខ្លឹមសារឯកសារមេរៀន និងបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ ផអ៣ ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៩៦រូប (០៤រូប/រាជធានី-ខេត្ត ក្នុងនោះនាយកទីចាត់ការហិរញ្ញវត្ថុ និងមន្ត្រីហិរញ្ញវត្ថុផអ៣ រាជធានី-ខេត្ត០២រូប ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី-ខេត្ត០១រូប និងមន្ត្រីបច្ចេកទេសហិរញ្ញវត្ថុរាជធានី-ខេត្ត០១រូប)។ ការបណ្តុះបណ្តាលត្រូវបានចែកជា០២ថ្នាក់ ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប៤៨នាក់។ ការបណ្តុះបណ្តាលនេះមានរយៈពេល០២ថ្ងៃ។
- **ការបណ្តុះបណ្តាលមន្ត្រីមកពីគ្រប់ទីចាត់ការនានាថ្នាក់រាជធានី ខេត្ត :** បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅរាជធានី ខេត្តរបស់ខ្លួនដល់មន្ត្រីតាមទីចាត់ការនានាថ្នាក់រាជធានី ខេត្ត ដោយរួមបញ្ចូលទាំងទីប្រឹក្សាផអ៣ទាំងអស់របស់រាជធានី ខេត្តផងដែរ (សិក្ខាកាមប្រមាណ ១៥នាក់/រាជធានីខេត្ត) ដើម្បីឱ្យពួកគេបានយល់ពីប្រព័ន្ធនេះ។ ការបណ្តុះបណ្តាលនេះមានរយៈពេល០២ថ្ងៃ។
- **ការបណ្តុះបណ្តាលថ្នាក់ដឹកនាំរបស់រាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលថ្នាក់ដឹកនាំរាជធានី ខេត្ត មានសិក្ខាកាមចំនួន១២០រូប (ក្រុមប្រឹក្សាចំនួន០២រូប គណៈអភិបាលចំនួន០២រូប និងនាយករដ្ឋបាលចំនួន០១រូប ក្នុងមួយរាជធានី ខេត្ត) ហើយចែកចេញជាពីរថ្នាក់ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប ៦០នាក់។ ការបណ្តុះបណ្តាលនេះមានរយៈពេល០១ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា-មេសា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែមេសា-ឧសភា ឆ្នាំ២០១២ : បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែមេសា-ឧសភា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រីតាមទីចាត់ការនានារបស់ថ្នាក់ជធានី ខេត្ត
- ខែមថុនា ឆ្នាំ២០១២ : បណ្តុះបណ្តាលថ្នាក់ដឹកនាំរបស់រាជធានី ខេត្ត

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១០,២០៤ ដុល្លារ
- បណ្តុះបណ្តាលមន្ត្រីតាមទីចាត់ការនានានៅថ្នាក់រាជធានី-ខេត្ត : ១,៣៦៨ ដុល្លារ
- បណ្តុះបណ្តាលថ្នាក់ដឹកនាំរាជធានី ខេត្តនៅថ្នាក់ជាតិ : ១០,៣៧០ ដុល្លារ

**សរុប : ២១,៩៤២ ដុល្លារ**

## ៤.២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក

### ក). ប្រវត្តិ

អនុកម្មវិធីទី៤ របស់ផអព ផ្តោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មី សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្តោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ៤.៤នៃអនុកម្មវិធីទី៤ កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាព ដោយផ្តោតសំខាន់ លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i) សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង (ii)ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្តោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គឺនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះជាការសំខាន់ណាស់ដែលនាយកដ្ឋាននេះត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក
- ចំណូល ចំណាយរបស់ក្រុង ស្រុក
- ការរៀបចំ និងការអនុម័តថវិកាក្រុង ស្រុក
- ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ក្រុង ស្រុក
- ការគ្រប់គ្រងចំណាយរបស់ក្រុង ស្រុក
- ការងារលទ្ធកម្មសាធារណៈ និងទ្រព្យសម្បត្តិរបស់ក្រុង ស្រុក
- សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ក្រុង ស្រុក
- របាយការណ៍ហិរញ្ញវត្ថុក្រុង ស្រុក

ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមកពីក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ រតនាគារជាតិ និងមន្ត្រីពីផ្នែកហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន គ.ជ.អ.ប។ ក្រុមការងារនេះមានតួនាទីរៀបចំ ពិនិត្យលើខ្លឹមសារឯកសារមេរៀន និងបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុង ស្រុក។

គ). **យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៩៦រូប (០៤រូប/រាជធានី-ខេត្ត ក្នុងនោះមកពីក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី-ខេត្ត០១រូប ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី-ខេត្ត០១រូប មន្ត្រីបច្ចេកទេសហិរញ្ញវត្ថុរាជធានី-ខេត្ត០១រូប និងមន្ត្រីហិរញ្ញវត្ថុផ្អែកពីទីចាត់ការហិរញ្ញវត្ថុរាជធានី-ខេត្ត០១រូប)។ ការបណ្តុះបណ្តាលត្រូវបានចែកជា០២ថ្នាក់ ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប ៤៨នាក់។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៤ថ្ងៃ។
- **ការបណ្តុះបណ្តាលដល់មន្ត្រីជំនាញរបស់រដ្ឋបាលក្រុង ស្រុក :** បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅរាជធានី ខេត្តដល់មន្ត្រីពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ចំនួន០២រូប និងទីប្រឹក្សាក្រុង ស្រុកចំនួន០១រូប (០៣នាក់/ក្រុង ស្រុក) នៅថ្នាក់រាជធានី ខេត្ត។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៤ថ្ងៃ។
- **ការបណ្តុះបណ្តាលថ្នាក់ដឹកនាំរបស់រដ្ឋបាលក្រុង ស្រុក :** គ្រូបង្គោលរបស់រាជធានី ខេត្ត សហការជាមួយទីប្រឹក្សាក្រុង ស្រុកត្រូវបណ្តុះបណ្តាលថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុកទាំងអស់ (គ្រប់ក្រុមប្រឹក្សាទាំងអស់ គ្រប់គណៈអភិបាលទាំងអស់ និងនាយក នាយរងរដ្ឋបាលទាំងអស់) ហើយការបណ្តុះបណ្តាល នេះត្រូវធ្វើឡើងនៅតាមសាលាក្រុង ស្រុក ដែលមានរយៈពេល០២ថ្ងៃ។

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមេសា-ឧសភា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែឧសភា ឆ្នាំ២០១២ : បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែមិថុនា-កក្កដា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រីជំនាញរបស់រដ្ឋបាលថ្នាក់ក្រុង ស្រុក
- ខែមិថុនា-កក្កដា ឆ្នាំ២០១២ : បណ្តុះបណ្តាលថ្នាក់ដឹកនាំក្រុង ស្រុក

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ១៥,០៦០ ដុល្លារ
- បណ្តុះបណ្តាលមន្ត្រីជំនាញក្រុង ស្រុកនៅថ្នាក់រាជធានី-ខេត្ត : ៦៤,៣៨០ ដុល្លារ
- បណ្តុះបណ្តាលថ្នាក់ដឹកនាំក្រុង ស្រុក : ១៥,៦៥៧ ដុល្លារ

**<u>សរុប : ៩៥,០៩៧ ដុល្លារ</u>**

## ៤.៣. ការអនុវត្តថវិកាក្រុង ស្រុក ឆ្នាំ២០១២

### ក). ប្រវត្តិ

អនុកម្មវិធីទី៤ របស់ផអ៣ ផ្ដោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មីសម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្ដោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាពដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ ៤.៤នៃអនុកម្មវិធីទី៤កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាព ដោយផ្ដោតសំខាន់លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i) សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង (ii) ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ នៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្ដោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គឺនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះ ជាការសំខាន់ណាស់ ដែលនាយកដ្ឋាននេះ ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤។

### ខ). ខ្លឹមសារនៃការបណ្ដុះបណ្ដាល

វគ្គបណ្ដុះបណ្ដាលនេះ ផ្ដោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងថវិកាក្រុង ស្រុកដែលជាផ្នែកមួយនៃថវិការាជធានី ខេត្ត
- ការរៀបចំថវិកា (មាតិកាគណនី)
- ការអនុវត្តថវិកា (កិច្ចបញ្ជីការគណនេយ្យ និយ័តថវិកា...)
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការិយបរិច្ឆេទ

ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមកពីក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ អគ្គនាយកដ្ឋានរតនាគារជាតិ និងមន្ត្រីពីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រុមការងារនេះមានតួនាទីរៀបចំ ពិនិត្យលើខ្លឹមសារឯកសារមេរៀន និងបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងនិងអនុវត្តថវិកាក្រុង ស្រុកឆ្នាំ២០១២ ដែលជាផ្នែកមួយនៃថវិការាជធានី ខេត្ត។

### គ). យុទ្ធសាស្ត្រនៃការបណ្ដុះបណ្ដាល

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្ដុះបណ្ដាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្ត នៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៩៦រូប (០៤រូប/រាជធានី-ខេត្ត

ក្នុងនោះមកពី ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី-ខេត្ត០១រូប មន្ត្រីបច្ចេកទេសហិរញ្ញវត្ថុរាជធានី ខេត្ត០១រូប មន្ត្រីគណនេយ្យករក្រុង ស្រុក០១រូប និងទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី ខេត្ត០១រូប)។ ការបណ្តុះបណ្តាលត្រូវបានចែកជា០២ថ្នាក់ ដោយមួយថ្នាក់ៗមានសិក្ខាកាមសរុប ៤៨នាក់។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ។

- **ការបណ្តុះបណ្តាលមន្ត្រីជំនាញនៅថ្នាក់រាជធានី ខេត្ត** : បន្ទាប់ពីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ គ្រូបង្គោលមកពីរាជធានី ខេត្តនីមួយៗត្រូវរៀបចំការបណ្តុះបណ្តាលបន្តនៅរាជធានី ខេត្តរបស់ខ្លួនដល់មន្ត្រីពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុកចំនួន ០២រូប និងទីប្រឹក្សាកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ (សិក្ខាកាមចំនួន០៣នាក់/១ក្រុង ស្រុក)។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា ឆ្នាំ២០១១២ : ការរៀបចំឯកសារ
- ខែមេសា ឆ្នាំ២០១២ : បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែមេសា-ឧសភា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រីជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១២,៤២៤ ដុល្លារ
- បណ្តុះបណ្តាលមន្ត្រីជំនាញនៅថ្នាក់ជធានី ខេត្ត : ៥៣,៤០០ ដុល្លារ

**សរុប : ៦៥.៨២៤ ដុល្លារ**

## ៤.៤. សិក្ខាសាលាពិនិត្យលើឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំអំពីការគ្រប់គ្រង ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

**ក). ប្រវត្តិ**

អនុកម្មវិធីទី៤ របស់ផអ៣ ផ្តោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មី សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្តោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ៤.៤នៃអនុកម្មវិធីទី៤ កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដោយផ្តោតសំខាន់ លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i) សមត្ថភាពរបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ ដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង(ii)ពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្តោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គឺនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះ ជាការសំខាន់ណាស់ដែលនាយកដ្ឋាននេះត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤ ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ជាតិ និងនីតិវិធីទូទាត់
- ប្រព័ន្ធគណនេយ្យ (រចនាសម្ព័ន្ធនៃលេខកូដថវិកា)
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការិយបរិច្ឆេទ
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជធានី ខេត្ត និងនីតិវិធិទូទាត់
- ប្រព័ន្ធគណនេយ្យ (រចនាសម្ព័ន្ធនៃលេខកូដថវិកា)
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការិយបរិច្ឆេទ

សិក្ខាសាលានេះនឹងរៀបចំឡើងក្រោមកិច្ចសហការរវាងក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងគោលបំណងប្រមូលនូវធាតុចូលនានាពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចងក្រងជាសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនិងរដ្ឋបាលថ្មីមួយសម្រាប់អនុវត្តដំណើរការផអព។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **សិក្ខាសាលានៅថ្នាក់ជាតិ :** សិក្ខាសាលាពិនិត្យលើឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិត្រូវធ្វើឡើងនៅថ្នាក់ជាតិ
  ដោយមានសិក្ខាកាមចូលរួមចំនួន១៤៥រូប (០៥រូប/រាជធានី-ខេត្ត ០៣រូប/អនុកម្មវិធី និងមន្ត្រីពីលេខាធិការដ្ឋានចំនួន០៧រូប) ។ សិក្ខាសាលានេះមានរយៈពេល០២ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមេសា-ឧសភា ឆ្នាំ២០១១២ : ការរៀបចំឯកសារ
- ខែមិថុនា-កក្កដា ឆ្នាំ២០១២ : សិក្ខាសាលាថ្នាក់ជាតិ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- សិក្ខាសាលានៅថ្នាក់ជាតិ : ១២,៦៥១ ដុល្លារ

**សរុប : ១២,៦៥១ ដុល្លារ**

## ៤.៥. បណ្តុះបណ្តាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ

### ក). ប្រវត្តិ

អនុកម្មវិធីទី៤ របស់ផអព ផ្តោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មីសម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្តោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ៤.៤នៃអនុកម្មវិធីទី៤ កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាព ដោយផ្តោតសំខាន់លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i) សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង(ii)ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ នៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្តដោយផ្តោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺ **នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះ ជាការសំខាន់ណាស់ដែលនាយកដ្ឋាននេះត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃថវិកាក្រុង ស្រុក
- ទម្រង់ និងមាតិកាថវិកាក្រុង ស្រុក
- ប្រព័ន្ធទូទាត់ និងគណនេយ្យថវិកាក្រុង ស្រុក
- មាតិកាគណនីនៃគណនេយ្យថវិកាក្រុង ស្រុក
- ការរៀបចំ អនុម័ត និងអនុវត្តថវិកាក្រុង ស្រុក

ក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ និងអគ្គនាយកដ្ឋានរតនាគារជាតិ នឹងរៀបចំក្រុមការងារមួយដោយក្រុមការងារនេះមានតួនាទីរៀបចំ ពិនិត្យលើខ្លឹមសារឯកសារមេរៀន និងបណ្តុះបណ្តាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់

រាជធានី ខេត្តនៅថ្នាក់ជាតិនឹងត្រូវរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៩៧រូប (០៣រូប/រាជធានី ខេត្ត ក្នុងនោះមកពីប្រធានគណនេយ្យកររាជធានី-ខេត្ត០១រូប ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី-ខេត្ត ០១រូប និងមន្ត្រីគណនេយ្យករក្រុង ស្រុក ខណ្ឌ០១រូប ព្រមទាំងពីលេខាធិការដ្ឋាន គ.ជ.អ.ប និងអនុកម្មវិធីទាំងអស់ ចំនួន២៥រូប)។ ការបណ្តុះបណ្តាលនេះមានរយៈពេល០២ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកញ្ញា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែតុលា ឆ្នាំ២០១២ : បណ្តុះបណ្តាលបំប៉ននៅថ្នាក់ជាតិ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលបំប៉ននៅថ្នាក់ជាតិ : ៧,៩០៩ ដុល្លារ

**<u>សរុប : ៧,៩០៩ ដុល្លារ</u>**

## ៤.៦. ការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ប្រចាំឆ្នាំ

**ក). ប្រវត្តិ**

អនុកម្មវិធីទី៤ របស់ផអព ផ្តោតការយកចិត្តទុកដាក់ច្រើនលើវិសាលភាពទូលំទូលាយនៃការអភិវឌ្ឍសមត្ថភាព ដែលចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌស្ថាប័នថ្មី សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ជាពិសេសគឺផ្តោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដូចដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វិសាលភាពនៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាសភាគ៤.៤នៃអនុកម្មវិធីទី៤ កំណត់គោលដៅនៃសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដោយផ្តោតសំខាន់ លើការលើកកម្ពស់សមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ (i) សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបំពេញការងារក្រោមការរៀបចំស្ថាប័នថ្មីសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និង(ii)ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ នៅពេលប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្តោតសំខាន់លើការងារផ្ទាល់របស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន។ តួអង្គសំខាន់ដែលទទួលខុសត្រូវក្នុងការបំពេញមុខងារគាំទ្រក្នុងការរៀបចំ និងត្រួតពិនិត្យក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ **នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**។ ដូច្នេះ ជាការសំខាន់ណាស់ដែលនាយកដ្ឋាននេះត្រូវពង្រឹងសមត្ថភាពបន្ថែមទៀតដើម្បីអនុវត្តតួនាទីរបស់ខ្លួនក្នុងអនុកម្មវិធីទី៤។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអព
- ការរៀបចំថវិកា (រចនាសម្ព័ន្ធនៃលេខកូដថវិកា)
- ការអនុវត្តថវិកា (កិច្ចបញ្ជីការគណនេយ្យ និយ័តថវិកា...)
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមការិយបរិច្ឆេទ

វគ្គបណ្តុះបណ្តាលនេះរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ សហការជាមួយក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤។ អគ្គនាយកដ្ឋានរតនាគារជាតិនឹងរៀបចំ ពិនិត្យលើខ្លឹមសារឯកសារមេរៀន និងបណ្តុះបណ្តាលអំពីការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ប្រចាំឆ្នាំ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ក្រុមការងារនឹងរៀបចំ និងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- **ការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធរបស់រាជធានី ខេត្តនៅថ្នាក់ជាតិ :** ការបណ្តុះបណ្តាលនេះធ្វើឡើងនៅថ្នាក់ជាតិដោយមានសិក្ខាកាមចូលរួមចំនួន១២១រូប (០៤រូប/រាជធានី-ខេត្ត ក្នុងនោះ ប្រធានរតនាគាររាជធានី-ខេត្ត០១រូប ប្រធានគណនេយ្យកររតនាគារថ្នាក់រាជធានី-ខេត្ត០១រូប ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី-ខេត្ត០១រូប មន្ត្រីគណនេយ្យករក្រុង-ស្រុកថ្នាក់រាជធានី-ខេត្ត០១រូប និងមន្ត្រីពាក់ព័ន្ធនៅថ្នាក់ជាតិ២៥រូប)។ ការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែវិច្ឆិកា ឆ្នាំ២០១១២ : ការរៀបចំឯកសារ
- ខែធ្នូ ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រីជំនាញនៅថ្នាក់ជាតិ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលមន្ត្រីជំនាញនៅថ្នាក់ជាតិ : ១២,៨៤៩ ដុល្លារ

**សរុប : ១២,៨៤៩ ដុល្លារ**

ក្រៅពីអនុវត្តការបណ្តុះបណ្តាល និងសិក្ខាសាលាលើប្រធានបទទាំង០៦ខាងលើ អនុកម្មវិធីទី៤ ដោយមានកិច្ចសហការជាមួយគម្រោងនានាគ្រោងនឹងរៀបចំសិក្ខាសាលពិគ្រោះយោបល់ និងអភិវឌ្ឍសមត្ថភាពលើប្រធានបទមួយចំនួនបន្ថែមទៀតដូចខាងក្រោម ៖

- សិក្ខាសាលាពីគ្រោះយោបល់ស្តីពីយន្តការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្ខាសាលាផ្សព្វផ្សាយស្តីពីយន្តការវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- សិក្ខាសាលាស្តីពីការអនុវត្តសាកល្បងប្រព័ន្ធផ្តល់មូលនិធិដោយមានភ្ជាប់ល័ក្ខខ័ណ្ឌដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្ខាសាលាពិគ្រោះយោបល់បឋមពីគោលនយោបាយអំពីជម្រើសនៃចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីគោលនយោបាយអំពីជម្រើសនៃចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកទី២
- សិក្ខាសាលាផ្សព្វផ្សាយអំពីនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងនីតិវិធីបញ្ជាបយេនឌ័រក្នុងការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអនុវត្តថវិកាក្រុង ស្រុក
- បណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

# អនុកម្មវិធីទី៥

# ផ្នែកទី៥
# អនុកម្មវិធីទី៥ "ក្រសួងផែនការ"

## ៥.១. បណ្តុះបណ្តាលស្តីពីដំណើរការកសាងផែនការ ឃុំ សង្កាត់

### ក). ប្រវត្តិ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងអាណត្តិទីមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមកក្រសួងមហាផ្ទៃ និងក្រសួងផែនការបានចេញប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ និងលេខ២៤២៣ប្រ.ក ចុះថ្ងៃទី០៣ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់។

ក្នុង ផអ៣ អនុកម្មវិធីទី៥ បានផ្តោតទៅលើការសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ឆ្នាំ២០១២ ដើម្បីបន្សុីគ្នាជាមួយសេចក្តីណែនាំបច្ចេកទេសការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អាស្រ័យហេតុនេះវាជាការចាំបាច់ណាស់ដែលក្រសួងផែនការនឹងសហការជាមួយក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទើបនឹងជាប់ឆ្នោត និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិយោគប្រចាំឆ្នាំឃុំ សង្កាត់ដែលបានកែសម្រួល។ អាស្រ័យហេតុនេះ អនុកម្មវិធីទី៥នឹងដាក់បញ្ចូលប្រធានបទស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិយោគប្រចាំឆ្នាំឃុំ សង្កាត់ទៅក្នុងផែនការអភិវឌ្ឍសមត្ថភាពសម្រាប់ឆ្នាំ ២០១២ របស់ គ.ជ.អ.ប។

### ខ).ខ្លឹមសារនៃការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ការប្រើប្រាស់ឧបករណ៍ និងការវិភាគស្ថានភាពឃុំ សង្កាត់
- ការវិភាគបញ្ហា តម្រូវការ និងដំណោះស្រាយ
- ការរៀបចំគោលដៅ និងទិសដៅអភិវឌ្ឍន៍
- ការរៀបចំគម្រោងអាទិភាព

ក្រុមការងារមួយដែលមានក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងស្ថាប័នដែលពាក់ព័ន្ធក្នុងការពិនិត្យ និងកែសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ ព្រមទាំងរៀបចំឯកសារបណ្តុះបណ្តាល។ បន្ទាប់ពីរៀបចំ និងកែសម្រួលសេចក្តីណែនាំនេះក្រុមការងារនឹងដាក់ជូនថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងមហាផ្ទៃពិនិត្យ និងអនុម័ត។

### គ).យុទ្ធសាស្ត្រ

បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងមហាផ្ទៃ ក្រុមការងារនឹងផ្តល់

ការបណ្តុះបណ្តាលដល់ ៖

- ការបណ្តុះបណ្តាលមន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត : អ្នកចូលរួម៨០នាក់ ចំនួនមួយថ្នាក់ បណ្តុះបណ្តាលរយៈពេល០៣ថ្ងៃ
- ការបណ្តុះបណ្តាលបន្ត : ក្រុមការងារថ្នាក់រាជធានី ខេត្ត នឹងបន្តការបណ្តុះបណ្តាលដល់ការិយាល័យគាំទ្រឃុំ សង្កាត់នៃសាលាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់។

**ឃ).ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមីនា ដល់មេសា ឆ្នាំ២០១២ :ការរៀបចំឯកសារ
- ខែឧសភា ឆ្នាំ២០១២ :បណ្តុះបណ្តាលមន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត
- ខែឧសភា ឆ្នាំ២០១២ :ការបណ្តុះបណ្តាលបន្ត

**ង).ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលថ្នាក់រាជធានី ខេត្ត : ១០,៧៤០ដុល្លារ
- ការបណ្តុះបណ្តាលបន្ត : ៤៨,៥០០ដុល្លារ

<u>សរុប : ៥៩,២៤០ ដុល្លារ</u>

## ៥.២. បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក). ប្រវត្តិ**

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងអាណត្តិទីមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមកក្រសួងមហាផ្ទៃ និងក្រសួងផែនការបានចូលរួមគ្នាចេញប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ និងលេខ២៤២៣ប្រ.ក ចុះថ្ងៃទី០៣ ខែកក្កដាឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់។

ជារៀងរាល់ឆ្នាំមុនពេលសមាហរណកម្មផែនការឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ទីរផែនការត្រូវរៀបចំបញ្ចូលគម្រោងអាទិភាពរបស់ឃុំ សង្កាត់ ក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ ហើយផលិតជាតារាងម៉ាទ្រិចផ្ញើរទៅមន្ទីរជំនាញអង្គភាពពាក់ព័ន្ធជុំវិញរាជធានី ខេត្តពិនិត្យ និងគាំទ្រគម្រោង ហើយតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ នឹងប្រើប្រាស់តារាងម៉ាទ្រិចនេះ បង្ហាញជូនដល់អ្នកចូលរួមក្នុងសមាហរណកម្មផែនការឃុំ សង្កាត់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីកៀរគរកថវិកាគាំទ្រ។ អាស្រ័យហេតុនេះ អនុកម្មវិធីទី៥នឹងដាក់បញ្ចូលប្រធានបទស្តីពីការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឆ្នាំ២០១២របស់ គ.ជ.អ.ប។

**ខ).ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ការប្រើប្រាស់ និងបញ្ចូលទិន្នន័យគម្រោងឃុំ សង្កាត់
- ការរៀបចំតារាម៉ាទ្រិចសម្រាប់សមាហរណកម្មផែនការថ្នាក់ស្រុក
- ការត្រួតពិនិត្យ និងតាមដានលទ្ធផលការអនុវត្តគម្រោង

**គ).យុទ្ធសាស្ត្រ**

ការបណ្តុះបណ្តាលប្រធានបទនេះ ក្រុមការងារអនុកម្មវិធីទី៥នឹងបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដែលមានអ្នកចូលរួម៨០នាក់ ដោយរៀបចំចំនួនមួយថ្នាក់ ហើយការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ។

**ឃ).ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមិថុនា ឆ្នាំ២០១២ :ការរៀបចំឯកសារ
- ខែកក្កដា ឆ្នាំ២០១២ :បណ្តុះបណ្តាលដល់មន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត

**ង).ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលថ្នាក់ រាជធានី ខេត្ត : **១០,៧៤០ ដុល្លារ**

### ៥.៣. បណ្តុះបណ្តាលស្តីពីដំណើរការរៀបចំវេទិកាអភិវឌ្ឍន៍រាជធានី ខេត្ត និងសមាហរណកម្មថ្នាក់ស្រុក ក្រុង ខណ្ឌ

**ក).ប្រវត្តិ**

យោងតាមសេចក្តីណែនាំបច្ចេកទេសសម្រាប់រៀបចំសមាហរណកម្មផែនការរបស់ក្រសួងផែនការ ចុះថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០០៤ និងបទពិសោធន៍ក្នុងការអនុវត្តដំណើរការសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ សមាហរណកម្មទទួលបានជោគជ័យអាស្រ័យទៅលើការចូលរួមរបស់អ្នកពាក់ព័ន្ធ និងពេលវេលាក្នុងការត្រៀមរៀបចំសិក្ខាសាលា។

ផ្អែកតាមសេចក្តីណែនាំបច្ចេកទេសនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលបានផ្សព្វផ្សាយដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងបទពិសោធន៍អនុវត្តជាងមួយឆ្នាំកន្លងមក អនុកម្មវិធីទី៥នឹងដំណើរការរៀបចំវេទិកាអភិវឌ្ឍន៍ថ្នាក់រាជធានី ខេត្ត។ បន្ទាប់ពីរៀបចំកែសម្រួល ចាំបាច់ត្រូវមានការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធទាំងអស់។ អាស្រ័យហេតុនេះ អនុកម្មវិធីទី៥នឹងដាក់បញ្ចូលប្រធានបទស្តីពីដំណើរការរៀបចំវេទិកាអភិវឌ្ឍន៍រាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឆ្នាំ២០១២ របស់ គ.ជ.អ.ប។

**ខ).ខ្លឹមសារនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម ៖

- ដំណើរការរៀបចំវេទិកាអភិវឌ្ឍន៍ថ្នាក់រាជធានី ខេត្ត
- ដំណើរការរៀបចំសមាហរណកម្មផែនការថ្នាក់ ក្រុង ស្រុក ខណ្ឌ
- ទំនាក់ទំនងរវាងសមាហរណកម្មផែនការថ្នាក់ ក្រុង ស្រុក ខណ្ឌ ជាមួយនឹងវេទិកាអភិវឌ្ឍន៍ថ្នាក់រាជធានី ខេត្ត

**គ).យុទ្ធសាស្ត្រ**

ក្រសួងផែនការនឹងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ការបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត : អ្នកចូលរួម៨០នាក់ ចំនួនមួយថ្នាក់ បណ្តុះបណ្តាលរយៈពេល០៣ថ្ងៃ
- ការបណ្តុះបណ្តាលបន្ត : ក្រុមការងារថ្នាក់រាជធានី ខេត្ត នឹងបន្តការបណ្តុះបណ្តាលដល់ការិយាល័យគាំទ្រឃុំ សង្កាត់នៃសាលាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកក្កដា-សីហា ឆ្នាំ២០១២ :ការរៀបចំឯកសារ
- ខែកញ្ញា ឆ្នាំ២០១២ :បណ្តុះបណ្តាលមន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្ត
- ខែកញ្ញា ឆ្នាំ២០១២ :ការបណ្តុះបណ្តាលបន្ត

**ង).ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលថ្នាក់រាជធានី ខេត្ត :១០,៧៤០ ដុល្លារ
- ការបណ្តុះបណ្តាលបន្ត : ៧,២០០ដុល្លារ

**<u>សរុប : ១៧,៩៤០ ដុល្លារ</u>**

## ៥.៤. បណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់

**ក). ប្រវត្តិ**

ទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ត្រូវបានរៀបចំឡើងដំបូងនៅក្នុងកម្មវិធីសិលាក្រោមការជួយគាំទ្ររបស់គម្រោង UNDP/OPS/CARERE ដើម្បីប្រើប្រាស់តែក្នុងកម្មវិធីប៉ុណ្ណោះ។ ក្រោយពីការសិក្សាបន្ថែម និងការកែសម្រួលជាច្រើនលើករួចមក ក្រសួងផែនការបានសម្រេចទទួលយកអនុសាសន៍ពីទីប្រឹក្សាបច្ចេកទេសក្នុងការប្រែក្លាយទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ឱ្យទៅជាប្រព័ន្ធព័ត៌មានជាតិមួយ ដើម្បីឱ្យ

ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានសម្រាប់ការអនុវត្តន៍កំណែទម្រង់វិមជ្ឈការនៅកម្ពុជា។

ផ្អែកតាមសេចក្ដីណែនាំបច្ចេកទេសរៀបចំដោយក្រសួងផែនការ នៅខែតុលា ឆ្នាំ២០១១ ការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់នេះមិនមែនជាការប្រមូលទិន្នន័យតាមបែបអង្កេតទេ។ ម្ចាស់ទិន្នន័យភូមិ ឃុំ សង្កាត់ គឺជាមេភូមិ មេឃុំ និង ចៅសង្កាត់ ។ ទិន្នន័យភូមិ ឃុំ សង្កាត់ នឹងជួយដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការរៀបចំឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីជាឧបករណ៍ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ អាស្រ័យហេតុនេះ អនុកម្មវិធីទី៥នឹងដាក់បញ្ចូលប្រធានបទស្ដីពីការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឆ្នាំ២០១២របស់ គ.ជ.អ.ប។

**ខ).ខ្លឹមសារនៃការបណ្ដុះបណ្ដាល**

វគ្គបណ្ដុះបណ្ដាលនេះផ្ដោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ការបំពេញទិន្នន័យតាមកម្រងសំណួរ
- វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ
- វិធីសាស្ត្រត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ

**គ).យុទ្ធសាស្ត្រ**

ក្រសួងផែនការនឹងអនុវត្តការបណ្ដុះបណ្ដាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ការបណ្ដុះបណ្ដាលដល់មន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការនិងវិនិយោគរាជធានី ខេត្ត : អ្នកចូលរួម៨០នាក់ ចំនួនមួយថ្នាក់ បណ្ដុះបណ្ដាលរយៈពេល០៣ថ្ងៃ
- ការបណ្ដុះបណ្ដាលបន្ត : ក្រុមការងារថ្នាក់រាជធានី ខេត្ត នឹងបន្តការបណ្ដុះបណ្ដាលដល់ការិយាល័យគាំទ្រឃុំ សង្កាត់នៃសាលាក្រុង ស្រុក ខណ្ឌ ស្មៀន មេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**ឃ).ពេលវេលាសម្រាប់ការបណ្ដុះបណ្ដាល**

- ខែសីហា-កញ្ញា ឆ្នាំ២០១២ :ការរៀបចំឯកសារ
- ខែតុលា ឆ្នាំ២០១២ :បណ្ដុះបណ្ដាលមន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត
- ខែតុលា ឆ្នាំ២០១២ :ការបណ្ដុះបណ្ដាលបន្ត (អាស្រ័យលើរាជធានី ខេត្ត)

**ង).ថវិកាគ្រោងសម្រាប់ការបណ្ដុះបណ្ដាល**

- បណ្ដុះបណ្ដាលថ្នាក់រាជធានី ខេត្ត : ១០,៧៤០ដុល្លារ
- ការបណ្ដុះបណ្ដាលបន្ត : ៦៤,៧៨៥ដុល្លារ

**សរុប : ៧៥,៥២៥ ដុល្លារ**

## ៥.៥. បណ្តុះបណ្តាលស្តីពីការកែច្នៃ និងផលិតឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត

### ក). ប្រវត្តិ

ជារៀងរាល់ឆ្នាំ មេភូមិ ស្មៀនឃុំ សង្កាត់ បន្ទាប់ពីបានទទួលសៀវភៅសម្រាប់សម្រង់ទិន្នន័យភូមិពីមន្ទីរផែនការរាជធានី ខេត្ត សម្រាប់ស្រង់លេខស្ថិតិក្នុងភូមិរបស់ខ្លួន ពេលស្រង់រួចត្រូវផ្ញើមកមន្ទីរផែនការដើម្បីបញ្ចូលទិន្នន័យ និងកែច្នៃទិន្នន័យនៅក្នុងប្រព័ន្ធ CDB ។ ការរៀបចំឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ គឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចដទៃទៀតរបស់មន្ទីរផែនការរាជធានី ខេត្ត ក្នុងដំណើរការគាំទ្រការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

ចំណែកឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជារៀងរាល់ឆ្នាំ ក្រសួងផែនការគ្រាន់តែផ្តល់ការបណ្តុះបណ្តាលអំពីការកែច្នៃ និងវិភាគទិន្នន័យ ហើយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្តរៀបចំឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗដើម្បីជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលការបណ្តុះបណ្តាលនេះចាំបាច់ត្រូវការរំលឹកឡើងវិញជាបន្តបន្ទាប់ ។ អាស្រ័យហេតុនេះ អនុកម្មវិធីទី៥នឹងដាក់បញ្ចូលប្រធានបទស្តីពីការកែច្នៃ និងផលិតឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តទៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឆ្នាំ២០១២របស់ គ.ជ.អ.ប ។

### ខ).ខ្លឹមសារនៃការបណ្តុះបណ្តាល

ក្រសួងផែនការនឹងរៀបចំខ្លឹមសារមេរៀនផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ការបញ្ចូលទិន្នន័យ
- ការកែច្នៃ និងវិភាគទិន្នន័យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ការរៀបចំឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

### គ).យុទ្ធសាស្ត្រ

ក្រសួងផែនការនឹងអនុវត្តការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ក្រុមការងារអនុកម្មវិធីទី៥នឹងបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរផែនការ និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដែលមានអ្នកចូលរួម៨០នាក់ ដោយរៀបចំចំនួនមួយថ្នាក់ ហើយការបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ ។

### ឃ).ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែតុលា ឆ្នាំ២០១២ : ការរៀបចំឯកសារ
- ខែវិច្ឆកា ឆ្នាំ២០១២ : បណ្តុះបណ្តាលមន្ត្រីមន្ទីរផែនការ

### ង).ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- បណ្តុះបណ្តាលថ្នាក់រាជធានី ខេត្ត : ១០,៧៤០ដុល្លារ

# អនុក្រមវិធីទី៦

# ផ្នែកទី៦

# អនុកម្មវិធីទី៦ "សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់"

ក្នុងឆ្នាំ ២០១២ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់មានវគ្គបណ្តុះបណ្តាលចំនួន០១ប្រធានបទដូចខាងក្រោម ៖

## ៦.១. សញ្ញាណមូលដ្ឋាន នៃសមាគមអាជ្ញាធរមូលដ្ឋាន (ទ្រឹស្តី និងឧទាហរណ៍)

### ក). ប្រវត្តិ

ចំណុចសំខាន់របស់កម្មវិធី ជអ៣ គឺការពង្រឹង និងអភិវឌ្ឍន៍ស្ថាប័ន ដែលក្នុងនោះការអភិវឌ្ឍធនធានមនុស្ស គឺជាគន្លឹះដ៏សំខាន់ និងចាំបាច់បំផុត ។

ការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាដំណើរការមួយដែលគោរពតាមគោលការណ៍ស្ម័គ្រចិត្ត និងលទ្ធិប្រជាធិបតេយ្យ ដូច្នេះតម្រូវឱ្យមានការផ្សព្វផ្សាយ និងពិគ្រោះយោបល់ឱ្យបានទូលំទូលាយ ដែលជាហេតុនាំឱ្យមានតម្រូវការធនធាន និងពេលវេលាជាបង្គួរ ។

ទោះបីជាសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់បានបង្កើតក៏ពិតមែន ប៉ុន្តែការចូលរួមរបស់តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ គឺជាការចាំបាច់ និងមិនអាចខ្វះបាន។ ហេតុដូច្នេះហើយ ទើបសម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានលើកផែនការអភិវឌ្ឍន៍សមត្ថភាពជូនដល់តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១លើកក្នុងឆ្នាំ២០១២ នេះ ។

### ខ. ខ្លឹមសារ នៃការបណ្តុះបណ្តាល

- សញ្ញាណមូលដ្ឋានស្តីពីសមាគមអាជ្ញាធរមូលដ្ឋាន (ជាទ្រឹស្តី និងឧទាហរណ៍)
- ផែនការយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់
- ភាពជាដៃគូ និងការតស៊ូមតិ ក្នុងភាពជាតំណាងសមាជិក
- គ្រោងឆ្អឹងនៃគំរូសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ ក្រោមជាតិនៅកម្ពុជា។

### គ. វិធីសាស្ត្រ នៃការបណ្តុះបណ្តាល

- <u>**សិក្ខាកាម ៖**</u> ជ្រើសរើសតំណាងក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ (៥២រូប) ។
- <u>**វិធីសាស្ត្រ ៖**</u> បទបង្ហាញជាទ្រឹស្តី ការផ្តល់ជាឧទាហរណ៍ និងការពិភាក្សា ។

ឃ. ពេលវេលា

- ខែមេសា ឆ្នាំ ២០១២ : ការរៀបចំទស្សទានដើម្បីសុំការគាំទ្រពីថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ
- ខែឧសភា ឆ្នាំ២០១២ : ការរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល
- ខែឧសភា ឆ្នាំ២០១២ : រៀបចំភស្តុភារ រដ្ឋបាល និងទំនាក់ទំនង
- ខែឧសភា ឆ្នាំ២០១២ : អនុវត្តការបណ្តុះបណ្តាល

ង. ថវិកា

- ថ្លៃរៀបចំវគ្គបណ្តុះបណ្តាល ៖ ៤,៦៦០ដុល្លារ

<u>**សរុប ៖ ៤,៦៦០ ដុល្លារ**</u>

# ប្រធានបទបណ្តុះបណ្តាល
# ដែលកំណត់ដោយរាជធានី ខេត្ត

## ប្រធានបទដែលរាជធានី ខេត្តបានកំណត់សម្រាប់ការបណ្ដុះបណ្ដាលក្នុងរាជធានី ខេត្តរបស់ខ្លួន

ក្នុងឆ្នាំ ២០១២ រាជធានី ខេត្តបានកំណត់វគ្គបណ្ដុះបណ្ដាលសម្រាប់ក្រុមគោលដៅនៅក្នុងរាជធានី ខេត្ត របស់ខ្លួនដោយឡែក១លើប្រធានបទមួយចំនួនដូចខាងក្រោម ៖

| ល.រ | ប្រធានបទ | ក្រុមគោលដៅ | ថវិកា | រាជធានី ខេត្ត |
|---|---|---|---|---|
| ០១ | រំលឹកឡើងវិញស្ដីពីការអនុវត្តគម្រោងមូលនិធិ ឃុំ សង្កាត់ | ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ខេត្ត, ទីប្រឹក្សាខេត្ត មន្ត្រីគាំទ្របច្ចេកទេស, មន្ត្រីទីចាត់ការនានា មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងអ្នកទទួលការ ក្រុមប្រឹក្សាឃុំ ជនបង្គោលថ្នាក់ឃុំ និងស្មៀនឃុំ សង្កាត់ មេឃុំ ចៅសង្កាត់, ទីប្រឹក្សាក្រុង ស្រុក, មន្ត្រី POCក្រុង ស្រុក, មន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់, | $ 23,049.00 | កំពង់ធំ កណ្ដាល កំពង់ស្ពឺ រតនគិរី ប៉ៃលិន មណ្ឌលគិរី កំពត កំពង់ឆ្នាំង ស្ទឹងត្រែង ឧត្តរមានជ័យ កែប ព្រៃវែង ព្រះសីហនុ ស្ទឹងត្រែង បន្ទាយមានជ័យ |
| ០២ | រំលឹកឡើងវិញស្ដីពីកម្មវិធីវិនិយោគឃុំ សង្កាត់ | ការិយាល័យទាំងពាររបស់ក្រុងស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងទីប្រឹក្សាក្រុង ស្រុក ប្រធានការិយាល័យផែនការក្រុង ស្រុក | $ 17,783.00 | បាត់ដំបង កំពង់ចាម ស្វាយរៀង តាកែវ ឧត្តរមានជ័យ ពោធិ៍សាត់ ព្រៃវែង |
| ០៣ | រំលឹកឡើងវិញស្ដីពីនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុឃុំសង្កាត់ | មន្ត្រី POC ថ្នាក់ខេត្ត ក្រុង ស្រុក និង PCD Team ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និង មន្ត្រីគាំទ្រឃុំ សង្កាត់ (CETSO) និងតំណាងការិយាល័យចំណុះសាលាក្រុង ស្រុក មន្ទីរសេវាសង្គមក្រុង ស្រុក | $ 18,400.00 | កំពង់ធំ ក្រចេះ កំពង់ស្ពឺ ប៉ៃលិន កំពង់ចាម ស្វាយរៀង ស្ទឹងត្រែង ឧត្តរមានជ័យ ព្រៃវែង ព្រះសីហនុ ស្ទឹងត្រែង បន្ទាយមានជ័យ |
| ០៤ | វគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ | ក្រុមអភិវឌ្ឍន៍សមត្ថភាពខេត្ត អភិបាលក្រុង ស្រុក នាយករដ្ឋបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ជិទប់ទី១ ជិទប់ទី២ ស្មៀនឃុំ សង្កាត់ ទីប្រឹក្សាកម្មវិធីក្រុង ស្រុក មន្ត្រីការិយាល័យផែនការ និងគាំទ្រ ឃុំ សង្កាត់ | $ 15,673.00 | សៀមរាប កំពង់ចាម ព្រៃវែង |
| ០៥ | រំលឹកឡើងវិញស្ដីពីសុវត្ថិភាពដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិច | មន្ត្រី POC ថ្នាក់ខេត្ត ក្រុង ស្រុក ទីប្រឹក្សា ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងមន្ត្រីគាំទ្រឃុំ សង្កាត់ ជនបង្គោលសុវត្ថិភាពដីធ្លី និងបរិស្ថាន នាយករដ្ឋបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់ ជិទប់ទី១ ជិទប់ទី២ | $ 15,645.00 | កំពង់ធំ បាត់ដំបង កណ្ដាល សៀមរាប កំពង់ចាម តាកែវ កែប បន្ទាយមានជ័យ |

| ល.រ | ប្រធានបទ | ក្រុមគោលដៅ | ថវិកា | រាជធានី ខេត្ត |
|---|---|---|---|---|
| ០៦ | រំលឹកឡើងវិញស្តីពីការរៀបចំផែនការ ការតាមដាន ត្រួតពិនិត្យ និងរបាយការណ៍ ផអពា | ទីប្រឹក្សាខេត្ត ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ខេត្ត មន្ត្រីតាមដានត្រួតពិនិត្យថ្នាក់ខេត្ត ក្រុមប្រឹក្សាក្រុងស្រុក, គណៈអភិបាលក្រុងស្រុក មន្ត្រីការិយាល័យចំហេះរដ្ឋបាលក្រុង ស្រុក ទីប្រឹក្សាក្រុង ស្រុក មន្ត្រីគាំទ្រឃុំ សង្កាត់ តំណាងទីចាត់ការនានា នាយករដ្ឋបាលសាលាស្រុក ស្មៀនឃុំ មន្ត្រីក្រុង ស្រុក មេឃុំ ចៅសង្កាត់ | $ 14,914.00 | ក្រចេះ រតនគិរី សៀមរាប ប៉ៃលិន មណ្ឌលគិរី កំពត កំពង់ឆ្នាំង កំពង់ចាម ស្វាយរៀង ពោធិ៍សាត់ ព្រៃវែង ព្រះសីហនុ ប៉ៃលិន ភ្នំពេញ បន្ទាយមានជ័យ |
| ០៧ | ការរៀបចំថវិកាឆ្នាំ២០១៣ និងបិទគណនេយ្យឆ្នាំ២០១២ និងការទូទាត់ | មន្ត្រីមកពីទីចាត់ការនានា ទីប្រឹក្សាខេត្ត, ក្រុមអភិវឌ្ឍន៍សមត្ថភាពខេត្ត មន្ត្រីតាមទីចាត់ការនានា, មន្ត្រីរតនាគារ មន្ត្រីក្រុងស្រុក មន្ត្រីការិយាល័យផែនការ មន្ត្រីជំនួយការព័ត៌មានវិទ្យាក្រុងស្រុក មេឃុំស្មៀន មន្ត្រីប/ទគាំទ្រឃុំ សង្កាត់ និងទីប្រឹក្សាក្រុង ស្រុក រដ្ឋគណនេយ្យករបុរេប្រទានស្រុក មេឃុំ ចៅសង្កាត់, ស្មៀនឃុំ សង្កាត់, និងគាំទ្រឃុំ សង្កាត់ គណនេយ្យករឃុំ ក្រុមប្រឹក្សាឃុំ និង | $ 13,669.00 | កំពង់ធំ កណ្តាល រតនគិរី កោះកុង កំពង់ឆ្នាំង ស្វាយរៀង តាកែវ ពោធិសាត់ |
| ០៨ | ការបណ្តុះបណ្តាល ការប្រមូល ការផលិត និងការចែកចាយទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ សម្រាប់តម្រូវការកសាងផែនការ | ប្រធានការិយាល័យផែនការ ក្រុង ស្រុក ទីចាត់ការផែនការវិនិយោគ មន្ទីរផែនការ ក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិក គ.ផ.ថ ស្មៀនឃុំ សង្កាត់ | $ 11,088.00 | កំពង់ចាម តាកែវ |
| ០៩ | វគ្គបណ្តុះបណ្តាលរំលឹកស្តីពីចំណេះដឹងព័ត៌មានវិទ្យា | មន្ត្រីជំនួយការព័ត៌មានវិទ្យាស្រុក ទីប្រឹក្សាក្រុង ស្រុក ទីប្រឹក្សាខេត្ត មន្ត្រី POC តំណាងទីចាត់ការនានា នាយករដ្ឋបាលសាលាស្រុក មន្ត្រីសាលាក្រុង ស្រុក, នាយក និងមន្ត្រីទីចាត់ការ, មន្ត្រីគាំទ្របច្ចេកទេស នាយករដ្ឋបាលសាលាខេត្ត មន្ត្រីផ្នែកព័ត៌មានវិទ្យា | $ 10,219.00 | កណ្តាល ក្រចេះ រតនគិរី កោះកុង សៀមរាប កំពង់ឆ្នាំង កំពង់ចាម តាកែវ ព្រៃវែង មណ្ឌលគិរី ព្រះសីហនុ ភ្នំពេញ |
| ១០ | សិក្ខាសាលាត្រួតពិនិត្យ ឆ្លុះបញ្ចាំង ការអនុវត្តន៍ផអពា ចុងឆ្នាំថ្នាក់ខេត្ត | ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលក្រុង ស្រុក និងមន្ត្រីសេវាសង្គម មន្ត្រីទាំងអស់ ស្រុក និងមេឃុំ ក្រុមប្រឹក្សាឃុំ ស្មៀន | $ 6,040.00 | កណ្តាល ស្វាយរៀង ភ្នំពេញ |

| ល.រ | ប្រធានបទ | ក្រុមគោលដៅ | | ថវិកា | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ១១ | ការគ្រប់គ្រង, ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | សមាជិកក្រុមប្រឹក្សាខេត្ត, គណៈអភិបាល, នាយក នាយករងរដ្ឋបាល, នាយក នាយករងទីចាត់ការ, ប្រធាន អនុការិយាល័យ និងមន្ត្រីសំខាន់ៗនៃសាលាខេត្ត ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ខេត្ត មេឃុំ, ស្មៀន, ជនបង្គោលM&Eឃុំ | $ | 5,309.00 | ពោធិ៍សាត់ ព្រៃវែង |
| ១២ | វំលឹកឡើងវិញស្តីពីអភិបាលកិច្ចល្អសម្រាប់ឃុំ-សង្កាត់ | ក្រុម CDខេត្ត, នាយក/នាយករងរដ្ឋបាល នាយក/នាយករងទីចាត់ការ និងមន្ត្រីសំខាន់ៗរបស់សាលាខេត្ត, សមាជិកក្រុមប្រឹក្សា, BoG, ប្រធាន/អនុការិយាល័ ក្រុង ស្រុក និងមន្ត្រីសំខាន់ៗ មន្ត្រីបច្ចេកទេសគាំទ្រឃុំ ក្រុមប្រឹក្សាឃុំ មន្ត្រីក្រុងស្រុក ស្មៀន | $ | 5,144.00 | កណ្តាល កែប ពោធិសាត់ ព្រៃវែង |
| ១៣ | វំលឹកឡើងវិញស្តីពីគ.ក.ន.ក និងការអនុវត្តគម្រោងសេវាសង្គម | ការិយាល័យទាំងពារបស់ក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ តំណាងគ.ក.ន.ក និងទីប្រឹក្សាក្រុង ស្រុក | $ | 6,630.00 | បាត់ដំបង សៀមរាប |
| ១៤ | បណ្តុះបណ្តាលស្តីពីការកសាងកម្មវិធីវិនិយោគ ខេត្ដ ក្រុង ស្រុក រួមទាំងវិធីសាស្ត្រឆ្លើយតប និងបញ្ហាបយេនឌ័រ | គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុមការងារកសាងផែនការថ្នាក់ខេត្ត ក្រុមការងារកសាងផែនការក្រុង ស្រុក | $ | 4,577.00 | កំពង់ចាម តាកែវ ឧត្តរមានជ័យ ភ្នំពេញ |
| ១៥ | ការសរសេរសំណើគម្រោងខ្នាតតូចសម្រាប់ឃុំសង្កាត់ | ក្រុមគ្រូបង្គោលខេត្ត និងមន្ត្រី POC ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ទីចាត់ការផែនការវិនិយោគ មន្ត្រីអភិវឌ្ឍន៍សមត្ថភាពថ្នាក់ខេត្ត, | $ | 4,438.00 | កំពង់ស្ពឺ ប៉ៃលិន តាកែវ ស្ទឹងត្រែង កែប បន្ទាយមានជ័យ |
| ១៦ | វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃការងារឃុំសង្កាត់ និងការប្រមូលទិន្នន័យ | មន្ត្រីទីចាត់ការធនធានមនុស្ស ទីចាត់ការផែនការវិនិយោគ មន្ត្រីអភិវឌ្ឍសមត្ថភាពថ្នាក់ខេត្ត, គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំសង្កាត់ មេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ មន្ត្រីPOCគាំទ្រឃុំ សង្កាត់ ទីប្រឹក្សាក្រុង ស្រុក និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគ មន្ត្រីM&E, | $ | 4,326.00 | ក្រចេះ រតនគិរី តាកែវ ព្រៃវែង |
| ១៧ | វំលឹកឡើងវិញស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ | មេឃុំ ចៅសង្កាត់ និងគណៈកម្មការគ្រប់គ្រងគម្រោង | $ | 2,984.00 | កំពង់ធំ សៀមរាប ស្ទឹងត្រែង |

| ល.រ | ប្រធានបទ | ក្រុមគោលដៅ | ថវិកា | រាជធានី ខេត្ត |
|---|---|---|---|---|
| ១៨ | រំលឹកឡើងវិញស្តីពីការប្រើប្រាស់ឧបករណ៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការគណនា (មូលដ្ឋានគ្រឹះគម្រោងហេដ្ឋា រចនាសម្ព័ន្ធ) | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ អ្នកទទួលការ មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | $ 2,117.50 | កំពង់ធំ រតនគិរី កំពត កំពង់ឆ្នាំង កំពង់ចាម តាកែវ ឧត្តរមានជ័យ ព្រៃវែង ភ្នំពេញ បន្ទាយមានជ័យ |
| ១៩ | រំលឹកឡើងវិញស្តីពីជំនាញបណ្តុះបណ្តាល និងទស្សនយោនទ័រក្នុងការអភិវឌ្ឍសមត្ថភាព | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ទីប្រឹក្សាក្រុង ស្រុក មន្ត្រីក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ | $ 1,796.00 | កំពង់ធំ កោះកុង ស្ទឹងត្រែង ភ្នំពេញ |
| ២០ | សិក្ខាសាលាឆ្លុះបញ្ចាំងពីការវិភាគចំណុចខ្លាំងនិងខ្សោយនៃការអនុវត្តមុខងារ និងសមត្ថភាពក្រុមប្រឹក្សាឃុំ | មន្ត្រីក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ | $ 1,297.00 | ស្ទឹងត្រែង |
| ២១ | បណ្តុះបណ្តាលអំពីការតាមដាន និងវាយតម្លៃសម្រាប់ក្រុង ស្រុក ខណ្ឌ | មន្ត្រីតាមដាន ទីប្រឹក្សាក្រុង ស្រុក នាយករដ្ឋបាលក្រុង ស្រុក | $ 1,290.00 | តាកែវ |
| ២២ | វគ្គតម្រង់ទិសស្តីពីការប្រើប្រាស់ប្រព័ន្ធ PID DIS PDB CDB និង BID | ទីប្រឹក្សាក្រុង ស្រុក មន្ត្រីជំនួយការព័ត៌មានវិទ្យា អង្គការសង្គមស៊ីវិល រដ្ឋបាលក្រុង ស្រុក ខេត្ត | $ 1,231.00 | កោះកុង ឧត្តរមានជ័យ |
| ២៣ | វគ្គផ្សព្វផ្សាយស្តីពីគោលនយោបាយគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងសារពើភ័ណ្ឌ | មន្ត្រី POC តំណាងទីចាត់ការនានា ទីប្រឹក្សាក្រុង ស្រុក មន្ត្រីជំនួយការព័ត៌មានវិទ្យា ជំនួយការការិយាល័យ មន្ត្រីសាលាក្រុង ស្រុក | $ 1,143.00 | ក្រចេះ |
| ២៤ | រំលឹកឡើងវិញស្តីពីការអនុវត្តកិច្ចសន្យា និងបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ | អ្នកទទួលការក្នុងបញ្ជី មន្ត្រីគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ | $ 1,108.00 | កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង |
| ២៥ | វគ្គតម្រង់ទិសអំពីការគ្រប់គ្រងការិយាល័យ | មន្ត្រីទីចាត់ការសាលាខេត្ត និងក្រុង ស្រុក ព្រមទាំងទីប្រឹក្សាក្រុង ស្រុក | $ 972.00 | កែប |

| ល.រ | ប្រធានបទ | ក្រុមគោលដៅ | ថវិកា | រាជធានី ខេត្ត |
|---|---|---|---|---|
| ២៦ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួលសម្រាប់ការិយាល័យកិច្ចការនារីស្រុក ដើម្បីគាំទ្រដល់ជនបង្គោលទទួល បន្ទុកកិច្ចការនារី និងកុមារនៃគ.ក.ន.ក ឃុំ សង្កាត់ | ជនបង្គោល គ.ក.ន.ក មន្ត្រីការិ. កិច្ចការនារីក្រុង ស្រុក គ.ក.ស.ក | $ 786.00 | តាកែវ |
| ២៧ | វគ្គបណ្តុះបណ្តាលអ្នកទទួលការស្តីពីនីតិវិធីលទ្ធកម្ម | អ្នកទទួលការ មន្ត្រី POCខេត្ត ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេស និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | $ 623.00 | ក្រចេះ សៀមរាប ស្វាយរៀង ឧត្តរមានជ័យ ភ្នំពេញ |
| ២៨ | រំលឹកឡើងវិញស្តីពីការសិក្សា និងរុស្តរ៉ងារបច្ចេកទេសគម្រោងឃុំ-សង្កាត់ | មន្ត្រីបច្ចេកទេសបោដ្ឋារចនាសម្ព័ន្ធ | $ 489.00 | កណ្តាល កំពង់ស្ពឺ |
| ២៩ | ការប្រមូលទិន្នន័យរដ្ឋបាលក្រុង ស្រុកឆ្នាំ២០១២ | មន្ត្រីជំនួយការព័ត៌មានវិទ្យាស្រុក | $ 412.00 | កណ្តាល |
| ៣០ | វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងទំនាក់ទំនង | រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | $ 652.00 | ប៉ៃលិន ភ្នំពេញ |
| ៣១ | វគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីជាតិ និងផែនការអនុវត្តបីឆ្នាំដំបូងដល់ក្រុមប្រឹក្សាខេត្ត មន្ទីរជំនាញ | ក្រុមប្រឹក្សាក្រុងស្រុក១៥នាក់, តំណាងមន្ទីរវិស័យជុំវិញខេត្ត២៧នាក់, អង្គការនានា១៥នាក់ | $ 278.00 | កំពង់ឆ្នាំង |
| ៣២ | វគ្គបណ្តុះបណ្តាលស្តីពី អូតូខេត | មន្ត្រីគាំទ្របច្ចេកទេស | $ 136.00 | កោះកុង |
| ៣៣ | វគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មន្ត្រីជ្រើសរើសថ្មី | $ 367.00 | ស្វាយរៀង ភ្នំពេញ បន្ទាយមានជ័យ |
| ៣៤ | វគ្គរំលឹកឡើងវិញស្តីពីតួនាទី និងរបៀបរបបការងាររបស់មេភូមិ | ប្រធានភូមិ ក្រុមប្រឹក្សាឃុំ ស្មៀន | $ 114.00 | កែប |

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី១

## កាលវិភាគអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ ២០១២

| ល.រ | ប្រធានបទ | ពេលវេលា (ខែ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| | **អនុកម្មវិធីទី១** | | | | | | | | | | | | |
| ១.១. | ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | ✓ | | | | | | | | | |
| ១.២. | ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | ✓ | ✓ | | | | | |
| ១.៣. | វគ្គតម្រង់ទិសដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប | | | | | ✓ | | | | | | | |
| ១.៤. | គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងតួនាទីរបស់ទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប | | | | | ✓ | ✓ | | | | | | |
| ១.៥. | តម្រង់ទិសសម្រាប់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | | | | ✓ | | | | | | | | |
| ១.៦. | សិក្ខាសាលាស្តីពីយុទ្ធសាស្ត្រផ្តល់សេវាសម្របសម្រួលក្រុមប្រឹក្សា | | | | | | | ✓ | | | ✓ | | |
| ១.៧. | សិក្ខាសាលាស្តីពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ | | | | | | | | ✓ | | | ✓ | |
| ១.៨. | សិក្ខាសាលាជាតិផ្លាស់ប្តូរបទពិសោធន៍ស្តីពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល | | | ✓ | | | | | | | | | |
| ១.៩. | ការតាមដាន និងវាយតម្លៃសម្រាប់ថ្នាក់រាជធានី ខេត្ត | | | | | | ✓ | | | | | | |
| ១.១០. | ការតាមដាន និងវាយតម្លៃសម្រាប់ក្រសួង ស្ថាប័ន | | | | | | | ✓ | | | | | |
| ១.១១. | ប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា | | | | | | ✓ | | | | ✓ | | |
| ១.១២. | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអព | | | | ✓ | | | | | | | | |
| ១.១៣. | ប្រព័ន្ធទិន្នន័យតាមដានការអនុវត្ត AWPB | | | | | | ✓ | | | | | ✓ | |
| ១.១៤. | ការរៀបចំតារាង AWPB តាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់អនុកម្មវិធី និងថ្នាក់ក្រោមជាតិ | ✓ | | | | | | | ✓ | | | | |
| ១.១៥. | ភាពជាអ្នកដឹកនាំ និងបណ្តាញការងារ | | | | | | ✓ | | | | | | |
| ១.១៦. | ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអព | | | | ✓ | | ✓ | | | | | | |

| ល.រ | ប្រធានបទ | ពេលវេលា (ខែ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.១៧. | ការពង្រឹងតួនាទីអនុប្រធានអចិន្ត្រៃយ៍របស់ គ.ក.ស.ក និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ | | | | ✓ | | | | | | | | |
| ១.១៨. | ការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី តេស្តបេតុង ឋានលេខា និង អីភីអេស | | | | ✓ | | | | | | | | |
| ១.១៩. | វគ្គតម្រង់ទិសសម្រាប់សវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន | | | | ✓ | | ✓ | | | | | | |
| ១.២០. | សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការរៀបចំគម្រោងថ្នាក់ក្រោមជាតិ | | | | ✓ | ✓ | ✓ | | | | | | |
| ១.២១. | ប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប | | | | | | | ✓ | | | | | |
| ១.២២. | ការបណ្តុះបណ្តាលទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ | | | | | | ✓ | | | | | | |
| ១.២៣. | ការរៀបចំគោលនយោបាយ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ | | | | | | | | | | | | |
| ១.២៤. | ការរៀបចំផែនទីមុខងារ | | | | | | | | | | | | |
| ១.២៥. | ការពិនិត្យមុខងារឡើងវិញ | | | | | | | | | | | | |
| | **អនុកម្មវិធីទី២** | | | | | | | | | | | | |
| ២.១. | ការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក | | | | ✓ | ✓ | | | | | | | |
| ២.២. | កិច្ចការរដ្ឋបាលក្រុង ស្រុក | | | | | | | ✓ | ✓ | | | | |
| ២.៣. | វគ្គពង្រឹងបរិស្ថានការអភិវឌ្ឍស្ថាប័ន | | | | ✓ | ✓ | | ✓ | | | | | |
| ២.៤. | ជំនាញអភិវឌ្ឍស្ថាប័ន | | | | | ✓ | | | ✓ | | ✓ | | |
| ២.៥. | ទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព | | ✓ | ✓ | | | | | | | | | |
| ២.៦. | ជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍសមត្ថភាព | | | | | | ✓ | | | | | | |
| ២.៧. | ជំនាញអភិវឌ្ឍន៍សមត្ថភាព | | ✓ | ✓ | | | | | | | | | |
| ២.៨. | សេវាសង្គមសម្រាប់ គ.ក.ន.ក | | | | | | | | | ✓ | ✓ | | |
| | **អនុកម្មវិធីទី៣** | | | | | | | | | | | | |
| ៣.១. | ផ្សព្វផ្សាយអំពីគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក | | | | | | ✓ | | | | | ✓ | |

| ល.រ | ប្រធានបទ | ពេលវេលា (ខែ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| | រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | | | | | | | |
| **អនុកម្មវិធីទី៤** | | | | | | | | | | | | | |
| ៤.១. | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ផអព | | | | ✓ | ✓ | ✓ | | | | | | |
| ៤.២. | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក | | | | | ✓ | ✓ | ✓ | | | | | |
| ៤.៣. | ការអនុវត្តថវិកាក្រុង ស្រុក ឆ្នាំ២០១២ | | | | ✓ | ✓ | | | | | | | |
| ៤.៤. | សិក្ខាសាលាពិនិត្យលើឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | | | | | | ✓ | ✓ | | | | | |
| ៤.៥. | បណ្តុះបណ្តាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ | | | | | | | | | | ✓ | ✓ | |
| ៤.៦. | ការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ប្រចាំឆ្នាំ | | | | | | | | | | | ✓ | ✓ |
| **អនុកម្មវិធីទី៥** | | | | | | | | | | | | | |
| ៥.១. | ដំណើរការកសាងផែនការឃុំ សង្កាត់ | | | | | ✓ | | | | | | | |
| ៥.២. | ការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ | | | | | | | ✓ | | | | | |
| ៥.៣. | ការរៀបចំវេទិកាស្តីពីកម្មវិធីវិនិយោគរាជធានី ខេត្ត និងការរៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ រួមទាំងវិធីសាស្ត្រឆ្លើយតប និងបញ្ជ្រាបយេនឌ័រ | | | | | | | | | ✓ | | | |
| ៥.៤. | ការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ សម្រាប់តម្រូវការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | | | | | | | ✓ | | |
| ៥.៥. | ការកែច្នៃ និងការផលិតឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត | | | | | | | | | | | ✓ | |
| **អនុកម្មវិធីទី៦** | | | | | | | | | | | | | |
| ៦.១. | សញ្ញាណមូលដ្ឋាននៃសមាគមអាជ្ញាធរមូលដ្ឋាន (ទ្រឹស្តី និងឧទាហរណ៍) | | | | | ✓ | | | | | | | |

# ឧបសម្ព័ន្ធទី២

## ឧបសម្ព័ន្ធទី២ ៖

## តារាងតម្រូវការថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ ២០១២

| ល.រ | ប្រធានបទ | ចំនួនថវិកា | ប្រភពថវិកា | ផ្សេងៗ |
|---|---|---|---|---|
| | **អនុកម្មវិធីទី១** | | | |
| ១.១. | ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 14744.00 | កញ្ចប់រួម | |
| ១.២. | ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | 9500.00 | កញ្ចប់រួម | |
| ១.៣. | វគ្គតម្រង់ទិសដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប | 1200.00 | កញ្ចប់រួម | |
| ១.៤. | គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងតួនាទីរបស់ទីប្រឹក្សាលេខាធិការដ្ឋាន គ.ជ.អ.ប | 75000.00 | កញ្ចប់រួម | |
| ១.៥. | តម្រង់ទិសសម្រាប់បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | 24620.00 | កញ្ចប់រួម | |
| ១.៦. | សិក្ខាសាលាស្តីពីយុទ្ធសាស្ត្រផ្តល់សេវាសម្របសម្រួលក្រុមប្រឹក្សា | 17224.00 | កញ្ចប់រួម | |
| ១.៧. | គោលការណ៍សំខាន់ៗនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ | 19400.00 | កញ្ចប់រួម | |
| ១.៨. | សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ស្តីពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល | 9280.00 | កញ្ចប់រួម | |
| ១.៩. | ការតាមដាន និងវាយតម្លៃសម្រាប់ថ្នាក់រាជធានី ខេត្ត | 32950.00 | កញ្ចប់រួម | |
| ១.១០. | ការតាមដាន និងវាយតម្លៃសម្រាប់ក្រសួង ស្ថាប័ន | 9800.00 | កញ្ចប់រួម | |
| ១.១១. | ប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា | 10936.00 | កញ្ចប់រួម | |
| ១.១២. | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីប្រព័ន្ធទិន្នន័យបុគ្គលិកនៃផអពា | 9240.00 | កញ្ចប់រួម | |
| ១.១៣. | ប្រព័ន្ធទិន្នន័យតាមដាន AWPB | 15120.00 | កញ្ចប់រួម | |
| ១.១៤. | ការរៀបចំតារាង AWPB តាមរយៈប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់អនុកម្មវិធី និងថ្នាក់ក្រោមជាតិ | 15120.00 | កញ្ចប់រួម | |
| ១.១៥. | ភាពជាអ្នកដឹកនាំ និងបណ្តាញការងារ | 200000.00 | UNICEF | |
| ១.១៦. | ការបញ្ជ្រាបយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងអនុកម្មវិធីនៃផអពា | 17840.00 | កញ្ចប់រួម | |
| ១.១៧. | ការពង្រឹងតួនាទីអនុប្រធានអចិន្ត្រៃយ៍របស់ គ.គ.ស.ក និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ | 13000.00 | កញ្ចប់រួម | |
| ១.១៨. | ការប្រើប្រាស់ឧបករណ៍ ឌីស៊ីភី គេស្តបេតុង ឋានលេខា និង អីភីអេស | 11220.00 | កញ្ចប់រួម | |

| ល.រ | ប្រធានបទ | ចំនួនថវិកា | ប្រភពថវិកា | ផ្សេងៗ |
|---|---|---|---|---|
| ១.១៩. | វគ្គតម្រង់ទិសសម្រាប់សវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន | 2968.00 | កញ្ចប់រួម | |
| ១.២០. | សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការរៀបចំគម្រោងថ្នាក់ក្រោមជាតិ | 8055.00 | កញ្ចប់រួម | |
| ១.២១. | ប្រព័ន្ធគ្រប់គ្រង និងសម្របសម្រួលផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប | 720.00 | កញ្ចប់រួម | |
| ១.២២. | ការបណ្តុះបណ្តាលទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ | 18480.00 | កញ្ចប់រួម | |
| ១.២៣. | ដំណើរការផ្ទេរមុខងារ | 32440 | កញ្ចប់រួម | |
| | **សរុបកម្មវិធីទី១** | **568,857.00** | | |
| | **អនុកម្មវិធីទី២** | | | |
| ២.១. | ការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក | 102,230.00 | កញ្ចប់រួម | |
| ២.២. | កិច្ចការរដ្ឋបាលក្រុង ស្រុក | 99,850.00 | កញ្ចប់រួម | |
| ២.៣. | វគ្គតម្រង់ទិសការអភិវឌ្ឍស្ថាប័ន | 69,120.00 | កញ្ចប់រួម | |
| ២.៤. | ជំនាញអភិវឌ្ឍន៍ស្ថាប័ន | 53,040.00 | កញ្ចប់រួម | |
| ២.៥. | ទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍន៍សមត្ថភាព | 6,705.00 | កញ្ចប់រួម | |
| ២.៦. | ជំនាញអភិវឌ្ឍន៍សមត្ថភាព និងទស្សនទានយេនឌ័រ និងឧបករណ៍វិភាគយេនឌ័រក្នុងការអភិវឌ្ឍន៍សមត្ថភាព | 5,890.00 | កញ្ចប់រួម | |
| ២.៧. | ជំនាញអភិវឌ្ឍន៍សមត្ថភាព | 31,520.00 | កញ្ចប់រួម | |
| ២.៨. | សេវាសង្គមសម្រាប់ គ.ក.ន.ក | 434,585.00 | UNICEF | |
| | **សរុបសម្រាប់អនុកម្មវិធីទី២** | **802,940.00** | | |
| | **អនុកម្មវិធីទី៣** | | | |
| ៣.១. | ផ្សព្វផ្សាយអំពីគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 82280 | កញ្ចប់រួម | |
| | **សរុបសម្រាប់អនុកម្មវិធីទី៣** | **82,280.00** | | |
| | **អនុកម្មវិធីទី៤** | | | |
| ៤.១. | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ជអព | 21,942.00 | កញ្ចប់រួម | |

| ល.រ | ប្រធានបទ | ចំនួនថវិកា | ប្រភពថវិកា | ផ្សេងៗ |
|---|---|---|---|---|
| ៤.២. | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក | 95,097.00 | កញ្ចប់រួម | |
| ៤.៣. | ការអនុវត្តថវិកាក្រុង ស្រុក ឆ្នាំ២០១២ | 65,824.00 | កញ្ចប់រួម | |
| ៤.៤. | សិក្ខាសាលាពិនិត្យឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | 12,651.00 | កញ្ចប់រួម | |
| ៤.៥. | បណ្តុះបណ្តាលបំប៉នអំពីប្រព័ន្ធគណនេយ្យ និងនីតិវិធីទូទាត់ថវិកាក្រុង ស្រុក ខណ្ឌ | 7,909.00 | កញ្ចប់រួម | |
| ៤.៦. | ការបិទបញ្ជីថវិការាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់ ប្រចាំឆ្នាំ | 12,849.00 | កញ្ចប់រួម | |
| | **សរុបសម្រាប់អនុកម្មវិធីទី៤** | **216,272.00** | | |
| | **អនុកម្មវិធីទី៥** | | | |
| ៥.១. | ដំណើរការកសាងផែនការឃុំ សង្កាត់ | 10,740.00 | កញ្ចប់រួម | |
| ៥.២. | ការគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ | 10,740.00 | កញ្ចប់រួម | |
| ៥.៣. | ការរៀបចំវេទិកាស្តីពីកម្មវិធីវិនិយោគរាជធានី ខេត្ត និងការរៀបចំសិក្ខាសាលាសមាហរណកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ រួមទាំងវិធីសាស្ត្រឆ្លើយតប និងបញ្ហាបយេនឌ័រ | 10,740.00 | កញ្ចប់រួម | |
| ៥.៤. | ការប្រមូលទិន្នន័យមូលដ្ឋាន ភូមិ ឃុំ សង្កាត់ សម្រាប់តម្រូវការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | 10,740.00 | កញ្ចប់រួម | |
| ៥.៥. | ការកែច្នៃ និងការផលិតឯកសារពត៌មានស្តីពីស្ថានភាពឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត | 10,740.00 | កញ្ចប់រួម | |
| | **សរុបសម្រាប់អនុកម្មវិធីទី៥** | **53,700.00** | | |
| | **អនុកម្មវិធីទី៦** | | | |
| ៦.១. | សញ្ញាណមូលដ្ឋាននៃសមាគមអាជ្ញាធរមូលដ្ឋាន (ទ្រឹស្តី និងឧទាហរណ៍) | 4,660.00 | កញ្ចប់រួម | |
| | **សរុបសម្រាប់អនុកម្មវិធីទី៦** | **4,660.00** | | |
| | ការបណ្តុះបណ្តាលលើប្រធានបទដែលកំណត់ដោយរាជធានី ខេត្ត | 190,094.00 | កញ្ចប់រួម | |
| | **សរុបរួម** | | | **1,918,803.00** |

| ល.រ | ប្រធានបទ | ចំនួនថវិកា | ប្រភពថវិកា | ផ្សេងៗ |
|---|---|---|---|---|
| | | | 80 | |